វិចារណកថា EDITORIAL

គ្មានអ្នកណាអាចមកបំផ្លាញដំណើរការកែចម្រើននៃកម្ពុជាបានឡើយ

No One Can Obstruct Cambodia's Path of Progress

*រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ បាន និងកំពុងដឹកនាំប្រទេសជាតិឲ្យមានការចម្រើនយ៉ាងលឿន ជាមួយនឹងការជំរុញកំណែទម្រង់លើគ្រប់វិស័យ ដែលបានផ្តល់លទ្ធផលជាក់ស្តែងជាប្រយោជន៍ជូនប្រជាជនយ៉ាងច្រើន។ បច្ចុប្បន្ននេះ ទិដ្ឋភាពទូទៅទាំងនយោបាយសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សេដ្ឋកិច្ច សង្គមកិច្ចប្រជាធិបតេយ្យ សិទ្ធិសេរីភាព និងនីតិរដ្ឋ កំពុងមានការវិវត្តន៍ប្រកបដោយភាពវិជ្ជមាន ធ្វើឲ្យសាធារណមតិជាតិ និងអន្តរជាតិ បានវាយតម្លៃថា កម្ពុជាកំពុងមានការផ្លាស់ប្តូរយ៉ាងល្អប្រសើរ ។*

ក្នុងរយៈពេលជាងពីរទសវត្សចុងក្រោយនេះ កម្ពុជាត្រូវបានចាត់ទុកជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចគួរឲ្យស្ងប់ស្ងែង ជាមួយនឹងកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំជាង ៧% ។ ជាប្រទេសដែលធ្លាប់មានជម្លោះផ្ទៃក្នុង អស្ថិរភាព សង្គ្រាមរ៉ាំរ៉ៃរាប់ទសវត្សន៍ និងជាប្រទេសដ៏ក្រីក្របំផុតមួយ បានប្រែក្លាយទៅជាប្រទេសដែលមានសន្តិភាព ស្ថិរភាព ឯកភាពជាតិ និងមានសេដ្ឋកិច្ចរីកចម្រើនយ៉ាងលឿនក្នុងទ្វីបអាស៊ី ។ តាមការព្យាករណ៍ កម្ពុជាត្រូវបានរំពឹងថានឹងបន្តរក្សាបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ រហូតដល់ឆ្នាំ ២០១៨ ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចមានភាពល្អប្រសើរអតិជរណាមានកម្រិតទាប អត្រាប្តូរប្រាក់មានស្ថិរភាពទុនបម្រុងអន្តរជាតិមានកំណើនល្អ ឯអតុល្យភាពពាណិជ្ជកម្មកាន់តែត្រូវបានកាត់បន្ថយ ។ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗកើនពីចំនួន ៧៦០ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៨ ដល់ ១១៥៨ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៥ ហើយនៅឆ្នាំ ២០១៦ នេះ អាចបន្តកើនឡើងដល់ជាង ១៣០០ ដុល្លារអាមេរិក ដែលធ្វើឲ្យកម្ពុជាប្រែក្លាយពីប្រទេសមានចំណូលទាប មកជាប្រទេសមានចំណូលមធ្យមកម្រិតទាប ភាពក្រីក្រត្រូវបានកាត់បន្ថយយ៉ាងរហ័សពី ៥៣,២% នៅឆ្នាំ ២០០៤ មកត្រឹម ១៣,៥% នៅឆ្នាំ ២០១៤ ។

កម្ពុជាមានសុទិដ្ឋិនិយមដ៏មុតមាំចំពោះអនាគតនៃសេដ្ឋកិច្ចរបស់ខ្លួន ។ វិស័យឧស្សាហកម្មកាត់ដេរ ដែលជាកម្លាំងចលករដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅតែមានភាពរឹងមាំ ។ បច្ចុប្បន្ននេះ នៅទូទាំងប្រទេសមានរោងចក្រសហគ្រាស គ្រឹះស្ថានការងារសរុបទាំងអស់ចំនួន ៦៧៤២ មានកម្មករនិយោជិត និងអ្នកបម្រើការងារចំនួន ១.១១៨.១៧៥ នាក់ ក្នុងនោះមានរោងចក្រកាត់ដេរ និងស្បែកជើង ១០២៧ មានពលករបម្រើការងារជាង ៧០ ម៉ឺននាក់ ។ វិស័យសំណង់ក៏នៅតែមានកំណើនល្អ ។ ក្នុងរយៈពេល ៨ ខែដើមឆ្នាំនេះ ទុនវិនិយោគក្នុងវិស័យសំណង់មានទំហំដល់ ៧.២១៨ លានដុល្លារ គឺកើនឡើងជាង ៤០០% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ វិស័យកសិកម្មនឹងមានការដើរឡើងបន្តិចក្នុងរយៈពេលមធ្យមខាងមុខ ។ វិស័យទេសចរណ៍រក្សាបានកំណើនរៀងរាល់ឆ្នាំ ដែលបានរួមចំណែកប្រមាណជា ១២% នៃផលិតផលក្នុងស្រុកសរុប ។ ក្នុងឆ្នាំ ២០១៥ កម្ពុជាទទួលបានទេសចរណ៍ប្រមាណ ៤,៨ លាននាក់ នាំចំណូលប្រមាណ ៣ ពាន់លានដុល្លារ និងផ្តល់ឱកាសការងារប្រមាណ

The Royal Government of the Fifth Legislative National Assembly led by SamdechAkkaMohaSenaPadeiTecho Hun Sen has made rapid progresses and driven reforms in all fields with concrete results for people. Currently, political aspect, security, public order, socio-economic condition, democracy, freedom, and rule of laws advance in a positive manner generating national and international public opinion to make an assessment that Cambodia is makingchange for the better.

Over the last more than two decades, admired for its growth, Cambodia has been yielding its economic growth at an average over 7% annually. A country inflicted by internal conflicts and protracted wars for decades, and considered one of the poorest country, has transformed into a country of peace, national unity and rapid economic progress in Asia. The prediction has it that Cambodia expects a continued economic growth of 7% per annum until 2018 with sound macro stability, low inflation, stabilized exchange rate, good growing international reserves, and a reduced imbalance of trade. The country's GDP for each person has grown from 760 USD in 2008 to 1,158 USD in 2015, and in 2016, the trend will grow to 1,300 USD. This will bring Cambodia from a low-income to lower-middle income country, where poverty rate reduces quickly from 53.2% in 2014 to 13.5% in 2014.

Cambodia is firmly positive for its economic future. The garment industry, the most vigorous force for growth in Cambodia, indicates its firmness. Currently, in the whole country, there are in all 6,742 employment establishments that employ 1,118,175 workers. Among them, 1,027 factories producing apparels and footwear employed over 700,000 employees. Construction maintains its growth. In the past eight months of this year, capital investment in construction sector recorded some 7,218 million USD, 400% bigger compared to the same period last year. Agriculture will rise a little bit in the medium term to come.

Tourism maintains a steady growth contributing roughly 12% to the country's GDP. In 2015, Cambodia received about 4.8 million tourists bringing in about three billion USD and providing works for some 620,000 people. For 2016, Cambodia expects to receive some 5 million tourists. In energy, the country has provided electricity on a wider scale to rural area with prospect of electricity reaching every home by 2020. The country is in busy pace of building and developing potential hydraulic works, communication infrastructures.

Besides important national roads, the Royal Government has been building and/or improving rural road conditions. In actual term, in its five years project (2015 to 2020), the Royal Government built some 500 Kilometers of roads as its first stage in seven provinces in 2015. By November 2016, the second-stage project to improve rural roads will commence

៦២ ម៉ឺននាក់ ។ សម្រាប់ឆ្នាំ ២០១៦ នេះ កម្ពុជារំពឹងថានឹងទទួលបានទេសចរណ៍អន្តរជាតិប្រមាណ ៥ លាននាក់ ។ វិស័យថាមពលអគ្គិសនីកំពុងមានការរីកចម្រើន ដែលបានផ្ដត់ផ្ដង់អគ្គិសនីដល់ទីជនបទ ឈានទៅសម្រេចគោលដៅគ្រប់ភូមិមានអគ្គិសនីទៅដល់នៅឆ្នាំ ២០២០ ។ ប្រព័ន្ធធារាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ កំពុងត្រូវបានកសាង និងអភិវឌ្ឍនៅទូទាំងប្រទេស ក្លាយជាសសៃឈាមសេដ្ឋកិច្ចដ៏មានសក្តានុពល ។ ក្រៅពីផ្លូវជាតិសំខាន់ៗ រាជរដ្ឋាភិបាលបានស្ថាបនា និងកែលម្អផ្លូវនៅជនបទ ជាក់ស្តែងក្នុងគម្រោង ៥ ឆ្នាំ (២០១៥-២០២០) រាជរដ្ឋាភិបាលកម្ពុជាស្ថាបនាបានផ្លូវប្រវែង ៥០០ គីឡូម៉ែត្រ ក្នុងជំហានទី ១ នៅខេត្តចំនួន ៧ កាលពីឆ្នាំ ២០១៥ ហើយនៅក្នុងខែវិច្ឆិកាឆ្នាំ ២០១៦ នេះ គម្រោងកែលម្អផ្លូវជនបទជំហានទី ២ ប្រវែង ១២០០ គីឡូម៉ែត្រ នៅខេត្តចំនួន ១០ ដែលត្រូវចំណាយថវិកា ១៩២ លានដុល្លារអាមេរិក នឹងត្រូវចាប់ផ្ដើមដំណើការ ។ ការប្រមូលចំណូលចូលថវិការដ្ឋមានការកើនឡើងគួរគត់សម្គាល់ក្នុងរយៈពេល ៨ ខែដើមឆ្នាំនេះ ពន្ធដារប្រមូលចំណូលបាន ១.០៧៥ លានដុល្លារ ស្មើនឹង ៧៥,៦៩% នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ។ ដោយឡែកក្នុងឆមាសទី ១ ឆ្នាំ ២០១៦ ការប្រមូលចំណូលពន្ធគយ និងអាករសម្រេចបានជាង ៨៨៣ លានដុល្លារអាមេរិក ក្នុងឆមាសទី ១ ឆ្នាំ ២០១៦ មានកំណើនប្រមាណណ ១៩,៤% ធៀបនឹងឆមាសទី ១ ឆ្នាំ ២០១៥ គឺសម្រេចបានប្រមាណជា ៥៥% នៃផែនការចំណូលដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ។ ការវិនិយោគផ្ទាល់ពីបរទេសនៅតែមានសកម្មភាពខ្លាំង អាស្រ័យដោយសក្តានុពល និងកាលានុវត្តភាពវិនិយោគនៅកម្ពុជា ជាពិសេសគឺកត្តាសន្តិភាព ស្ថិរភាព ការជឿទុកចិត្តទៅលើសមត្ថភាព និងការដឹកនាំរបស់រាជរដ្ឋាភិបាល ។

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការថែរក្សាសន្តិសុខសណ្ដាប់ធ្នាប់សង្គម ទប់ស្កាត់ឧបាកល និងសកម្មភាពប្រទូសរ៉ាយរបស់ពួកប្រឆាំង និងមជ្ឈដ្ឋានអតតិនានា ដែលព្យាយាមរារាំងការរីកចម្រើននៃសង្គមជាតិ និងជំរុញឲ្យកម្ពុជាធ្លាក់ទៅក្នុងកលិយុគសារជាថ្មីទៀត ដើម្បីសម្រេចមហិច្ឆតានយោបាយរបស់ពួកគេ ។ ជាក់ស្តែងតាំងពីក្រោយការបោះឆ្នោតឆ្នាំ ២០១៣ ពួកគេបានធ្វើសកម្មភាពប្រទូសរ៉ាយឥតឈប់ឈរតាមរូបភាពជាច្រើន ទាំងក្នុងវិស័យនយោបាយ សន្តិសុខ ច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច និងទំនាក់ទំនងអន្តរជាតិ ។ ប៉ុន្តែពួកគេមិនអាចសម្រេចបំណងបានឡើយ ព្រោះថាអ្វីៗដែលពួកគេធ្វើនេះបានបំពានលើរដ្ឋធម្មនុញ្ញ និងច្បាប់ និងដើរផ្ទុយពីផលប្រយោជន៍របស់ជាតិ និងប្រជាជន ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់ជំហរដ៏ច្បាស់លាស់ ក្នុងការអនុវត្តច្បាប់ ដើម្បីការពាររដ្ឋធម្មនុញ្ញ ការពាររាល់សមិទ្ធផលនៃសង្គមជាតិ ការពារដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅដ៏សុខសាន្តរបស់ប្រជាជន ។ សេចក្ដីត្រូវការចាំបាច់របស់ប្រជាជននៅពេលនេះ គឺសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខសណ្ដាប់ធ្នាប់សង្គម ដើម្បីការអភិវឌ្ឍ ។

នៅសល់តែ ៣ ខែទៀតប៉ុណ្ណោះ ឆ្នាំ ២០១៦ នឹងបញ្ចប់ហើយ ឆ្នាំ ២០១៧ នឹងមកដល់ ។ ប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែមានគោលបំណងចង់ឲ្យមាតុភូមិខ្លួនបន្តរីកចម្រើន និងគង់វង្សស្ថិតស្ថេរជារៀងដរាប អាស្រ័យហេតុនេះ យើងទាំងអស់គ្នាបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ពង្រឹងសន្តិភាពស្ថិរភាព ឯកភាពជាតិ លើកកម្ពស់ស្មារតីទទួលខុសត្រូវចំពោះជោគវាសនាប្រទេសជាតិ ចៀសវាងរាល់អំពើណាដែលធ្វើឲ្យខ្មែរបែកបាក់សាមគ្គីគ្នា ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិបតេយ្យ លើកតម្កើងសិទ្ធិសេរីភាព សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងការគោរពអនុវត្តច្បាប់ ។ លើមូលដ្ឋាននេះ យើងពិតជាសម្រេចបានសមិទ្ធផលថ្មីៗទៀតក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម នៅក្នុងឆ្នាំ២០១៦នេះ ហើយអាចឈានចូលឆ្នាំ២០១៧ ប្រកបដោយមោទនភាព និងការសង្ឃឹមជឿជាក់ ។

ទស្សនាវដ្ដីប្រជាជន

building another 1,200 Kilometers in ten provinces at a sum of 192 million USD.

Income gathering for state budget grows markedly in the first eight months of this year. Income from tax reached 1,075 billion USD or 75.69% of objective defined by financial law for management in 2016. Particularly, in the first six month of 2016, income collection from tax and excise had reached 883 million USD, or 19.4% more than the same period last year. This means that the collection achieved 55% of planned income defined in the financial law for management in 2016. Foreign direct investment is still active thanks to potential and opportunity in Cambodia, especially the factors of peace, stability, and trust on capability and leadership of the Royal Government.

The Royal Government of Cambodia pays undeterred attention on safeguarding security, social order, preventing controversial tricks and actions of the opposition and ill-willed circles, who always attempt to hinder national progress and pushing Cambodia into turmoil once again to realize their ambitions. In reality, after the general elections in 2013, they conducted endlessly hostile actions in many forms – in politics, security, law, socio-economic and international relations. However, they could not realize their aims because everything they did violated the Constitution and laws, and were against national and people's interests. The Royal Government of Cambodia adheres strictly to a position of implementing law to protect the Constitution, national achievements, socio-economic development, and peaceful life of the people. What our people need in the present time are peace, political stability, security, and social order for the country's development.

In about three more months, the year 2016 will end and the year 2017 will arrive. Every Cambodian wishes to see their motherland continues to advance and exist forever. It is therefore important for everyone to take active part in implementing the political platform of the Royal Government, strengthening peace, stability, national unity, raising high spirit of responsibility for the sake of national destiny, avoiding actions leading to division among Cambodians, and adhering strictly to principles of democracy, freedom, human dignity, and abiding by laws. On this basis, we will be able to realize further achievements in socio-economic development for the year 2016, while stepping into the year 2017 with pride, hope and confidence./.

THE PRACHEACHUN MAGAZINE

ទោះក្ដៅតម្លៃណាក្ដី ត្រូវតែការពារសុខសន្តិភាពជូនប្រជាជន

រយៈពេលជាង ៣ ទសវត្ស ចាប់ពីឆ្នាំ ១៩៧០ មក កម្ពុជាបានឆ្លងកាត់នូវសង្គ្រាមដ៏វ៉ាវ៉ៃ និងអំពើប្រល័យពូជសាសន៍ដែលបានបង្ករនូវសោកនាដកម្ម និងគ្រោះមហន្តរាយដ៏ធំធេងបំផុតដែលពុំអាចនឹងពណ៌នាបានឡើយ ។ ភាពវិនាសហិនហោចនៃប្រជាជាតិមួយនេះ គឺកើតឡើងពីមហិច្ឆតាណ្ដោតអំណាចរបស់អ្នកដឹកនាំនយោបាយមួយចំនួន ដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ជាន់ឈ្លីផលប្រយោជន៍ជាតិ និងប្រជាជន ព្រមទាំងការជ្រៀតជ្រែករបស់បរទេសដែលព្យាយាមច្បាមយកកម្ពុជាដើម្បីបម្រើយុទ្ធសាស្ត្ររបស់ខ្លួន ។ គឺមានតែចាប់ពីចុងឆ្នាំ ១៩៩៨ មកប៉ុណ្ណោះ ដែលប្រជាជនកម្ពុជាបានស្គាល់នូវសន្តិភាពពេញលេញ ព្រមទាំងការឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង តាមរយៈនយោបាយឈ្នះ ឈ្នះ ដែលដឹកនាំដោយសម្ដេចតេជោ **ហ៊ុន សែន** ។ ប៉ុន្តែបច្ចុប្បន្ន ក្នុងពេលប្រទេសជាតិកំពុងស្ថិតក្នុងសុខសន្តិភាព និងការអភិវឌ្ឍ ប្រជាជនរស់នៅប្រកបដោយសុភមង្គលនោះ បែរជាក្រុមអ្នកនយោបាយប្រឆាំងខិតខំប្រើប្រាស់គ្រប់ឧបាយកលដើម្បីបង្ករភាពរឹតត្បិតជាថ្មីក្នុងសង្គម បំផ្លាញសេចក្ដីសុខរបស់ប្រជាជនទៅវិញ ។

ជាក់ស្ដែង ក្នុងពេលថ្មីៗនេះ ពួកមេដឹកនាំគណបក្សប្រឆាំងបានប្រកាសពីការរៀបចំផែនការធ្វើមហាបាតុកម្ម ដោយប្រឌិតហេតុផលអំពីបញ្ហាប្រជាធិបតេយ្យ សិទ្ធិសេរីភាព អភ័យឯកសិទ្ធិសភា ការរឹតត្បិតសកម្មភាពគណបក្សប្រឆាំង ។ល។ ពួកគេបានអះអាងថា គេធ្វើឡើងក្នុងគោលបំណងឲ្យរាជរដ្ឋាភិបាលគោរពកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងបញ្ឈប់ការកៀបសង្កត់ ។ ប៉ុន្តែការពិត ការព្រមានធ្វើមហាបាតុកម្មនេះកើតឡើងភ្លាមៗក្រោយពេលដែលតុលាការសម្រេចផ្ដន្ទាទោសលើជនជាប់ចោទ កឹម សុខា ដាក់ពន្ធនាគារ ៥ ខែ និងពិន័យជាប្រាក់ ៨ សែនរៀល ពីបទ "បដិសេធការចូលខ្លួន "តាមមាត្រា ៥៣៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ ក្រោយពេលតុលាការប្រកាសសាលក្រម ក្រុមសមាជិកសភាគណបក្សប្រឆាំងបានផ្សព្វផ្សាយឯកសារមួយឈ្មោះថា "ឯកសារសស្ដីពីការចោទប្រកាន់ប្រឆាំងនឹងលោក កឹម សុខា គឺជារឿងនយោបាយ "ដែលឯកសារមួយនេះ មានគោលដៅបំភ័ន់សាធារណមតិជាតិ និងអន្តរជាតិឲ្យយល់ច្រឡំលើចំណាត់ការដ៏ត្រឹមត្រូវតាមច្បាប់របស់តុលាការចំពោះករណីល្មើសច្បាប់របស់បុគ្គលជាមេដឹកនាំនៃគណបក្សប្រឆាំង និងជនមួយចំនួនទៀត សំដៅប្រែក្លាយរឿងឯកជនរបស់បុគ្គលទាំងនោះឲ្យទៅជាបញ្ហានយោបាយ ហើយជំរុញទៅរកការចរចានយោបាយដើម្បីដកចេញនូវបទចោទប្រកាន់របស់តុលាការទៅលើបុគ្គលទាំងនោះ ។ ម្យ៉ាងទៀត គឺបើកឱកាសហុចឲ្យពួកគេនឹងប្រែក្លាយមហាបាតុកម្មនេះឲ្យទៅជាចលនាផ្ដួលរំលំរាជរដ្ឋាភិបាលស្របច្បាប់តែម្ដង ដូចដែលពួកគេធ្លាប់បានព្យាយាមអនុវត្តរួចមកហើយនៅក្រោយពេលបោះឆ្នោតនាឆ្នាំ ២០១៣ និងដើមឆ្នាំ ២០១៤ តែត្រូវទទួលបរាជ័យនោះ ។ ចំពោះការទាមទារឲ្យរាជរដ្ឋាភិបាលគោរពកិច្ចព្រមព្រៀងទីក្រុងប៉ារីស ក៏ជាប្រការមិនសមហេតុផលដែរ ពីព្រោះថារាល់គោលការណ៍ធំៗដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ បានប្រែក្លាយទៅជាខ្លឹមសារនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជារួចទៅហើយ ដែលត្រូវបានគោរព និងអនុវត្តយ៉ាងម៉ឺងម៉ាត់ក្នុងប្រាំនីតិកាលមកនេះ។ ប៉ុន្តែគឺគណបក្សប្រឆាំងទៅវិញទេ ដែលប្រព្រឹត្តផ្ទុយពីគោលការណ៍គ្រឹះនៃប្រជាធិបតេយ្យ និងសិទ្ធិសេរីភាព ការឡើងរឿងបុគ្គលឲ្យទៅជារឿងនយោបាយ រំលោភលើរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ដែលក្នុងនោះ មានទាំងការយកបញ្ហាអភ័យឯកសិទ្ធិសភាមកប្រើប្រាស់ខុសពីខ្លឹមសារច្បាប់ទៀតផង ។

នៅចំពោះមុខការអំពាវនាវឲ្យចូលរួមមហាបាតុកម្មតើអ្នកគាំទ្រក្រុមប្រឆាំងត្រូវតែបន្តធ្វើតាមដូចពេលមុនឬ? អ្នកទាំងនោះភាគច្រើនក៏បានមើលឃើញច្បាស់ហើយនូវភាពមិនស្មោះត្រង់ ពុតត្បុត ភាពកំសាក និងអត្តចរិត ភាពស្មោកគ្រោករបស់មេដឹកនាំនៃក្រុមនេះ ជាពិសេសប្រជាជនកម្ពុជាទាំងមូល មិនថាមាននិន្នាការនយោបាយណាទេ គឺទាំងអស់គ្នាសុទ្ធតែត្រូវការសន្តិភាព សន្តិសុខ ឯកភាពជាតិ និងការអភិវឌ្ឍ ។

គួររំឭកថា ក្រោយការបោះឆ្នោតសកលថ្នាក់ជាតិថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ គណបក្សប្រឆាំងបានបង្កើតសភាពការណ៍ដ៏ស្មុគស្មាញ និងគ្រោះថ្នាក់បំផុត ដោយដឹកនាំការធ្វើបាតុកម្មតាមដងផ្លូវយ៉ាងអនាធិបតេយ្យ ស្រែកបដិសេធលទ្ធផលនៃការបោះឆ្នោត មិនចូលរួមកិច្ចប្រជុំសភាលើកដំបូងតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ទាមទារឲ្យសម្ដេចតេជោ **ហ៊ុន សែន** ដែលជានាយករដ្ឋមន្ត្រីស្របច្បាប់ចុះចេញពីតំណែង និងទាមទារឲ្យមានការបោះឆ្នោតឡើងវិញជាដើម ។ បាតុកម្មនៅពេលនោះបានក្លាយជាកុប្បកម្មដ៏ហិង្សា ដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់មនុស្ស ខូចខាតទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិប្រជាជនអស់យ៉ាងច្រើន ។ ច្បាស់ណាស់ថា កាលនោះពួកគេបានធ្វើអាជីវកម្មនយោបាយយ៉ាងថោកទាបលើឆន្ទៈរបស់អ្នកគាំទ្រខ្លួន ដើម្បីមហិច្ឆតាផ្ទាល់របស់ពួកខ្លួន ។ ប្រសិនបើពេលនោះ រាជរដ្ឋាភិបាលមិនអនុវត្តវិធានការច្បាប់ដ៏ម៉ឺងម៉ាត់ដើម្បីការពារសន្តិភាព សណ្ដាប់ធ្នាប់ ១ ១ ១

សម្ដេចចក្រី ហេង សំរិន អញ្ជើញទៅកាន់បិណ្ឌទី ៤ នៅវត្តប្រជុំនទី ហៅវត្តក្រពើហារ នៅក្រុងតាខ្មៅ

*សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ អញ្ជើញកាន់បិណ្ឌទី ៤ នៅវត្ត ប្រជុំនទី ហៅវត្តក្រពើហារ ស្ថិតនៅក្រុងតាខ្មៅ ខេត្តកណ្ដាល*

កាលពីថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១៦ សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ រួមជាមួយឯកឧត្ដម លោកជំទាវ ជាសមាជិក សមាជិការដ្ឋសភា ទីប្រឹក្សា មន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា និងបងប្អូនពុទ្ធបរិស័ទជិតឆ្ងាយជាច្រើនទៀត បានអញ្ជើញទៅកាន់បិណ្ឌទី ៤ នៅវត្ត ប្រជុំនទី ហៅ វត្តក្រពើហារ ស្ថិតនៅក្រុងតាខ្មៅ ខេត្តកណ្ដាល ។ ឯកឧត្ដម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងលោកជំទាវក៏មានវត្តមាននៅក្នុងពិធីកាន់បិណ្ឌនេះដែរ ។

បន្ទាប់ពីថ្វាយគ្រឿងសក្ការៈបូជាដល់ព្រះពុទ្ធរូប និងបង្សុកូលសមាទានសីលរួចមក សម្ដេចចក្រីប្រធានរដ្ឋសភា ព្រមទាំងក្រុមគ្រួសារ និងបងប្អូនពុទ្ធបរិស័ទជិតឆ្ងាយ បានអញ្ជើញប្រារព្ធធ្វើកិច្ចតាមប្រពៃណីព្រះពុទ្ធសាសនា រាប់បាត្រ និងវេចង្ហាន់ប្រគេនព្រះសង្ឆ ទៅតាមទំនៀមទម្លាប់ប្រពៃណីព្រះពុទ្ធសាសនា ឧទ្ទិសកុសលផលបុណ្យដល់មាតាបិតា ជីដូនជីតា ញាតិទាំង ៧ សន្ដានដែលបានចែកឋានទៅលោកខាងមុខ សូមបានដល់ឋានសុខគតិភពកុំបីឃ្លាងឃ្លាតឡើយ និងបានបួងសួងឲ្យកូនចៅនៅខាងក្រោយជួបតែសេចក្ដីសុខ ចម្រុងចម្រើន និងមានអាយុយឺនយូរ ។

នៅក្នុងពិធីបុណ្យកាន់បិណ្ឌនេះដែរ សម្ដេចចក្រី **ហេង សំរិន** និងលោកជំទាវក៏បាននាំយកទេយ្យទាន និងថវិកាផ្ទាល់របស់សម្ដេចចំនួនជាង ១៦ លានរៀល ប្រគេនដល់ព្រះសង្ឆ និងប្រគេនសម្រាប់កសាងសមិទ្ធផលនានានៅវត្តក្រពើហារនេះផងដែរ ។

គួររំលឹកដែរថា បុណ្យកាន់បិណ្ឌភ្ជុំបិណ្ឌជាពិធីសាសនាដ៏សំខាន់បំផុតនៅប្រទេសកម្ពុជា ហើយពិធីកាន់បិណ្ឌនេះមានរយៈពេល ១៥ ថ្ងៃ ដែលមានតាំងពីសម័យអង្គរមកម្ល៉ះ ។ ពិធីបុណ្យនេះតែងចាប់ផ្ដើមពីថ្ងៃទី១រោចខែភទ្របទ ដែលឆ្នាំនេះ ត្រូវនឹងថ្ងៃទី ១៧ ខែកញ្ញា រហូតដល់ថ្ងៃទី១៥រោចខែភទ្របទ ត្រូវនឹងថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០១៦ ។

ទាក់ទិនទៅនឹងពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌដែរនេះ ប្រជាពលរដ្ឋខ្មែរដែលកាន់សាសនាព្រះពុទ្ធ តែងមានជំនឿថា នៅក្នុងរដូវកាន់បិណ្ឌ-ភ្ជុំ-បិណ្ឌ យមរាជតែងបានដោះលែងព្រលឹងអ្នកដែលស្លាប់ទៅជាពិសេសព្រលឹងអ្នកដែលស្លាប់ រសាត់អណ្ដែតដូចជាមនុស្សទុគ្គត ក្មេងកំព្រា មនុស្សគ្មានទីពឹង ឬមនុស្សដែលស្លាប់ក្នុងសង្គ្រាមដែលគេមិនបានធ្វើបុណ្យ ឲ្យមកជួបជុំឪពុកម្ដាយ បងប្អូន សាច់ញាតិ ។ ដូច្នេះ" ការពិតន័យសំខាន់របស់ភ្ជុំបិណ្ឌគឺត្រូវជួយព្រលឹងតែលតោលឲ្យចាប់ជាតិ ហើយមិនទុកឲ្យនៅតែលតោលគ្មានទីបញ្ចប់នោះទេ" ប្រសិនបើព្រលឹងខ្មោចមករកឪពុកម្ដាយ បងប្អូនសាច់ញាតិ ក្នុងរយៈពេល ៧ វត្ត មិនឃើញទេ ព្រលឹងខ្មោចនោះនឹងដាក់បណ្ដាសារឲ្យយើងរកទទួលទាន មិនមានបានដូចគេដូចឯងនោះទេ ។ ហេតុនេះហើយបានជារយៈពេល ១៤ ថ្ងៃ នៃថ្ងៃកាន់បិណ្ឌ ប្រជាពលរដ្ឋខ្មែរកាន់សាសនាព្រះពុទ្ធ តែងមកជួបជុំគ្នានៅតាមវត្តអារាមមុនពេលថ្ងៃរះ ក្នុងបំណងដើរប្រទក្សិណបីជុំដោយស្ងៀមស្ងាត់ជុំវិញព្រះវិហារ ដើម្បីបោះបាយបិណ្ឌ ដែលបកប្រែជាភាសាខ្មែរថា "ភ្ជុំបិណ្ឌ " ដើម្បីផ្ដល់អាហារដល់ព្រលឹងដែលវិលវល់ ដើម្បីឲ្យពួកគេអាចទៅចាប់ជាតិបាន ។

ពិធីបុណ្យនេះ ធ្វើឡើងនៅពេលយប់ក្នុងចំណោមមនុស្សស្ងៀមស្ងាត់មុនពេលថ្ងៃរះ ហើយប្រគេនចង្ហាន់ដល់ព្រះសង្ឆនៅពេលថ្ងៃ ដើម្បីឧទ្ទិសកុសលផលបុណ្យឲ្យបានដល់វិញ្ញាណក្ខន្ធឪពុកម្ដាយ បងប្អូនញាតិទាំង ៧ សន្ដានដែលបានស្លាប់ទៅ បានទទួលកុសលផលបុណ្យ ទៅសោយសុខក្នុងឋានសុគតិភព ហើយឆាប់បានចាប់ជាតិកំណើតមកវិញ ។

សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនៅប្រទេសឡាវ

កិច្ចប្រជុំកំពូលអាស៊ានលើកទី ២៨-២៩ បានប្រារព្ធពិធីបើកជាផ្លូវការនៅថ្ងៃទី ៦ ខែកញ្ញា ដោយមានប្រមុខរដ្ឋប្រមុខរដ្ឋាភិបាលអាស៊ានទាំង ១០ ប្រទេស យាង និងអញ្ជើញចូលរួមនៅសាលសន្និសីទនៃទីក្រុងវៀងច័ន្ទ

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះ-រាជាណាចក្រកម្ពុជា បានដឹកនាំគណប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៨-២៩ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធចំនួនជាង ១០ និងជំនួបទ្វេភាគីចំនួន ២ នៅទីក្រុងវៀងច័ន្ទប្រទេសឡាវ ពីថ្ងៃទី ៦ ដល់ទី ៨ ខែកញ្ញា ឆ្នាំ ២០១៦ ។

នៅរសៀលថ្ងៃទី ៦ ខែកញ្ញា សម្តេចតេជោ **ហ៊ុនសែន** បានជួបពិភាក្សាការងារជាមួយឯកឧត្តម **ម៉ាន គីមូន** អគ្គលេខាធិការអង្គការសហប្រជា-ជាតិ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើទំនាក់ទំនងរវាងអង្គការសហប្រជាជាតិ និងព្រះរាជាណាចក្រកម្ពុជា,បញ្ហាតំបន់ និងអន្តរជាតិ ដែលមានការយកចិត្តទុកដាក់ដូចគ្នា ។

ឯកឧត្តម **ម៉ាន គីមូន** បានស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាបន្តការគាំទ្រដល់ការចំណាយលើប្រតិបត្តិការរបស់សាលាក្តីខ្មែរក្រហមជាបន្តទៀត និងបានថ្លែងនូវការកោតសរសើរចំពោះកងទ័ពមួកខៀវកម្ពុជាដែលបានចូលរួមក្នុងប្រតិបត្តិការមនុស្សធម៌ និងសកម្មភាពបោសសម្អាតគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ និងបានស្នើដល់សម្តេចតេជោគាំទ្រអនុសញ្ញានៃបម្រែបម្រួលអាកាសធាតុ ដើម្បីឲ្យអនុសញ្ញានោះចូលជាធរមាន ។ សម្តេចតេជោបានទទួលយកការស្នើឲ្យកម្ពុជាគាំទ្រដល់អនុសញ្ញានៃបម្រែបម្រួលអាកាសធាតុរបស់ អ.ស.ប ដោយបានគូសបញ្ជាក់ថា នៅពេលដែលរដ្ឋសភាកម្ពុជាបើកសម័យប្រជុំជាថ្មីបន្ទាប់ពីការឈប់សម្រាកនោះ រាជរដ្ឋាភិបាលកម្ពុជានឹងដាក់សំណើនោះទៅសម័យប្រជុំពេញអង្គសភាធ្វើការពិភាក្សាអនុម័តដើម្បីកម្ពុជាផ្តល់សច្ចាប័នលើអនុសញ្ញានោះ។ សម្តេចតេជោ**ហ៊ុនសែន**បានបញ្ជាក់ទៀតថាសម្តេចនឹងចាត់ឲ្យឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទៅធ្វើសេចក្តីថ្លែងការណ៍តំណាងសម្តេចក្នុងសម័យប្រជុំរបស់អ.ស.ប នាខែកញ្ញានេះ ក្នុងការប្រកាសគាំទ្រដល់អនុសញ្ញាដ៏មានសារសំខាន់នោះ ឲ្យបានរួចរាល់នៅមុនដំណាច់ឆ្នាំ ២០១៦ នេះ ។

កិច្ចប្រជុំកំពូលអាស៊ានលើកទី ២៨-២៩ បានប្រារព្ធពិធីបើកជាផ្លូវការនៅថ្ងៃទី ៦ ខែកញ្ញា ដោយមានប្រមុខរដ្ឋប្រមុខរដ្ឋាភិបាលអាស៊ានទាំង ១០ ប្រទេសបានយាង និងអញ្ជើញចូលរួមនៅសាលសន្និសីទនៃទីក្រុងវៀងច័ន្ទ ។

ថ្លែងក្នុងពិធីនេះ ឯកឧត្តម **ថុងលួង ស៊ីស៊ូលីត** នាយករដ្ឋមន្ត្រីឡាវ និងជាប្រធានកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៨-២៩ បានបញ្ជាក់ថា គោលដៅសំខាន់មួយ ក្នុងចំណោមគោលដៅសំខាន់បំផុតរបស់អាស៊ាន ចាប់តាំងពីការចាប់បដិសន្ធិនៅឆ្នាំ ១៩៦៧ គឺខិតខំរក្សា និងលើកកម្ពស់សន្តិភាពស្ថេរភាព និងកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍក្នុងតំបន់ និងសម្រាប់ពិភពលោកទាំងមូល ។ អាស៊ានបានពង្រឹងនូវសហប្រតិបត្តិ-ការផ្ទៃក្នុងពិសេសពង្រឹកទំនាក់ទំនងជាមួយដៃគូខាងក្រៅរបស់ខ្លួន ។ នៅក្នុងរយៈពេល ៥ ទសវត្សកន្លងមកនេះ អាស៊ានបានជម្នះរាល់បញ្ហាប្រឈមនានា និងបន្ត នូវវឌ្ឍនភាពរបស់ខ្លួន ។ អាស៊ានបានក្លាយជាតំបន់ប្រកបដោយសន្តិភាព និងស្ថិរភាពដែលផ្តល់នូវលក្ខខណ្ឌអំណោយផលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ប្រកបដោយចីរភាព ។ ជាលទ្ធផលអាស៊ានបានជាប់ចំណាត់ថ្នាក់សេដ្ឋកិច្ចធំបំផុតទី ៦ លើពិភពលោកនៅឆ្នាំ ២០១៥ ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្ររបស់អាស៊ានមួយទៀត គឺការបង្កើតនូវសហ-គមន៍អាស៊ានកាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ ។ ក្នុងរយៈពេលជាងកន្លះសតវត្ស៍កន្លងមកនេះ អាស៊ានបានបង្កើតឡើងនូវយន្តការកិច្ចសហប្រតិ-បត្តិការ ដែលនោះគឺមិនគ្រាន់តែបង្កើតឡើងនូវវេទិកាសម្រាប់កិច្ចសហ-ប្រតិបត្តិការជាមួយដៃគូសន្ធនា និងដៃគូដទៃទៀតប៉ុណ្ណោះទេប៉ុន្តែថែមទាំងបង្កើតនូវឱកាសសម្រាប់ដៃគូសន្ធនារបស់ខ្លួន ដើម្បីទាក់ទងជាមួយគ្នាទៅវិញទៅមកលើបញ្ហាតំបន់ និងសកលលោកពិសេសការស្វែងរកវិធីសាស្ត្រដោះស្រាយបញ្ហាប្រឈមរួមគ្នា ។

ក្នុងកិច្ចប្រជុំនោះ បណ្តាមេដឹកនាំអាស៊ានបានស្វាគមន៍ចំពោះវឌ្ឍន-ភាពជាវិជ្ជមាននៃការអនុវត្តផែនការលម្អិតឆ្នាំ ២០២៥ នៃសហគមន៍នយោបាយសន្តិសុខអាស៊ាន (APSC) សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងសហគមន៍សង្គមវប្បធម៌អាស៊ាន (ASCC) ឆ្ពោះទៅសម្រេចឲ្យបាននូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ ២០២៥ ។ នៅក្នុងសហគមន៍នយោបាយសន្តិសុខអាស៊ាន មេដឹកនាំអាស៊ានបានសង្កត់ធ្ងន់ពីសារសំខាន់នៃការការារតួនាទីស្នូលអាស៊ាន និងឯកភាពក្នុងដំណើរការនិម្មាបនកម្មតំបន់ និងក្នុងទំនាក់ទំនងរបស់យើងជាមួយដៃគូខាងក្រៅ ។ មេដឹកនាំអាស៊ានបានបញ្ជាក់សាជាថ្មីពីការតាំងចិត្តរបស់ខ្លួនក្នុងការការារតំបន់អាស៊ីអាគ្នេយ៍ជាតំបន់ដែលគ្មានអាវុធនុយក្លេអ៊ែរ និងគ្មានអាវុធប្រល័យលោកផ្សេងទៀត ដូចមានចែងក្នុងសន្ធិសញ្ញាតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ និងធម្មនុញ្ញអាស៊ាន ។ មេដឹកនាំអាស៊ានក៏បានអះអាងជាថ្មីនូវការតាំងចិត្តរបស់អាស៊ាន ក្នុងការឆ្លើយតបទៅនឹងការគំរាមកំហែងនៃបទឧក្រិដ្ឋកម្ម ឆ្លងដែន និងបញ្ហាប្រឈមឆ្លងដែនប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ។ មេដឹកនាំទាំងអស់ក៏បានស្វាគមន៍ចំពោះការចូលជាភាគីនៃសន្ធិ-សញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីអាគ្នេយ៍របស់ប្រទេសឈីលី អេហ្ស៊ីប អ៊ីរ៉ង់ និងម៉ារ៉ុក ។ មេដឹកនាំអាស៊ានបានធ្វើការកត់សម្គាល់ថា ផលិតផលក្នុងស្រុកសរុបរួមរបស់អាស៊ានគឺស្មើនឹង ២,៤៣ ទ្រីលានដុល្លារអាមេរិកនៅឆ្នាំ ២០១៥ ដែលជាការពង្រឹងជំហរអាស៊ានឲ្យទៅជាមជ្ឈមណ្ឌលនៃកំណើនសេដ្ឋកិច្ចពិភពលោក ។ មេដឹកនាំអាស៊ានក៏បានកត់សម្គាល់ដោយរីករាយថាឆ្នាំ ២០១៦ ជាឆ្នាំដំបូងនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន រាល់កិច្ចខិតខំប្រឹងប្រែងត្រូវផ្តោតទៅលើការអនុវត្តឲ្យបានពេញលេញនូវវិធានការដែលមិនទាន់បានអនុវត្តក្នុងផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ ក៏ដូចជាការចាប់ផ្តើមអនុវត្តវិធានការថ្មីនៅក្នុងផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០២៥ ។ មេដឹកនាំអា-ស៊ានបានអបអរសាទរចំពោះប្រទេសឡាវដែលបានសម្រេចដោយជោគ-ជ័យនូវអាទិភាពរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងវេនជាប្រធានអា-ស៊ានឆ្នាំ ២០១៦ នេះ ។ ចំពោះសហគមន៍សង្គមវប្បធម៌អាស៊ាន មេដឹកនាំ

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសជួបពិភាក្សាការងារជាមួយ ឯកឧត្តម **បាន គីមូន** អគ្គលេខាធិការអង្គការសហប្រជាជាតិ*

អាស៊ានបានបញ្ជាក់សាជាថ្មី នូវការប្ដេជ្ញាចិត្តយ៉ាងខ្លាំងក្លារបស់អាស៊ាន ដើម្បីធ្វើការឆ្ពោះទៅរកការអនុវត្តឲ្យបានពេញលេញ និងមានប្រសិទ្ធភាពផែនការលម្អិតនៃសហគមន៍សង្គមវប្ផធម៌អាស៊ានឆ្នាំ២០២៥។ការអនុម័តសេចក្ដីប្រកាសរួមអាស៊ានស្ដីពីការប្រែប្រួលអាកាសធាតុឆ្នាំ ២០១៦ ពិសេសលើកទឹកចិត្តដល់បណ្ដាប្រទេសជាសមាជិកអាស៊ានឲ្យផ្ដល់សច្ចាប័ន និងអនុវត្តកិច្ចព្រមព្រៀងបរិស្ថានពហុភាគីនៅក្នុងកម្រិតតំបន់ និងអន្តរជាតិ ។ មេដឹកនាំអាស៊ានបានអនុម័តសេចក្ដីប្រកាសអាស៊ាន ស្ដីពីការពង្រឹងការអប់រំសម្រាប់កុមារ និងយុវជននៅក្រៅសាលា និងបានស្វាគមន៍ការអនុម័តផែនការការងារលើវិស័យអប់រំក្នុងឆ្នាំ២០១៦-២០២០ ។មេដឹកនាំអាស៊ានបានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ទៅលើគំនិតផ្ដួចផ្ដើមសមាហរណកម្មអាស៊ាន ការតភ្ជាប់អាស៊ាន ការពិភាក្សាស្ដីពីទំនាក់ទំនងជាមួយដៃគូខាងក្រៅរបស់អាស៊ាន បញ្ហាតំបន់ និងអន្តរជាតិ ពិសេសការអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៥០ នៃការបង្កើតអាស៊ាននៅឆ្នាំ ២០១៧ ដើម្បីជាការរំលឹកដល់កិច្ចសហប្រតិបត្តិការ និងការកសាងសហគមន៍អាស៊ានប្រាំទសវត្សរ៍កន្លងទៅ និងគាំទ្រដល់គំនិតផ្ដួចផ្ដើមរបស់ប្រទេសហ្វីលីពីនដែលជាប្រធានអាស៊ានឆ្នាំ ២០១៧ ។

បន្ទាប់ពីបញ្ចប់កិច្ចប្រជុំកំពូលអាស៊ានលើកទី ២៨-២៩ រួចមក មេដឹកនាំនៃបណ្ដាប្រទេសអាស៊ានទាំង ១០ បានចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍អាស៊ានស្ដីពី "អាស៊ានមួយ ការឆ្លើយតបមួយ ៖ ការឆ្លើយតបរបស់អាស៊ានមួយទៅនឹងគ្រោះមហន្តរាយជាផ្នែកមួយនៅក្នុងតំបន់ និងក្រៅតំបន់ " ។ តាមរយៈនេះមេដឹកនាំអាស៊ានទាំងអស់បានខិតខំរួមគ្នា ក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់អាស៊ាន ដើម្បីឆ្លើយតបឲ្យបានទាន់ពេលវេលាក្នុងការទប់ស្កាត់ និងសង្គ្រោះឲ្យបានយ៉ាងឆាប់រហ័សគ្រោះមហន្តរាយនៅក្នុងតំបន់ និងក្រៅតំបន់ ដែលមេដឹកនាំនៃប្រទេសអាស៊ាន និងបណ្ដាមេដឹកនាំនានាលើពិភពលោកកំពុងយកចិត្តទុកដាក់ដូចគ្នា ។

នៅថ្ងៃទី ៧ ខែកញ្ញា កិច្ចប្រជុំកំពូលអាស៊ាន-ចិនលើកទី១៩បានចាប់ផ្ដើមជាផ្លូវការ ដោយមានឯកឧត្តម **លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិនអញ្ជើញចូលរួម ។ មេដឹកនាំអាស៊ានបានធ្វើការកត់សម្គាល់ថា ចិននៅតែបន្ដជាប្រទេសដៃគូពាណិជ្ជកម្មធំបំផុតរបស់អាស៊ានជាមួយនឹងទំហំពាណិជ្ជកម្មទ្វេភាគីសរុប ៣៤៦,៤ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ ២០១៥ និងលំហូរវិនិយោគផ្ទាល់ពីចិនមកកាន់អាស៊ានមាន ៨,២ ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៥ ។ មេដឹកនាំទាំងអស់ក៏បានស្វាគមន៍ចំពោះការចូលជាធរមាន នៃពិធីសារនៃការធ្វើវិសោធនកម្មក្របខណ្ឌកិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងជាក់លាក់រវាងអាស៊ាន និងចិននៅថ្ងៃទី ១ ខែកក្កដាឆ្នាំ ២០១៦ ។ មេដឹកនាំទាំងអស់ក៏បានរំពឹងទុកការសម្រេចឲ្យបាននូវគោលដៅពាណិជ្ជកម្មសរុបចំនួន ១ ទ្រីលានដុល្លារអាមេរិក និងការវិនិយោគចំនួន ១៥០ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ ២០២០ ។ កត់សម្គាល់ពីការរីកចម្រើននៃការពិគ្រោះយោបល់ស្ដីពីក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង (COC) មេដឹកនាំទាំងអស់បានលើកទឹកចិត្តឲ្យបន្ដរក្សាជំហាននៃកិច្ចប្រជុំនេះដើម្បីឆ្ពោះទៅរកការបញ្ចប់ (COC) ឲ្យបានឆាប់ ដោយផ្អែកលើកុងសង់ស៊ីស ។ ជាមួយគ្នានេះមេដឹកនាំអាស៊ាន-ចិន បានស្វាគមន៍ក្នុងការកំណត់ឆ្នាំ ២០១៧ ជាឆ្នាំនៃកិច្ចសហប្រតិបត្តិការទេសចរណ៍អាស៊ាន-ចិន ដោយរំពឹងទុកនូវការបង្កើនកិច្ចសហប្រតិបត្តិការ និងសកម្មភាពនានា ក្នុងគោលបំណងជំរុញការចូលទស្សនាទៅវិញទៅមករវាងអ្នកទេសចរណ៍របស់អាស៊ាន និងចិន ។

កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី ១៩ មេដឹកនាំបណ្ដាប្រទេសអាស៊ាន និងឯកឧត្តម **ហ្ស៊ិន ហ្ស៊ូអាបេ** នាយករដ្ឋមន្ត្រីជប៉ុនបានបញ្ជាក់សាជាថ្មីនូវការគាំទ្រចំពោះគំនិតផ្ដួចផ្ដើម និងសកម្មភាពនានាដើម្បីកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយនូវនិន្នាការថ្មី និងបញ្ហាប្រឈមដែលកើតមានឡើងនៅក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន រួមទាំងភេរវកម្ម ហិង្សាជ្រុលនិយម និងបទល្មើសតាមអ៊ីនធើណេត ។ មេដឹកនាំអាស៊ានក៏បានកត់សំគាល់ដែរថា ជប៉ុនបានក្លាយជាដៃគូពាណិជ្ជកម្មធំជាងគេលំដាប់ទី ២ របស់អាស៊ាន និងជាប្រភពលំហូរវិនិយោគទុនដោយផ្ទាល់ពីបរទេសធំជាងគេលំដាប់ទី ២ មកអាស៊ាន ។ ពាណិជ្ជកម្មរវាងអាស៊ាន និងជប៉ុនបានឈានដល់ ២៣៩,៤ ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៥ និងវិនិយោគផ្ទាល់ពីជប៉ុនមកអាស៊ានមានចំនួន ១៧,៤ ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៥ ។

មេដឹកនាំនៃប្រទេសអាស៊ានទាំង ១០ បានចូលរួមកិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េលើកទី ១៨ ជាមួយលោកជំទាវ **ប៉ាក់ គ្យឿនហេ** ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ ។ មេដឹកនាំអាស៊ានបានកត់សម្គាល់ថាសាធារណរដ្ឋកូរ៉េនៅតែជាប្រទេសដៃគូពាណិជ្ជកម្មដ៏ធំបំផុតទី ៥ របស់អាស៊ានចាប់តាំងពីឆ្នាំ ២០១០ ជាមួយទំហំពាណិជ្ជកម្មសរុប ១២២,៩ ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៥ ។ ការវិនិយោគផ្ទាល់ពីបរទេសរបស់សាធារណរដ្ឋកូរ៉េមកអាស៊ានបានកើនឡើងជាលំដាប់គឺពីចំនួន ៤,៣ ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៣ ដល់ ៥,៧ ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៥ ធ្វើឲ្យសាធារណរដ្ឋកូរ៉េក្លាយជាប្រទេសលំហូរ FDI ធំជាងគេទី ៥ របស់អាស៊ាន ។ មេដឹកនាំអាស៊ានបានស្វាគមន៍ចំពោះការចុះហត្ថលេខាលើពិធីសារទី ៣ នៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-សាធារណរដ្ឋកូរ៉េកាលពីខែសីហាឆ្នាំ ២០១៥ ដោយរំពឹងទុកថាការអនុវត្តកិច្ចព្រមព្រៀងនោះឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព នឹងជំរុញទំនាក់ទំនងពាណិជ្ជកម្មកាន់តែប្រសើរ ដើម្បីសម្រេចឲ្យបាននូវទំហំពាណិជ្ជកម្ម ២០០ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ ២០២០ ។

កិច្ចប្រជុំកំពូលអាស៊ាន-អង្គការសហប្រជាជាតិលើកទី ៨ បានប្រព្រឹត្តទៅដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **បាន គីមូន** អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ មេដឹកនាំអាស៊ាន និងអង្គការសហប្រជាជាតិបានស្វាគមន៍ចំពោះការអនុម័តផែនការសកម្មភាពរយៈពេល ៥ ឆ្នាំ (២០១៦-២០២០) ដើម្បីអនុវត្តសេចក្ដីថ្លែងការណ៍រួមស្ដីពីភាពជាដៃគូទូលំទូលាយរវាងអាស៊ាន និងអង្គការសហប្រជាជាតិ ។

នៅរសៀលថ្ងៃទី ៧ ខែកញ្ញាដដែលមេដឹកនាំប្រទេសអាស៊ានទាំង ១០ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលីលើកទី២ជាមួយ ឯកឧត្តម **ម៉ាលខូមធើនបឺន** (Malcolm Turbull) នាយករដ្ឋមន្ត្រីអូស្ត្រាលី ។ មេដឹកនាំទាំងអស់បានស្វាគមន៍ចំពោះការបន្ដកម្មវិធីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាស៊ាន-អូស្ត្រាលីដំណាក់កាលទី ២ ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៩ ដែលគាំទ្រដល់ការពង្រឹងស្ថាប័នរបស់លេខាធិការអាស៊ានព្រមទាំងយន្ដការ និងសមត្ថភាពថ្នាក់តំបន់ ដើម្បីអនុវត្តផែនការលម្អិតនៃសហ-

គមន៍សេដ្ឋកិច្ចអាស៊ាន ។ មេដឹកនាំទាំងអស់បានបញ្ជាក់ពីសារៈសំខាន់នៃការរក្សានូវទំនាក់ទំនងដៃគូសន្ធនាក្នុងកម្រិតខ្ពស់បំផុតដោយរំពឹងទុកថាការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលីលើកទី ៣ ,កិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលីសម្រាប់ ២ ឆ្នាំម្តង លើកទី ២ ក្នុងឆ្នាំ ២០១៨ ។

កិច្ចប្រជុំកំពូលអាស៊ានបូកបីលើកទី ១៩ ក៏បានប្រារព្ធធ្វើនៅរសៀលថ្ងៃទី ៧ ខែកញ្ញាដែលក្នុងពេលនោះមេដឹកនាំទាំងអស់បានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការបន្តពង្រឹងបន្ថែមទៀត និងធ្វើឲ្យកាន់តែស៊ីជម្រៅនូវដំណើរការអាស៊ានបូកបីជាកម្លាំងនាំមុខ សម្រាប់ការលើកកម្ពស់សន្តិភាពសន្តិសុខ និងវិបុលភាពនៅក្នុងតំបន់អាស៊ីបូព៌ាជាមួយនឹងគោលដៅរយៈពេលវែងនៃការកសាងសហគមន៍អាស៊ីបូព៌ា ។ មេដឹកនាំទាំងអស់ក៏បានកត់សម្គាល់ដែរថា ផែនទីចង្អុលផ្លូវរយៈពេលមធ្យមថ្មីនៃគំនិតផ្តួចផ្តើមផ្សារមូលប័ត្រអាស៊ីនឹងបន្តសម្រាប់រយៈពេល ៣ ឆ្នាំ បន្ទាប់ទៀតដែលរំពឹងថានឹងអាចបន្តជំរុញការអភិវឌ្ឍទីផ្សារមូលប័ត្ររូបិយប័ណ្ណក្នុងស្រុកដើម្បីពង្រឹងស្ថេរភាពហិរញ្ញវត្ថុ និងឆ្លើយតបតម្រូវការវិនិយោគរយៈពេលយូរអង្វែងនៅក្នុងតំបន់ ។

នៅថ្ងៃទី ៧ ខែកញ្ញាមេដឹកនាំនៃប្រទេសមេគង្គទាំងប្រាំរួមមានប្រទេសកម្ពុជាឡាវមីយ៉ាន់ម៉ាថៃ និងវៀតណាមបានចូលរួមក្នុងកិច្ចប្រជុំកំពូលមេគង្គ-ជប៉ុនលើកទី ៨ ជាមួយឯកឧត្តម **ស៊ិន ហ្សូអាបេ** នាយករដ្ឋមន្ត្រីជប៉ុន ។ ថ្នាក់ដឹកនាំនៃប្រទេសមេគង្គបានកោតសរសើរប្រទេសជប៉ុនក្នុងការខិតខំប្រឹងប្រែងលើកកម្ពស់គុណភាពហេដ្ឋារចនាសម្ព័ន្ធ រួមមានការអនុវត្តគម្រោងអាទិភាពមួយចំនួនដូចជាការបើកការដ្ឋានពង្រីកចំណតអាកាសយានដ្ឋានវៀងច័ន្ទប្រទេសឡាវ,គម្រោងអយស្ម័យានទីក្រុងហូជីមិញទី ១ នៅប្រទេសវៀតណាម,គម្រោងធ្វើឲ្យប្រសើរឡើងកំណាត់ផ្លូវជាតិលេខ ៥ នៅប្រទេសកម្ពុជា,ការសាងសង់ស្ពានទន្លេបាគូនៅប្រទេសមីយ៉ាន់ម៉ា ការបើកគំនូសពណ៌ស្វាយក៏ដូចជាការផ្តល់ប្រាក់កម្ចីរហូតដល់ ១៧០ ៣ន់លានយ៉ែនសម្រាប់គំនូសពណ៌ក្រហមនៅប្រទេសថៃ ។ មេដឹកនាំនៃប្រទេសមេគង្គបានកោតសរសើរចំពោះវត្តមានរបស់ក្រុមហ៊ុនជប៉ុនដែលបានវិនិយោគនៅបណ្តាប្រទេសមេគង្គ ពោលគឺក្នុងរយៈពេល ៣ ឆ្នាំកន្លងមកនេះមានរហូតដល់ជិត ១០០០ ក្រុមហ៊ុន ។ មេដឹកនាំទាំងអស់បានយល់ថាការអភិវឌ្ឍធនធានមនុស្សក្នុងតំបន់មេគង្គ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។ ពិសេសទៅទៀតនោះ មេដឹកនាំទាំងអស់បានស្វាគមន៍ចំពោះការធ្វើឲ្យប្រសើរឡើងនៃការផ្លាស់ប្តូរវប្បធម៌ប្រជាជន និងប្រជាជនរវាងជប៉ុន និងប្រទេសមេគង្គពិសេសស្វាគមន៍ចំពោះការហោះហើរត្រង់ជាលើកដំបូងរវាងទីក្រុងតូក្យូ និងរាជធានីភ្នំពេញដែលបានសម្ពោធកាលពីថ្ងៃទី ១ ខែកញ្ញាឆ្នាំ ២០១៦ ដោយរំពឹងថាការហោះហើរនោះនឹងជួយជំរុញការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន ។

នៅទីក្រុងវៀងច័ន្ទ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបចរចារទ្វេភាគីជាមួយឯកឧត្តម **លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ។ ក្នុងជំនួបពិភាក្សាគ្នានោះឯកឧត្តម **លី ខឺឈាង** បានបញ្ជាក់ទៅកាន់សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា ពីការបន្តបញ្ជាទិញកសិផលកសិកម្មរបស់ប្រទេសកម្ពុជាឲ្យកាន់តែច្រើនឡើងថែមទៀតពោលគឺការបញ្ជាទិញអង្ករពី ១០ ម៉ឺនតោន ក្នុងឆ្នាំ ២០១៦ ទៅ ២០ ម៉ឺនតោន ក្នុងឆ្នាំ ២០១៧ ផ្តល់កម្ចីដល់ការស្ថាវកំណាត់ផ្លូវជាតិលេខ ៥១ និងការស្ថាវប្រព័ន្ធធារាសាស្ត្រទន្លេវ៉ែកូក្នុងខេត្តស្វាយរៀងឡើងវិញ រួមទាំងគម្រោងផ្សេងៗទៀតដែលស្នើឡើងដោយភាគីកម្ពុជាកាលពីពេលកន្លងទៅ ។ ពិសេសការបង្កើនអាហារូបករណ៍ដល់និស្សិតកម្ពុជា បានទៅបន្តការសិក្សាក្នុងប្រទេសចិនឲ្យកាន់តែមានចំនួនច្រើនឡើង ។ ឯកឧត្តមនាយករដ្ឋមន្ត្រីចិនក៏បានប្រកាសផ្តល់ថវិកាក្នុងការជួយជួសជុលប្រាសាទអង្គរវត្ត រួមទាំងការផ្តល់លទ្ធភាពក្នុងការសិក្សាដើម្បីឈានទៅជួយជួសជុលប្រាសាទព្រះវិហារ ក្នុងគោលបំណងដើម្បីជំរុញរមណីយដ្ឋានទេសចរណ៍វប្បធម៌ និងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជននៃប្រទេសទាំងពីរផងដែរ ។ សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះប្រទេសចិនដែលតែងតែជួយដល់ប្រទេសកម្ពុជា ។ សម្តេចតេជោបានឯកភាពទៅនឹងការលើកឡើងរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីចិន ក្នុងការជំរុញឲ្យមានការផ្លាស់ប្តូរដំណើរទស្សនកិច្ចពីគ្រប់កម្រិតទាំងអស់សម្រាប់ប្រទេសទាំងពីរដើម្បីឲ្យប្រទេសទាំងពីរកាន់តែមានភាពជិតស្និតទ្វេឡើងថែមទៀត ។

នៅព្រឹកថ្ងៃទី ៨ ខែកញ្ញា កិច្ចប្រជុំកំពូលអាស៊ាន-សហរដ្ឋអាមេរិកលើកទី ៤ បានប្រព្រឹត្តទៅដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **បារ៉ាក់ អូ-បាម៉ា** ប្រធានាធិបតីសហរដ្ឋអាមេរិក ។ មេដឹកនាំនៃប្រទេសអាស៊ាន និងអាមេរិកបានកត់សម្គាល់រួមគ្នាថា អាមេរិកគឺជាប្រទេសដៃគូពាណិជ្ជកម្មធំបំផុតទី ៤ របស់អាស៊ានជាមួយនឹងទំហំពាណិជ្ជកម្មសរុបចំនួន ២១២,៨ ប៊ីលានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០១៥ ដែលធ្វើឲ្យអាមេរិកក្លាយជាប្រភពវិនិយោគធំបំផុតទី ៣ របស់អាស៊ាន ។ មេដឹកនាំទាំងអស់បានសម្តែងនូវការកោតសរសើរចំពោះការបង្កើតឡើងនូវគំនិតផ្តួចផ្តើមស្តីពីការតភ្ជាប់អាមេរិក-អាស៊ាន ដើម្បីពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចអាស៊ានអាមេរិកបន្ថែមទៀត ។ មេដឹកនាំអាស៊ានក៏បានរំពឹងទុកពីការគាំទ្របន្ថែមទៀតរបស់សហរដ្ឋអាមេរិក សម្រាប់ការតភ្ជាប់អាស៊ានឆ្នាំ២០២៥និងស្វាគមន៍ការប្រកាសកម្មវិធីសិក្សាសហគ្រាសធុនតូច និងមធ្យមអាស៊ាន ។

មេដឹកនាំនៃប្រទេសអាស៊ានទាំង ១០ បានចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកទី ១៤ ជាមួយឯកឧត្តម **ណារេន ម្រាម៉ូឌី** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌា ។ មេដឹកនាំប្រទេសអាស៊ានបានស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមរបស់ឥណ្ឌាស្តីពីគោលនយោបាយឆ្ពោះទៅទិសខាងកើត និងការផលិតនៅប្រទេសឥណ្ឌា និងអរគុណការគាំទ្ររបស់ឥណ្ឌាសម្រាប់សហគមន៍អាស៊ាន និងបានរំពឹងថា អាស៊ាន-ឥណ្ឌានឹងប្រារព្ធខួបអនុស្សាវរីយ៍ ២៥ ឆ្នាំនៃទំនាក់ទំនងនៃគូសន្ធនាអាស៊ាន-ឥណ្ឌាក្នុងឆ្នាំ ២០១៧ ។ មេដឹកនាំអាស៊ាន-ឥណ្ឌាបានកត់សម្គាល់ពីលទ្ធផលនៃការធ្វើពាណិជ្ជកម្ម និងការវិនិយោគមិនទាន់ឈានដល់សក្តានុពលពេញលេញនៅឡើយ ។ ពាណិជ្ជកម្មសរុបក្នុងឆ្នាំ ២០១៥ មានទឹកប្រាក់ចំនួន ៥៨ ប៊ីលានដុល្លារអាមេរិកឬប្រមាណ ២,៦ ភាគរយនៃពាណិជ្ជកម្មសរុបរបស់អាស៊ាន ។ មេដឹកនាំអាស៊ានឥណ្ឌាបានកត់សម្គាល់ពីការអនុវត្តផែនការសកម្មភាពបន្តស្តីពីកិច្ចសហប្រតិបត្តិការអាស៊ាន-ឥណ្ឌាលើវិស័យម្ហូបអាហារកសិកម្ម និងព្រៃឈើឆ្នាំ ២០១៦-២០២០ ដើម្បីជំរុញបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការលើវិស័យម្ហូបអាហារកសិកម្ម និងព្រៃឈើ ។

នៅថ្ងៃទី ៨ ខែកញ្ញា មេដឹកនាំនៃប្រទេសអាស៊ានទាំង ១០ ក៏បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី ១១ ។ មេដឹកនាំទាំងអស់បានអះអាងសាជាថ្មីនូវការគាំទ្រចំពោះដំណើរការ នៃការកសាងសហគមន៍អាស៊ាននិងបញ្ជាក់ឡើងវិញនូវសារៈសំខាន់នៃតួនាទីស្នូលរបស់អាស៊ានក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងក្នុងដំណើរវិវឌ្ឍនៃនិម្មាបនកម្មតំបន់ ។ មេដឹកនាំអាស៊ីបូព៌ាទាំងអស់បានអះអាងជាថ្មីថា វេទិកាអាស៊ីបូព៌ានឹងនៅបន្តជាវេទិកាបើកចំហរសម្រាប់ការចូលរួមទាំងអស់គ្នាប្រកបដោយតម្លាភាពនឹងសម្លឹងឆ្ពោះទៅខាងក្រៅដែលនឹងពង្រឹងបន្ថែមដល់បទដ្ឋានជាសកល និងគោលការណ៍នានាដែលបានទទួលស្គាល់ជាសកលថា អាស៊ានជាកម្លាំងនាំមុខ ព្រមទាំងធ្វើការក្នុងភាពជាដៃគូជាមួយបណ្តាប្រទេសចូលរួមវេទិកាអាស៊ីបូព៌ា ។

គួរបញ្ជាក់ថា ក្នុងឱកាសអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៨-២៩ ខែកញ្ញា និងកិច្ចប្រជុំកំពូលពាក់ព័ន្ធជាច្រើននៅរដ្ឋធានីវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញធ្វើបទអន្តរាគមន៍ចំនួន ១៣ ។ កិច្ចប្រជុំកំពូលអាស៊ានលើកទី ៣០ នឹងធ្វើនៅប្រទេសហ្វីលីពីននាឆ្នាំ ២០១៧ ខាងមុខនេះ ។

កម្ពុជាខិតខំពង្រីកទីផ្សារ និងធ្វើសមាហរណកម្ម២ឲ្យកាន់តែស៊ីជម្រៅក្នុងតំបន់អាស៊ាន

❋ សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមការតាំងពិព័រណ៍ អាស៊ាន-ចិន លើកទី ១៣ នៅខេត្តក្វាងស៊ី



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជ-ណាចក្រកម្ពុជា ជួបពិភាក្សាការងារជាមួយឯកឧត្តម **ឆឹង ឈីវហ៊ី** លេខាគណៈកម្មាធិការបក្សកុម្មុយនីស្តចិនតំបន់ស្វយ័តខេត្តក្វាងស៊ី*

តបតាមការអញ្ជើញរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជ-ណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ ទៅចូលរួមការតាំងពិព័រណ៍អាស៊ាន-ចិនលើកទី ១៣ ក្រោមប្រធានបទ "ការកសាងផ្លូវសូត្រសមុទ្រសតវត្សរ៍ទី ២១ " និងវេទិកាវិនិយោគ និងពាណិជ្ជកម្មកម្ពុជា-ចិន លើកទី ១ ចាប់ពីថ្ងៃទី ១០-១២ ខែកញ្ញា ឆ្នាំ ២០១៦ នៅទីក្រុងណាននីញ ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន ។ នេះជាលើកទី ៩ ហើយដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានអញ្ជើញចូលរួមការតាំងពិព័រណ៍អាស៊ាន-ចិន ដែលបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះការជំរុញពាណិជ្ជកម្ម និងការកៀរគរវិនិយោគពីប្រទេសចិនមកកាន់កម្ពុជា។

នៅទីក្រុងណាននីងខេត្តក្វាងស៊ីនាព្រឹកថ្ងៃទី ១០ ខែ កញ្ញា សម្តេចតេ-ជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម **ឆឹង ឈីវហ៊ី** លេខាគណៈកម្មាធិការ-បក្សកុម្មុយនីស្តចិនតំបន់ស្វយ័តខេត្តក្វាងស៊ី ។

ឯកឧត្តមលេខាគណៈកម្មាធិការបក្សតំបន់ស្វយ័តខេត្តក្វាងស៊ី និងសម្តេចតេជោនាយករដ្ឋមន្ត្រី បានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ទៅលើបញ្ហាទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីនៃប្រទេសទាំងពីរ កម្ពុជា-ចិន ពិសេសទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងខេត្តក្វាងស៊ី ។ ឯកឧត្តមលេខាបក្សខេត្ត បានចាត់ទុកថាសម្តេចតេជោ **ហ៊ុនសែន** គឺជាមេដឹកនាំអាស៊ានដ៏សកម្មម្នាក់ដែលបានអញ្ជើញមកចូលរួមពិព័រណ៍ចិន-អាស៊ានចំនួន ៩ លើក ជាប់ៗគ្នា ។ សម្តេចតេជោគឺជាមិត្តដ៏ល្អមិត្តជាទីទុកចិត្តរបស់ប្រទេស និងប្រជាជនចិន ពិសេសប្រជាជនខេត្តក្វាងស៊ី ។ សម្តេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍ពីប្រវត្តិនៃការប្រារព្ធពិព័រណ៍ចិន-អាស៊ាន គឺកើតចេញពីគំនិតផ្តួចផ្តើមរបស់ឯកឧត្តម **ភេន ជា ប៉ាវ** អតីតនាយករដ្ឋមន្ត្រីចិន និងក្នុងពេលដែលកម្ពុជាជាប្រទេសសម្របសម្រួលអាស៊ាន-ចិន ហើយព្រឹត្តិការណ៍នាពេលនេះ គឺស្របពេលនៃការប្រារព្ធខួបអនុស្សាវរីយ៍ ២៥ ឆ្នាំ នៃទំនាក់ទំនងក្នុងភាពជាដៃគូសន្ធនារវាងចិន-អាស៊ាន ។ សម្តេចតេជោបានស្នើដល់ថ្នាក់ដឹកនាំខេត្តក្វាងស៊ីបន្តជំរុញអ្នកវិនិយោគពីខេត្តក្វាងស៊ីទៅបណ្តាក់ទុនវិនិយោគក្នុងប្រទេសកម្ពុជាឲ្យកាន់តែមានចំនួនច្រើនឡើងថែមទៀត ពិសេសខិតខំធ្វើយ៉ាងណាជំរុញកំណើននៃទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងខេត្តក្វាងស៊ីឲ្យកាន់តែមានទំហំធំឡើង ។ ព្រះរាជាណាចក្រកម្ពុជា និងខេត្តក្វាងស៊ី កម្ពុជាបានបង្កើតស្ថានអគ្គកុងស៊ុលនៅទីក្រុងណាននីង ខេត្តក្វាងស៊ីនៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ។

នៅល្ងាចថ្ងៃទី ១០ ខែកញ្ញា សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជាបានអនុញ្ញាតឲ្យឯកឧត្តម**ចាង ភៅលី** (ZhangGaoli) ឧបនាយក-រដ្ឋមន្ត្រីចិនចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ។ ក្នុងសវនាការនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីចិនបានចាត់ទុកវត្តមានរបស់សម្តេចតេ-ជោថាបានបង្ហាញពីគោលជំហររបស់សម្តេចចំពោះប្រទេសចិន និងជាការចូលរួមពង្រឹងនូវទំនាក់ទំនងរវាងចិន និងកម្ពុជា និងក៏រវាងចិននិងអាស៊ានទាំងមូលផងដែរ ។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានស្នើដល់ភាគីចិនបន្តជំរុញការនាំចូលនូវផលិតផលកម្ពុជាទៅកាន់ទីផ្សារចិនដោយមិនកំណត់កូតាចំនួន និងដោយមិនជាប់ពន្ធគយ តាមរយៈការជំរុញឲ្យរដ្ឋមន្ត្រីពាណិជ្ជកម្មនៃប្រទេសទាំងពីរកម្ពុជាចិន ធ្វើការពិភាក្សាជាមួយគ្នា ។ សម្តេចតេជោ និងឯកឧត្តមឧបនាយករដ្ឋមន្ត្រីចិន បានពិភាក្សាគ្នាពីគម្រោងអាទិភាពនា-នា ដែលរដ្ឋាភិបាលចិនបានផ្តល់ជូនភាគីកម្ពុជា រួមទាំងជំនួយឥតសំណងមានទឹកប្រាក់ ៣៦០០ លានយ៉ន ផងដែរ ។ ឯកឧត្តម **ចាង ភៅលី** បានកោតសរសើរ និងចាត់ទុកសម្តេចតេជោ គឺជាសាក្សីពិតក្នុងទំនាក់ទំនងអា-ស៊ាន-ចិន ដោយសម្តេចតែងតែខិតខំជំរុញកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន បន្តមានការរីកចម្រើនទៅមុខក្នុងភាពជាដៃគូយុទ្ធសាស្ត្រ ។

នាព្រឹកថ្ងៃទី ១១ ខែកញ្ញា សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជាបានអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីកាត់ខ្សែបូជានិមិត្តរូបនៃការសម្ពោធស្តង់ពិព័រណ៍ និងពន្លាជាតិកម្ពុជា ដើម្បីបើកឲ្យភ្ញៀវមកពីគ្រប់ទិសទីទាំងជនជាតិចិន និងបណ្តាប្រទេសជាច្រើនទៀត ចូលទស្សនា ។ ក្នុងការចូលរួមព្រឹត្តិការណ៍ពិព័រណ៍ចិន-អាស៊ានលើកទី ១៣ នៅទីក្រុងណាននីង ក្នុងឆ្នាំ ២០១៦ នេះ កម្ពុជាមានក្រុមហ៊ុនចំនួន ៧៦ ដែលសុទ្ធសឹងជាក្រុមហ៊ុនក្នុងស្រុកចូលរួម ហើយមានស្តង់សរុបចំនួន ១១៤ បានតាំងបង្ហាញលក់ទំនិញដែលជាផលិតផលក្នុងស្រុក ។

សម្តេចតេជោ **ហ៊ុន សែន** បានជួបសំណេះសំណាលជាមួយបណ្តាពាណិជ្ជករកម្ពុជា ព្រមទាំងបានថតរូបជាអនុស្សាវរីយ៍ប្រកបដោយភាពស្និទ្ធស្នាល និងបានសម្តែងការកោតសរសើរដល់ក្រុមហ៊ុនជាតិ និងអន្តរ-ជាតិដែលកំពុងវិនិយោគលើវិស័យកសិកម្ម និងដំណាំកសិផលនានាដែលបានយកទំនិញកម្ពុជាមកចូលរួមបង្ហាញ និងដាក់លក់នៅក្នុងប្រទេសចិន នាឱកាសនេះផងដែរ ។ សម្តេចតេជោបានវាយតម្លៃខ្ពស់ចំពោះផលិតផលរបស់កម្ពុជាដែលបានយកមកតាំងបង្ហាញលក់ ក៏ដូចជាប្រកួតប្រជែងជា



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាការងារជាមួយឯកឧត្តម **ចាង កៅលី** (Zhang Gaoli) ឧបនាយករដ្ឋមន្ត្រីចិន*

មួយនឹងបណ្ដាប្រទេសអាស៊ានដែលនេះបង្ហាញថាផលិតផលរបស់កម្ពុជាកំពុងមានសក្តានុពលដែលបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ នាពេលបច្ចុប្បន្ន ។

ថ្លែងសុន្ទរកថា នៅក្នុងពិធីបើកការតាំងពិព័រណ៍អាស៊ាន-ចិនលើកទី ១៣ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជាបានថ្លែងថា កម្ពុជានឹងផ្ដល់នូវសារៈសំខាន់ពិសេសចំពោះកិច្ចសហប្រតិបត្តិការនិងសមាហរណកម្មជាមួយបណ្ដាប្រទេសទាំងក្នុង និងក្រៅតំបន់ពិសេសអាស៊ាន និងបណ្ដាប្រទេសដែលមានសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត ដូចជា ចិន ឥណ្ឌា ជប៉ុន និងកូរ៉េ ។ ជាក់ស្ដែង កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងចិនមានសន្ទុះរីកចម្រើនកាន់តែខ្លាំងក្លាឡើងជាលំដាប់ ពិសេសក្នុងវិស័យពាណិជ្ជកម្មកសិកម្ម និងទេសចរណ៍ព្រមទាំងការវិនិយោគរួមទាំងការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ថាមពល បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។ កម្ពុជាបាន និងកំពុងខិតខំបន្ដធ្វើពិពិធកម្មសេដ្ឋកិច្ចបន្ថែមទៀត សំដៅពង្រីកទីផ្សារ និងធ្វើសមាហរណកម្មខ្លួនឲ្យកាន់តែស៊ីជម្រៅ ទាំងក្នុងតំបន់អាស៊ាន ស្របតាមទស្សនទាននិយមតំបន់ តំបន់និយមបើកទូលាយ ។ សម្តេចតេជោបានមានប្រសាសន៍ទៀតថា ដើម្បីសម្រេចនូវគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងកំពុងជំរុញអនុវត្តន៍យ៉ាងសកម្មនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម សំដៅពង្រឹងពិពិធកម្មមូលដ្ឋានឧស្សាហកម្ម តាមរយៈការលើកទឹកចិត្តដល់ការវិនិយោគលើឧស្សាហកម្ម ដែលមានលក្ខណៈប្រកួតប្រជែងកាន់តែខ្លាំង និងមានតម្លៃបន្ថែមកាន់តែខ្ពស់ ដូចជាឧស្សាហកម្មផ្ដុំតម្លើងអេឡិចត្រូនិច និងគ្រឿងបន្លាស់ ។ ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មធនធានស្រាលផ្សេងៗទៀត ព្រមទាំងការជំរុញការតភ្ជាប់ទំនាក់ទំនង និងការបង្កើតចង្កោមឧស្សាហកម្មរវាងសហគ្រាសធុនតូច និងមធ្យមក្នុងស្រុកជាមួយសហគ្រាសបរទេស ដើម្បីជំរុញឧស្សាហកម្មកម្ពុជាឲ្យក្លាយទៅជាចំណែកមួយនៃខ្សែសង្វាក់ផលិតកម្មតំបន់ និងសកលលោក ។ ក្នុងបរិការណ៍នេះ កម្ពុជាត្រៀមខ្លួនជាស្រេចដើម្បីចូលរួមចែករំលែកនូវស្ថានភាពឈ្នះ ឈ្នះជាមួយគ្រប់ដៃគូពាក់ព័ន្ធនៅក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការ ពិសេសក្នុងក្របខណ្ឌគំនិតផ្ដួចផ្ដើមនៃការស្ថាបនាវិថីសូត្រសមុទ្រ សម្រាប់សតវត្សរ៍ទី ២១ នេះ ទទួលបាននូវភាពជោគជ័យ ។

សម្តេចតេជោ **ហ៊ុន សែន** បានបន្ដថា កម្ពុជាមានការពេញចិត្ត និងកោតសរសើរចំពោះមិត្តចិន ដែលបានខិតខំប្រឹងប្រែង ព្រមទាំងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹង និងពង្រីកការតភ្ជាប់តំបន់ ។ វេទិកានាពេលនេះ ពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកិច្ចសហប្រតិបត្តិការអភិវឌ្ឍនៅក្នុងវិស័យភ្ជាប់រូបវន្ត ពាណិជ្ជកម្ម ធុរកិច្ច ការវិនិយោគ ទេសចរណ៍ និងវប្បធម៌ រវាងសាធារណរដ្ឋប្រជាមានិតចិន និងបណ្ដាប្រទេសផ្សេងទៀតនៅក្នុងតំបន់អាស៊ាន ។ កម្ពុជាយល់ឃើញថា អាស៊ាននិងចិន នៅតែមានសក្តានុពលច្រើនណាស់ក្នុងកិច្ចសហប្រតិបត្តិការរួមគ្នា ហើយឆ្នាំនេះគឺជាឆ្នាំទី ១ នៃសហគមន៍សេដ្ឋកិច្ចអាស៊ានដែលជាទីផ្សារមួយមានប្រជាជនជាង ៦០០ លាននាក់ និងជារោងចក្រផលិតថ្មីមួយរបស់ពិភពលោកដែលមានតម្រូវការចាំបាច់ក្នុងវិស័យសំខាន់ៗមួយចំនួន ដូចជាអគ្គិសនី បច្ចេកវិទ្យាព័ត៌មាន កសិកម្ម ការអភិវឌ្ឍធនធានមនុស្ស ការស្រាវជ្រាវ និងគំនិតច្នៃប្រឌិតថ្មីៗ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិបទដែលទាមទារឲ្យមានការចូលរួម និងកិច្ចសហការកាន់តែស៊ីជម្រៅពីសំណាក់ដៃគូសន្ធនានានារបស់អាស៊ាន ជាពិសេសចិន ដែលជាប្រទេសមហាអំណាចសេដ្ឋកិច្ចទី ១ នៅក្នុងតំបន់ ។ ដូច្នេះកម្ពុជាសូមគាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែង សំដៅលើកស្ទួយកិច្ចសហប្រតិបត្តិការអាស៊ានចិន ក្នុងគ្រប់វិស័យឲ្យកាន់តែស៊ីជំរៅថែមទៀត ពិសេសតាមរយៈការជំរុញ និងលើកទឹកចិត្តវិនិយោគិនចិនឲ្យទៅវិនិយោគនៅក្នុងតំបន់អាស៊ាន ឲ្យកាន់តែច្រើនឡើង ។ សម្តេចតេជោបានបន្ថែមថា បើទោះបីកន្លងមកនេះពិភពលោកបានជួបនូវវិបត្តិសេដ្ឋកិច្ចយ៉ាងណាក្តី ប៉ុន្តែប្រទេសចិនបានរក្សាបាននូវលំនឹងផ្នែកសេដ្ឋកិច្ច ហើយបានក្លាយជាដៃគូលំដាប់ទី ១ របស់អាស៊ានដដែល ។ ក្នុងឆ្នាំ ២០១៥ កន្លងមក ចិនបានវិនិយោគដោយផ្ទាល់ជាមួយអាស៊ាន ៨.២០០ លានដុល្លារ ហើយបានក្លាយជាដៃគូលំដាប់ទី ៤ របស់ប្រទេសអាស៊ានផងដែរ ។

នៅក្នុងវេទិកាវិនិយោគ និងពាណិជ្ជកម្មកម្ពុជា-ចិនលើកទី១នាព្រឹកថ្ងៃទី ១២ ខែកញ្ញា សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជាបានមានប្រសាសន៍ថាប្រមុខដឹកនាំនៃប្រទេសទាំងពីរ បានបង្កើនផែនការពង្រីកទំហំពាណិជ្ជកម្មឱ្យបានចំនួន ៥ ៣ន់លានដុល្លារ នៅឆ្នាំ ២០១៧ ។ តាមការអនុវត្តជាក់ស្ដែង ពាណិជ្ជកម្មសរុបរវាងកម្ពុជា និងចិនក្នុងឆ្នាំ ២០១៥ សម្រេចបានចំនួន ៤៣៣១ លានដុល្លារ មានការកើនឡើង ១៥,១៩ ភាគរយ បើប្រៀបធៀបនឹងឆ្នាំ ២០១៤ ដែលសម្រេចបានចំនួន ៣៧៦០ លានដុល្លារ ។ ក្នុងនោះការនាំចេញរបស់កម្ពុជាទៅប្រទេសចិនក្នុងឆ្នាំ ២០១៥ មានចំនួន ៤០៥ លានដុល្លារ ថយចុះ ១៥,៦៣ ភាគរយ បើប្រៀបឆ្នាំ ២០១៤ ដែលមានចំនួន ៤៨០ លានដុល្លារអាមេរិក និងការនាំចូលកម្ពុជាពីប្រទេសចិន ក្នុងឆ្នាំ ២០១៥ មានចំនួន ៣៩២៦ លានដុល្លារ កើនឡើង ១៩,៧០ % បើប្រៀបធៀបនឹងឆ្នាំ ២០១៤ ដែលមានចំនួន ៣២៨០ លានដុល្លារ ។ សម្តេចតេជោបានបន្ដឲ្យដឹងថា ក្នុងក្របខណ្ឌនៃការវិនិយោគផ្ទាល់ពីបរទេស និងផ្នែកតាមការកត់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងរយៈពេល ៥ ឆ្នាំ ជាប់ៗគ្នាពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៥ ចិនគឺជាប្រទេសដែលបានដាក់ទុនវិនិយោគច្រើនជាងគេនៅកម្ពុជា ដោយបានបោះទុនវិនិយោគសរុបប្រមាណ ៤,៩ ៣ន់លានដុល្លារ ក្នុងនោះការវិនិយោគរបស់ចិននៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួនប្រមាណ ៥៦០ លានដុល្លារ ។ កម្ពុជាទទួលបានកំណើនវិនិយោគយ៉ាងច្រើនពីវិស័យឯកជនរបស់ចិនដូចជា ហេដ្ឋារចនាសម្ព័ន្ធថាមពល គម្រោងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងការពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យពា-

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទស្សនាការតាំងពិព័រណ៍អាស៊ាន-ចិនលើកទី ១៣ នៅខេត្តហ្វាងស៊ី*

ណិជ្ជកម្ម កសិកម្មនិងទេសចរណ៍ ផងដែរ ។ ទាក់ទិននឹងចំណងមិត្តភាពរវាងប្រទេសទាំងពីរវិញ សម្ដេចតេជោ **ហ៊ុន សែន** បានឲ្យដឹងបន្ថែមថា ផ្អែកលើទំនាក់ទំនងមិត្តភាពជាប្រពៃណីនេះ រដ្ឋាភិបាលនៃប្រទេសពីរ កម្ពុជា ចិន បានខិតខំលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីរហូតដល់កម្រិតកំពូលមួយគឺ "កិច្ចសហប្រតិបត្តិការ ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ" ។

សម្ដេចតេជោ **ហ៊ុន សែន** បានថ្លែងបញ្ជាក់សារជាថ្មីនូវការគាំទ្រចំពោះគំនិតផ្ដួចផ្ដើមរបស់ឯកឧត្ដម **ស៊ី ជីនពីង** ប្រធានាធិបតីចិន ក្នុងការបង្កើតខ្សែក្រវាត់សេដ្ឋកិច្ចផ្លូវសូត្រ និងផ្លូវសូត្រសមុទ្រសតវត្សទី ២១ ដើម្បីជំរុញការតភ្ជាប់ទ្វីបអាស៊ី អឺរ៉ុប និងអាហ្វ្រិក ក៏ដូចជាជាមួយប្រទេសដទៃទៀតនៅក្នុងពិភពលោក ក្នុងការជំរុញតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ពាណិជ្ជកម្ម ហិរញ្ញវត្ថុ ការភ្ជាប់ទំនាក់ទំនងប្រជាជន និងប្រជាជន និងការផ្លាស់ប្តូរវប្បធម៌ សម្រាប់កិច្ចសហប្រតិបត្តិការឈ្នះ ឈ្នះ ជំរុញការអភិវឌ្ឍន៍រួមដើម្បីមិត្តភាព សន្តិភាព និងវិបុលភាព ។ តាមរយៈក្របខណ្ឌខ្សែក្រវាត់មួយ ផ្លូវមួយ នេះសូមឲ្យមន្ត្រីសេដ្ឋកិច្ចធុរជននានា ដែលអាចទាក់ទាញការវិនិយោគ ដោយប្រើប្រាស់មូលនិធិផ្លូវសូត្រ ដែលមានទឹកប្រាក់ចំនួនប្រមាណ ៤០ ពាន់លានដុល្លារអាមេរិក មកអភិវឌ្ឍន៍សេដ្ឋកិច្ច ពាណិជ្ជកម្ម និងតភ្ជាប់ខេត្ត តាមមាត់សមុទ្ររបស់កម្ពុជា និងចិន ។ ដោយយល់ឃើញពីសក្តានុពលដ៏ធំធេងរបស់ខេត្តនៅតាមមាត់សមុទ្រ យើងបានជ្រើសរើសយកខេត្តកោះកុង ធ្វើជាទីក្រុងស្រស់ប្រិមប្រិយរបស់កម្ពុជាក្នុងការរៀបចំពន្លាជាតិ

ក្នុងឱកាសនៃការតាំងពិព័រណ៍ពាណិជ្ជកម្មអាស៊ាន ចិនលើកទី ១៣ នេះ ដើម្បីតំណាងឲ្យព្រះរាជាណាចក្រកម្ពុជាស្របតាមប្រធានបទ "សហប្រតិបត្តិការផ្លូវសូត្រតាមដែនសមុទ្រសតវត្សរ៍ទី ២១" ។

នៅព្រឹកថ្ងៃទី ១២ ខែកញ្ញា ដែលជាថ្ងៃបញ្ចប់នៃទស្សនកិច្ចនៅក្នុងទីក្រុងណាននីង ប្រទេសចិន សម្ដេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមក្នុងវេទិកាពាណិជ្ជកម្ម និងវិនិយោគកម្ពុជា ចិន លើកទី ១ ដែលមានអ្នកចូលរួមប្រមាណជា ៤០០ នាក់ ដែលក្នុងនោះភាគច្រើនជាអ្នកវិនិយោគចិន ។ ថ្លែងនៅពេលនោះ សម្ដេចតេជោបានចាត់ទុកវេទិកានេះថាជាវេទិកាប្រវត្តិសាស្ត្រមួយសម្រាប់កៀរគរការវិនិយោគ និងពាណិជ្ជកម្ម ជាវេទិកាសម្រាប់ការចាប់ដៃគូរកស៊ីរវាងអ្នកវិនិយោគ ចិននិងអ្នកវិនិយោគកម្ពុជា ។ សម្ដេចតេជោក៏បានជម្រាបជូនអ្នកវិនិយោគនូវនយោបាយបើកចំហររបស់កម្ពុជា គឺស្វាគមន៍រាល់ការវិនិយោគពីខាងក្រៅ ពិសេសគឺវិនិយោគពីប្រទេសចិនលើគ្រប់វិស័យ ។ សម្ដេចតេជោបានប្រាប់ទៅក្រុមអ្នកវិនិយោគចិនថាកុំសម្លឹងឃើញកម្ពុជាជាទីផ្សារតូចមួយដែលមានមនុស្សត្រឹម ១៥ លាននាក់ ត្រូវសម្លឹងមើលទៅដល់ទីផ្សារប្រទេសមេគង្គ ដែលមានប្រជាជនជាង ២៦០ លាននាក់ ទីផ្សារអាស៊ានដែលមានប្រជាជនចំនួនជាង ៩៣២ លាននាក់ ទីផ្សារនៅសហភាពអឺរ៉ុប និងតំបន់មួយចំនួនទៀត ដែលសុទ្ធសឹងជាទីផ្សាររបស់កម្ពុជា ។ សូមចាត់ទុកកម្ពុជាជាកន្លែងផលិតសម្រាប់បម្រើការនាំចេញ ។ សម្ដេចតេជោក៏បានបង្ហាញពីសក្តានុពលរបស់កម្ពុជា មានដូចជា វិស័យកសិកម្ម ទេសចរណ៍ ថាមពល និងវិស័យឧស្សាហកម្ម ។ ជាចុងក្រោយសម្ដេចតេជោនាយករដ្ឋមន្ត្រីបានសំណូមពរឲ្យមានការរៀបចំវេទិកានេះជារៀងរាល់ឆ្នាំ ដើម្បីទាក់ទាញវិនិយោគមកកាន់កម្ពុជាឲ្យបានកាន់តែច្រើនថែមទៀត ។

ការតាំងពិព័រណ៍អាស៊ាន-ចិន លើកទី១៣ នេះកាន់តែពង្រឹងថែមទៀតនូវកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន ដែលបានទទួលហ៊ានៈជាដៃគូពេញសិទ្ធិនៅឆ្នាំ ១៩៩៦ និងត្រូវបានតម្លើងទៅជាភាពជាដៃគូយុទ្ធសាស្ត្រនៅឆ្នាំ ២០០៣ ។ ប្រទេសចិនគឺជាដៃគូពាណិជ្ជកម្មធំបំផុតរបស់អាស៊ានដែលនៅក្នុងឆ្នាំ ២០១៥ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងអាស៊ានចិនមានតម្លៃដល់ទៅ ៤៧២,១៦ ពាន់លានដុល្លារអាមេរិក ។ ដោយឡែកជាមួយកម្ពុជា ពាណិជ្ជកម្មរវាងកម្ពុជា និងចិនក្នុងឆ្នាំ ២០១៦ នេះ មានទំហំប្រមាណ ៤,៣១ ពាន់លានដុល្លារអាមេរិក ហើយឆ្នាំ ២០១៧ ខាងមុខនឹងកើនឡើងដល់ប្រមាណ ៥ ពាន់លានដុល្លារអាមេរិក ។

តមកពីទំព័រទី ៣

ប្រព្រឹត្តល្មើសច្បាប់របស់ខ្លួនប៉ុណ្ណោះ។ ការចរចានយោបាយជាយន្តការប្រជាធិបតេយ្យមួយដែលរួមចំណែកពង្រឹងនីតិរដ្ឋ តែគេមិនអាចយកដំណោះស្រាយនយោបាយទៅគ្របដណ្ដប់លើរដ្ឋធម្មនុញ្ញ និងច្បាប់បានឡើយ។ ប្រទេសជាតិកំពុងធ្វើដំណើរលើផ្លូវត្រូវ គឺផ្លូវនីតិរដ្ឋផ្លូវសន្តិភាព ផ្លូវអភិវឌ្ឍន៍ ប្រជាជនកំពុងរស់ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ ភាពសុខសាន្ត ប្រជាជនមិនត្រូវការមហាបាតកម្មឡើយ ។

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសយ៉ាងម៉ឹងម៉ាត់ ក្នុងការកម្ចាត់មហាបាតកម្មនេះបើវាកើតមានឡើង ដោយបញ្ជាឲ្យកម្លាំងមានសមត្ថកិច្ចត្រៀមទប់ស្កាត់រាល់សកម្មភាពទាំងឡាយណា ដែលនឹងបង្ករនូវភាពវឹកវរក្នុងសង្គម ។ ប្រជាជនគ្រប់ស្រទាប់ គ្រប់មជ្ឈដ្ឋាន អង្គការសហជីព អង្គការនៃសង្គមស៊ីវិល បានប្រកាសគាំទ្រនូវជំហរដ៏មុតមាំនេះរបស់រាជរដ្ឋាភិបាល ។ កងកម្លាំងប្រដាប់អាវុធក៏បានប្រកាសប្ដេជ្ញាអនុវត្តតាមបទបញ្ជារបស់សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារសន្តិភាព ការពាររដ្ឋធម្មនុញ្ញ ការពាររាជរដ្ឋាភិបាល ការពារសេចក្ដីសុខរបស់ប្រជាជន។ គណបក្សប្រជាជនកម្ពុជាគាំទ្រពេញទំហឹងចំពោះចំណាត់ការដ៏ត្រឹមត្រូវរបស់តុលាការ និងកិច្ចខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងវិធានការច្បាប់ ដើម្បីពង្រឹងនីតិរដ្ឋ មិនឲ្យពួកប្រឆាំង និងមជ្ឈដ្ឋានអតិណាមកបំផ្លាញសន្តិភាព ការអភិវឌ្ឍ និងជីវភាពដ៏សុខសាន្តរបស់ប្រជាជនបានឡើយ ។

សម្តេចតេជោ : ផ្តល់សារសំខាន់បំផុតលើការចុះឈ្មោះបោះឆ្នោត
❋ការលើកកម្ពស់វិស័យអប់រំ
❋និងផ្តល់អនុសាសន៍ទាក់ទងនឹងតម្លៃស្រូវ-អង្ករ

ក្នុងខែកញ្ញាឆ្នាំ២០១៦ កន្លងទៅនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមសម្ពោធសមិទ្ធផលមួយចំនួន ចូលរួមជួបជាមួយសិស្សពូកែប្រឡងជាប់និទ្ទេស A ព្រមទាំងចែកសញ្ញាបត្រដល់និស្សិតដែលបញ្ចប់ការសិក្សាជាច្រើនសាកលវិទ្យាល័យផងដែរ ។

❋ល្ងាចថ្ងៃទី ១ ខែកញ្ញា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** បានអញ្ជើញចុះឈ្មោះបោះឆ្នោតក្នុងប្រព័ន្ធបញ្ជីបោះឆ្នោតថ្មីនៅសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាលដែលជាថ្ងៃដំបូងនៃដំណើរការចុះឈ្មោះបោះឆ្នោត ។

*ថ្ងៃទី ១ ខែកញ្ញា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** អញ្ជើញចុះឈ្មោះបោះឆ្នោតក្នុងប្រព័ន្ធបញ្ជីបោះឆ្នោតថ្មី នៅសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល*

សម្តេចតេជោបានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ចូលរួមឲ្យបានពេញលេញក្នុងដំណើរការប្រជាធិបតេយ្យ និងបច្ចេកវិទ្យាទំនើបដែលបាន និងកំពុងប្រើប្រាស់ចាប់ពីថ្ងៃនេះទៅ ។ ប្រជាពលរដ្ឋទាំងអស់ ទោះជាធ្លាប់បោះឆ្នោតបួន-ប្រាំអាណត្តិរួចមកហើយក៏ដោយ តែបញ្ជីបោះឆ្នោតកាលពីមុនមិនត្រូវបានប្រើប្រាស់ទៀតទេ ដូចនេះបើចង់ប្រើប្រាស់សិទ្ធិរបស់ខ្លួនត្រូវអញ្ជើញមកចុះឈ្មោះបោះឆ្នោត ។

សម្តេចតេជោបានរំលឹកឡើងវិញ ពាក់ព័ន្ធទៅនឹងការចរចានៅពេលកន្លងមករវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។ កាលណោះគណបក្សសង្គ្រោះជាតិបានស្នើសុំត្រឹមការកែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប.)ចំណែកសម្តេចបានសូមឲ្យធ្វើការកែទម្រង់ការបោះឆ្នោត ។ នេះជាចំណុចចាប់ផ្តើម ។ សម្តេចតេជោបានបន្ថែមថា អស់លោកអាចមើលឃើញថា ម្ខាងគ្រាន់តែទាមទារឲ្យមានការផ្លាស់ប្តូរសមាសភាព គ.ជ.ប.តែប៉ុណ្ណោះ ឯខ្ញុំវិញសុំឲ្យមានការកែទម្រង់ទូលំទូលាយរាប់ទាំងប្រព័ន្ធបោះឆ្នោតនេះផង ។

សម្តេចផ្ទាល់ក៏បានស្នើសុំទៅឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុន **ស៊ីនហ្ស៊ូ អាបេ** ឲ្យមានការជួយកែទម្រង់ការបោះឆ្នោត ក្នុងនោះប្រព័ន្ធចុះឈ្មោះបោះឆ្នោតឡើងវិញនេះ ដើម្បីឲ្យបញ្ជីបោះឆ្នោតនេះមានសុក្រឹត្យភាពហើយកុំឲ្យមានបក្សនយោបាយខ្លះចេះតែប្រើពាក្យថាបាត់មនុស្ស ឬខុសនេះខុសនោះ ។ យើងចង់ឲ្យមានសុក្រឹត្យភាពច្បាស់លាស់ ។ សម្តេចតេ-ជោបញ្ជាក់ថា "ខ្ញុំសង្ឃឹមថាប្រជាពលរដ្ឋកម្ពុជារបស់យើងនឹងចូលរួមពេញលេញក្នុងដំណើរការប្រជាធិបតេយ្យ និងបច្ចេកវិទ្យាទំនើបរបស់យើងដែលយើងបាន និងកំពុងប្រើប្រាស់ ហើយចាប់ផ្តើមនៅថ្ងៃនេះ" ។

ពាក់ព័ន្ធនឹងសំណួរដែលបានសួរថា តើអាចមានការប្តឹងតវ៉ាជំទាស់ទៀតទេនៅពេលលទ្ធផលបោះឆ្នោតចេញ ? សម្តេចតេជោបានតបថា សម្តេចមិនសង្ឃឹមថាគេនឹងតវ៉ាបែបនេះទេ ប៉ុន្តែក៏អាចផងដែរ ព្រោះសូម្បីតែហ្វេសប៊ុក Like ចាញ់សម្តេចក៏គេករឿងដែរ ។ ប៉ុន្តែករឿងយ៉ាងណាក៏ដោយសូមបញ្ជាក់ថា បើមិនចូលប្រជុំសភាទេ បើមិនចូលស្បថទេ គឺនឹងបាត់បង់កៅអីទាំងអស់ ។ សូមបញ្ជាក់តែប៉ុណ្ណឹង ព្រោះច្បាប់ថ្មីមិនអនុញ្ញាតឲ្យអ្នកឯងធ្វើពហិកាកន្លះឆ្នាំ មួយឆ្នាំទេ ។ បានសេចក្ដីថាទី ១.សភាកោះប្រជុំក្រោមព្រះរាជធិបតីរបស់ព្រះមហាក្សត្រ បើអ្នកឯងមិនចូលគឺ ត្រូវតែបាត់ ។ ទី២.ការស្បថចូលកាន់មុខតំណែង បើអ្នកឯងមិនចូលក៏បាត់ហើយ នៅមានរឿងមួយចំនួនទៀតដែលត្រូវតែគិត ប៉ុន្តែសម្តេចសង្ឃឹមថាគណ-បក្សនយោបាយទាំងអស់នឹងទទួលបានទាំងអស់គ្នា ព្រោះនេះជាការកែ-ទម្រង់មួយដ៏ធំដែលយើងមិនធ្លាប់មានពីមុនមក ។ សង្ឃឹមថានៅពេលខាងមុខ យើងនឹងរកឃើញថាមនុស្សចំនួន ១,២ លាននាក់ ដែលគេធ្លាប់ថាបាត់នោះ តើវាទៅណា នៅពេលដែលចុះឈ្មោះនេះហើយ? ។ សម្តេចតេជោបន្ថែមថា យើងកំពុងតែប្រុងប្រៀបនូវការគិតគូបែបនេះ ព្រោះនៅពេលបោះឆ្នោត ២០១៣ គេថាបាត់ឈ្មោះ ១,២ លាននាក់ ។ ឥឡូវនេះរង់ចាំមើលថា បន្ទាប់ពីការចុះឈ្មោះនេះ តើមនុស្ស ១,២ លាននាក់នោះនឹងស្ថិតនៅក្នុងបញ្ជីនេះ ឬក៏នៅបាត់បន្ត? ។ បើនៅបាត់បន្តអ្នកបំផុសឲ្យមានរឿងនេះពេលមុនត្រូវទទួលខុសត្រូវបែបណា?ដូចនេះសូមអំពាវនាវឲ្យប្រជាពលរដ្ឋទាំងអស់បង្ហាញខ្លួននៅពេលនេះ ដើម្បីចៀសវាងនូវការចោទប្រកាន់ថាបាត់មនុស្ស ព្រោះមនុស្សមិនមែនសត្វមាន់ ឬសត្វចាបទេ ។ បាត់ ១,២ លាននាក់ គឺច្រើនណាស់ ។

សម្តេចតេជោបានស្នើឲ្យអ្នកនិយាយថា បាត់ៗនោះស្តាប់ភាសាសម្តេចឲ្យបានច្បាស់ម្រាប់ទាំងអ្នកនិយាយថា ទឹកខ្មៅលុបជ្រុះក្នុងរយៈពេលមិនដល់ទាំង ១២ ម៉ោង, មិនដល់ ២៤ ម៉ោង មុនការបោះឆ្នោត ។ ប៉ុន្តែការពិតជាក់ស្តែង ទឹកខ្មៅនោះត្រូវបានអ្នកទាំងអស់គ្នាប្រើប្រាស់ធ្វើជាមូលដ្ឋានក្នុងការបោះឆ្នោត ប៉ុន្តែគេបានស្រែករឿងនេះ ។ យើងនឹងទូទាត់បញ្ជីមួយនៅពេលខាងមុខ ដើម្បីពិនិត្យឲ្យដឹងថា តើការបោះឆ្នោតរយៈពេលកន្លងទៅមានបាត់មនុស្សដូចដែលគេលើកឡើងឬទេ?យើងក៏កំពុងស្វែងរកថាទឹកខ្មៅនោះត្រូវបានប្រើប្រាស់ខុស ឬលុបជ្រុះដូចដែលគេបានលើកឡើងឬទេ? ព្រោះនេះគ្រាន់តែជាលេសដើម្បីបង្កមហន្តរាយ សម្រាប់ប្រទេសតែប៉ុណ្ណោះ ។

❋ព្រឹកថ្ងៃទី ១៩ ខែកញ្ញា សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីចែកសញ្ញាបត្រ

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អញ្ជើញពិនិត្យបន្ទប់នានានៃមន្ទីរពេទ្យជប៉ុន **សាន់រ៉ាយស៍** ភ្នំពេញ ដែលជាមន្ទីរពេទ្យដំបូងវិនិយោគដោយវិស័យឯកជនជប៉ុន*

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជួបសំណេះសំណាលជាមួយសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ នៅអនុវិទ្យាល័យលំផាត់ ក្នុងឃុំជ័យឧត្ដម ស្រុកលំផាត់ ខេត្ដរតនគិរី ក្នុងឱកាសដែលសម្ដេចបានអញ្ជើញពិនិត្យវឌ្ឍនភាពនៃការអនុវត្ដកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ដែលអនុវត្ដបានពាក់កណ្ដាលអាណត្ដិនៃរាជរដ្ឋាភិបាល*

ដល់និស្សិតសាកលវិទ្យាល័យបញ្ញាជាតិនៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ ។

សម្ដេចតេជោ បានលើកជាអនុសាសន៍ដល់ឯកឧត្ដមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឬ ឲ្យពិនិត្យលទ្ធភាពដល់សិស្សប្រឡងជាប់បាក់ឌុបគ្រប់និទ្ទេសរាប់ចាប់តាំងពី(A)ដល់(E) ដើម្បីឲ្យពួកគេប្រឡងចូលក្រុ-ខណ្ឌគ្រូដោយស្មើភាព ។ នេះជាលទ្ធភាពថ្មី ព្រោះកន្លងមកសិស្សទទួលបាននិទ្ទេស A, B, C ពួកគេត្រូវបានបញ្ជូលទៅក្នុងក្រុមខណ្ឌគ្រូដោយស្វ័យប្រវត្ដិប្រសិនជាសិស្សមានបំណងចង់ធ្វើជាគ្រូបង្រៀន ។ តែទោះបីយ៉ាងណា សម្ដេចតេជោក៏បានបញ្ជាក់ដែរថា គួរតែអនុគ្រោះដល់និទ្ទេស A ដោយឲ្យពួកគេចូលក្រុមខណ្ឌគ្រូដោយស្វ័យប្រវត្ដិ ។ ប៉ុន្ដែផ្ទុយមកវិញ សម្ដេចនៅតែចង់ឲ្យសិស្សនិទ្ទេស A ចូលរួមប្រឡងដោយស្មើគ្នា ព្រោះគេមានសមត្ថភាពរួចទៅហើយ ។

បើតាមឯកឧត្ដមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឬ បានឲ្យដឹងថានៅឆ្នាំនេះ រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យរើសក្រុមខណ្ឌគ្រូបង្រៀនចំនួន ៣.000 នាក់ ។

សម្ដេចតេជោបានធ្វើការប៉ាន់ប្រមាណថា យ៉ាងហោចណាស់ក៏មានសិស្សប្រមាណ ២ ម៉ឺននាក់ ក្នុងចំណោមសិស្សដែលជាប់ជាង ៥ ម៉ឺននាក់ ដាក់ពាក្យប្រឡងធ្វើគ្រូដែរ ។ ដូច្នេះគួរតែមានការប្រឡងដើម្បីចម្រាញ់ជ្រើសរើសគ្រូដែលពូកែ ទោះត្រូវចំណាយថវិកាក៏ដោយដើម្បីទទួលបានមកវិញនូវសមធម៌សង្គម ។

ក្នុងឱកាសនេះដែរ ទាក់ទងទៅនឹងបញ្ហាស្រូវអង្ករ សម្ដេចតេជោបានអំពាវនាវឲ្យធនាគារពាណិជ្ជកម្មបន្ដផ្ដល់ប្រាក់កម្ចីដល់ក្រុមហ៊ុនរកស៊ីផ្នែកស្រូវអង្ករ និងអំពាវនាវឲ្យស្ថាប័នមីក្រូហិរញ្ញវត្ថុពន្យារពេលការសងប្រាក់ និងបន្ទូរបន្ថយការប្រាក់ ។ អំពាវនាវឲ្យឈ្មួញប្រមូលទិញ និងប្រជាពលរដ្ឋបរិភោគអង្ករក្នុងស្រុក ។ ជាមួយនេះ សម្រាប់រយៈពេលមធ្យមខាងមុខ សម្ដេចតេជោបានឲ្យដឹងថា កម្ពុជាត្រូវការទុនពីចិនប្រមាណ ៣00 លានដុល្លារ សម្រាប់វិនិយោគលើវិស័យកែច្នៃអង្ករ ។

សម្ដេចតេជោ **ហ៊ុន សែន** ក៏បានសុំការយោគយល់ពីប្រជាកសិករពាក់ព័ន្ធនឹងតម្លៃស្រូវធ្លាក់ចុះនេះ ព្រោះមិនមែនតែកម្ពុជាមួយទេគឺជាបញ្ហាសាកល ដោយសារថាវិបត្ដិហិរញ្ញវត្ថុសាកលលោកមិនទាន់ផុតរលត់នៅ

ឡើយទេ ។ តម្លៃស្បៀង តម្លៃប្រេងឥន្ធនៈ កៅស៊ូ នៅតែបន្ដធ្លាក់ចុះ បានធ្វើឲ្យប្រទេសផលិតប្រេងកំពុងបាត់បង់នូវប្រាក់ចំណូលយ៉ាងខ្លាំង ។ ដូចគ្នានេះ តម្លៃកៅស៊ូក៏មានការធ្លាក់ចុះផងដែរ ប្រទេសមួយចំនួន ដូចជាប្រទេសថៃបានបិទចំការកៅស៊ូ ឈប់ចៀរដំរ ដោយសារតែតម្លៃលក់ទាបជាងតម្លៃនៃការផលិត ។ តែសម្រាប់កម្ពុជា រាជរដ្ឋាភិបាលបានឧបត្ថម្ភទុនតាមរយៈការបន្ទូរបន្ថយប្រាក់ពន្ធជាដើម ។

សម្ដេចតេជោបានបន្ដថាបញ្ហាតម្លៃស្រូវធ្លាក់ចុះមិនមែនជាបញ្ហាកម្ពុជាតែម្នាក់នោះទេ ។ ដោយសារថា ប្រទេសកំពុងអភិវឌ្ឍន៍ ជាទូទៅមានការប្រកួតប្រជែងគ្នាទៅលើមុខទំនិញដូចគ្នា វាខុសពីប្រទេសអភិវឌ្ឍន៍ដែលគេមានប្រភេទទំនិញផ្សេងៗគ្នា ។ គ្រាន់តែក្នុងក្រុមខណ្ឌប្រទេសអ៊ីចមុ៉ចមួយ(កម្ពុជា,ថៃ ,វៀតណាម,ឡាវ,មីយ៉ាន់ម៉ា)ប្រទេសថៃផលិតអង្ករមួយឆ្នាំសល់ ១0 លានតោន ដូចនេះគេចាំបាច់ត្រូវការបញ្ចេញអង្ករឲ្យបាន ២ លានតោនក្នុង ១ ឆ្នាំ, ប្រទេសវៀតណាមផលិតអង្ករនាំចេញមួយឆ្នាំរាប់លានតោន, ប្រទេសមីយ៉ាន់ម៉ាក៏ផលិតអង្ករនាំចេញ,ប្រទេសឡាវមានអង្ករគ្រប់គ្រាន់សម្រាប់ហូប ។

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានបន្ដថា ចំពោះវិធានការរយៈពេលមធ្យម រាជរដ្ឋាភិបាលកម្ពុជាត្រូវការខ្វីលុយពីប្រទេសចិនចំនួន ៣00 លានដុល្លារ ដើម្បីទប់ស្កាត់ការធ្លាក់ចុះតម្លៃស្រូវ ពិសេសដើម្បីធ្វើជាទុនសម្រាប់ទិញស្រូវ ខណៈបច្ចុប្បន្ន ទុនដែលកម្ពុជាមាននៅមិនទាន់គ្រប់គ្រាន់ ។ យើងត្រូវការខ្វីចិន ៣00 លានដុល្លារ សម្រាប់កសាងទីតាំងមួយចំនួនសម្រាប់រោងម៉ាស៊ីនកិនស្រូវ, ឡសម្ងួត និងធ្វើឃ្លាំងស្តុក ក៏ដូចជាទុនក្នុងការទិញស្រូវ ។

❋ព្រឹកថ្ងៃទី ២0 ខែកញ្ញា សម្ដេចតេជោ **ហ៊ុន សែន** បានអញ្ជើញសម្ពោធមន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍ភ្នំពេញ ដែលជាមន្ទីរពេទ្យដំបូងវិនិ-យោគដោយវិស័យឯកជនជប៉ុន ក្នុងទំហំទឹកប្រាក់ប្រមាណ ៣៥ លានដុល្លារ ។ មន្ទីរពេទ្យនេះស្ថិតក្នុងសង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ ។

សម្ដេចតេជោបានគាំទ្រ ចំពោះការអះអាងរបស់លោកប្រធានមន្ទីរ-

*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាលជាមួយសិស្សទុតិយភូមិ ឬបាក់ឌុប និទ្ទេសអេ (A)ចំនួន ៤០៥ នាក់ និងលោកគ្រូអ្នកគ្រូ ព្រមទាំងមន្ត្រីក្រសួងអប់រំយុវជន និងកីឬា នៅវិមានសន្តិភាព*

ពេទ្យដែលបានបញ្ជាក់ថា នេះជាការចាប់ផ្ដើម ហើយនឹងមានការវិនិយោគបន្ថែមទៀត និងឈានទៅបង្កើតសាកលវិទ្យាល័យសុខាភិបាលមួយនៅកម្ពុជាផងដែរ ។ សម្ដេចតេជោបន្ថា ការដែលយើងមានមន្ទីរពេទ្យខ្នាតខ្ពស់បែបនេះ វាមិនត្រឹមតែជាបញ្ហាដាច់ដោយឡែករបស់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែវាបង្កើតបាននូវជំនឿទុកចិត្តសម្រាប់អ្នកវិនិយោគ និងអ្នកទេសចរណ៍ដែលមានប្រាក់ហើយមកពីចំងាយគេត្រូវដឹងថា នៅពេលដែលគេមកវិនិយោគ និងមកធ្វើទេសចរនៅកម្ពុជា តើមានមន្ទីរពេទ្យ និងមានសេវាគ្រប់គ្រាន់ដើម្បីសង្គ្រោះគេឬទេ? ដូច្នេះការសាងសង់មន្ទីរពេទ្យនេះ មិនមែនគ្រាន់តែជាបញ្ហាសុខភាពនោះទេ ក៏ប៉ុន្តែវាជះឥទ្ធិពលទៅលើបញ្ហាដទៃទៀត រាប់ទាំងវិស័យទេសចរណ៍ ការវិនិយោគ និងអ្នកមកស្រាវជ្រាវនៅកម្ពុជាផងដែរ ។

❋ ព្រឹកថ្ងៃទី២១ខែកញ្ញាសម្ដេចតេជោនាយករដ្ឋមន្ត្រីបានអញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាលជាមួយសិស្សទុតិយភូមិ ឬបាក់ឌុប និទ្ទេសអេ (A)ចំនួន ៤០៥ នាក់ និងលោកគ្រូអ្នកគ្រូ ព្រមទាំងមន្ត្រីក្រសួងអប់រំយុវជន និងកីឬា នៅវិមានសន្តិភាព ។

នាឱកាសនោះ សម្ដេចតេជោបានបង្ហាញនូវក្តីសង្ឃឹមថា ២០ ឆ្នាំទៀត ធនធានមនុស្សរបស់កម្ពុជានឹងខ្លាំងសម្បើមណាស់ ។ សម្ដេចតេជោបានរំលឹកថា ក្រោយឆ្នាំ ១៩៧៩ ធនធានមនុស្សរបស់ប្រទេសនៅសល់តិចតួចណាស់ នៅក្នុងចំនួនតិចនេះ ក្រសួងការបរទេសដែលសម្ដេចដឹកនាំបានស្រូបយកធនធានបញ្ញវន្ដដែលក្រសួងនានាមិនត្រូវការយកទៅក្រសួងការបរទេស ដែលក្នុងនោះ មានវិស្វករហូតដល់ទៅ ៥ នាក់ ។ នៅពេលដែលសម្ដេចចេញទៅបរទេសម្ដង១ គោលបំណងធំគឺសុំអាហារូបករណ៍សម្រាប់និស្សិតកម្ពុជា ។ ដូច្នេះហើយបានជានិស្សិតរបស់យើងរាប់ម៉ឺននាក់បានទៅរៀននៅក្រៅប្រទេសក្នុងដំណាក់កាលនោះ ។

សម្ដេចតេជោបានកោតសរសើរថា កំណែទម្រង់ដែលក្រសួងអប់រំបានដឹកនាំធ្វើនៅក្នុងអាណត្តិថ្មីនេះ បានបង្កើតនូវស្ថានភាពមួយដែលបានបង្ហាញថា កូនសិស្សបានយកចិត្តទុកដាក់ខិតខំរៀន តាមរយៈការជួយបំប៉នសិស្សនៅមុនពេលប្រឡង គឺមានអន្តរសកម្មខ្លាំងណាស់សម្រាប់សិស្សទាំងសិស្សត្រៀមប្រឡង និងសិស្សផ្សេង១ទៀត ។

❋ ព្រឹកថ្ងៃទី ២២ ខែកញ្ញា សម្ដេចតេជោ **ហ៊ុន សែន** បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីចែកសញ្ញាបត្រដល់និស្សិតសកលវិទ្យាល័យពុទ្ធិសាស្ត្រ ដែលប្រារព្ធនៅសណ្ឋាគារសុខាភ្នំពេញ ។ នៅទីនោះ សម្ដេចតេជោបានថ្លែងសារនយោបាយជាប្រយោល សំដៅទៅរកគណៈ-បក្សប្រឆាំង និងអំពាវនាវជាថ្មីឲ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតឲ្យបានគ្រប់ៗគ្នា ។

សម្ដេចតេជោមានប្រសាសន៍ថា បទឈប់បាញ់នយោបាយថ្មីមួយ ហាក់បីដូចជាបានស្ងប់ស្ងាត់បន្ដិចកាលពីថ្ងៃអង្គារ ។ សម្ដេចរង់ចាំមើលថានរណាជាអ្នកវាយប្រហារមុនក្នុងឱកាសនៃពិធីបុណ្យភ្ជុំបិណ្ឌនេះ? ។ សម្ដេចតេជោបន្ថា "ខ្ញុំគួរតែមិនត្រូវបាននិយាយច្រើនទេដោយសារតែបទឈប់បាញ់មួយ ហាក់បីដូចជាបានស្ងៀមស្ងាត់បន្ដិចនៅក្នុងរយៈពេលតាំងពីថ្ងៃចន្ទ ។ ថ្ងៃចន្ទវាមានការបាញ់គ្នា ដល់ថ្ងៃអង្គារបទឈប់បាញ់មួយ គឺហាក់បីដូចជាមិនត្រូវមានការបាញ់ឆ្លងឆ្លើយទេ ។ បើអញ្ចឹងខ្ញុំរង់ចាំមើលថារដូវបុណ្យភ្ជុំបិណ្ឌនេះ នរណាវាយនរណាមុន?។ ព្រោះជាធម្មតាខ្ញុំចង់ឲ្យសភាពការណ៍វាស្ងប់ស្ងាត់ មិនចង់ឲ្យមានការឆ្លងឆ្លើយគ្នា ។

សម្ដេចតេជោក៏បានអំពាវនាវជាថ្មី ចំពោះប្រជាពលរដ្ឋឲ្យបន្ដការទៅចុះឈ្មោះបោះឆ្នោត ទោះបីថាមានការរវល់ ប៉ុន្តែសុំកុំបោះបង់សិទ្ធិរបស់ខ្លួនតាមរយៈការចុះឈ្មោះបោះឆ្នោត ។ សម្ដេចតេជោបន្ថា គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត,បណ្ដាបក្សនយោបាយទាំងអស់ សុទ្ធតែបានអំពាវនាវឲ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត ។ បណ្ដាបក្សនយោបាយ ទោះបីមានចំណុចខុសៗគ្នានៃកម្មវិធីនយោបាយរបស់ខ្លួន ក៏ប៉ុន្តែចំណុចរួមនៃបក្សនយោបាយទាំងអស់នៅកម្ពុជា គឺស្ថិតនៅត្រង់ថាអំពាវនាវឲ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត ។ សម្ដេចតេជោបានពន្យល់ថា ចុះនៅកន្លែងណាគឺជាសិទ្ធិ និងបំណងប្រាថ្នារបស់បុគ្គលម្នាក់ៗ។ កម្មករកម្ម-ការិនី បើយល់ថាចុះនៅភ្នំពេញស្រួលអាចចុះនៅភ្នំពេញទៅក្បែរកន្លែងធ្វើការរបស់ខ្លួន ។ តែបើយល់ថាទៅចុះនៅស្រុកភូមិដែលខ្លួនរស់នៅក៏ចុះទៅ អាស្រ័យលើខ្លួនឯង ។

គួរបញ្ជាក់ដែរថា នៅក្នុងខែកញ្ញានេះដែរ សម្ដេចតេជោក៏បានអញ្ជើញទៅពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុ-កោណដំណាក់កាលទី ៣ ដែលអនុវត្តបានពាក់កណ្ដាលអាណត្តិនៃរាជ-រដ្ឋាភិបាល នៅបណ្ដាខេត្តមួយចំនួន ក្នុងនោះមានខេត្តរតនគិរី និងខេត្តមណ្ឌលគិរីផងដែរ ។

សម្ដេចក្រឡាហោម ស ខេង អំពាវនាវឲ្យប្រជាជនចូលរួមកសាងប្រទេស តាមរយៈការអភិវឌ្ឍមូលដ្ឋានថ្នាល់

*សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីដាំកូនឈើ និងលែងកូនត្រីឆ្ពិនក្នុងបឹងកសិណមុខប្រាសាទបាណន់ ឃុំកន្ធឹ ១ ស្រុកបាណន់ ខេត្តបាត់ដំបង*

កាលពីព្រឹកថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៦ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានអញ្ជើញចូលរួមក្នុងពិធីដាំកូនឈើ និងលែងកូនត្រីឆ្ពិនក្នុងបឹងកសិណមុខប្រាសាទបាណន់ ឃុំកន្ធឹ ១ ស្រុកបាណន់ ខេត្តបាត់ដំបង ។

នៅក្នុងឱកាសនោះ សម្ដេចក្រឡាហោមបានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចយកខេត្តបាត់ដំបងធ្វើជាខេត្តគំរូ ក្នុងការផ្ទេរអំណាចក្នុងការគ្រប់គ្រងមត្តេយ្យសាលា ការអប់រំកុមារតូចៗ សាលាបឋមសិក្សាពីក្រសួងអប់រំ យុវជន និងកីឬ មកឲ្យរដ្ឋបាលស្រុក ក្រុង ទាំង ១៤ ក្នុងខេត្តបាត់ដំបង ដើម្បីធ្វើជាគំរូដល់ខេត្តដទៃទៀត ។ សម្ដេចក្រឡាហោម **ស ខេង** បានអំពាវនាវឲ្យអាជ្ញាធរស្រុកក្រុងត្រូវប្ដេជ្ញាចិត្តធ្វើឲ្យបានជោគជ័យ ព្រោះបើធ្វើមិនបានទេក្លាយទៅជាគំរូមិនល្អ ហើយមិនមែនជះឥទ្ធិពលតែត្រឹមវិស័យអប់រំទេ គឺវាជះឥទ្ធិពលដល់គ្រប់វិស័យទាំងអស់ ព្រោះយើងត្រូវផ្ទេរអំណាចឲ្យថ្នាក់ក្រោមជាតិ ។

សម្ដេចក្រឡាហោមបានថ្លែងបន្ដថា ការធ្វើប្រតិភូកម្មអំណាចនេះ មិនមែនផ្ទេរត្រឹមតែអំណាចប៉ុណ្ណោះទេ ។ តើយើងផ្ទេរយ៉ាងម៉េច? បើផ្ទេរតែអំណាចទទេ គឺពិតជាបរាជ័យ ដូច្នេះត្រូវផ្ទេរទាំងសិទ្ធិអំណាច ទាំងធនធាន ពោលគឺផ្ទេរ ៖ ទី១.ធនធានមនុស្សមានសមត្ថភាព មានចំណេះដឹង និងទី ២.ធនធានថវិកា ហិរញ្ញវត្ថុ ទ្រព្យសម្បត្ដិ គឺផ្ទេរទាំងអស់ ។ រឿងនេះនៅក្នុងប្រវត្ដិសាស្ត្រស្រុកខ្មែរមិនដែលមានទេ ទើបសម្ដេចមានការបារម្ភណាស់ ព្រោះរូបសម្ដេចជាអ្នកទទួលខុសត្រូវ ក្នុងការអនុវត្ដនយោបាយកំណែទម្រង់រឹមជ្ឈការនិងវិសហមជ្ឈការនេះ។បើវាបរាជ័យទៅនោះ ក្រសួងផ្សេងទៀតក៏ពិបាក ព្រោះកំពុងមានអារម្មណ៍មិនចង់ផ្ទេរអំណាចផង ។

បន្ដិចទៀតយើងផ្ទេរវិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យឧស្សាហកម្ម និងសិប្បកម្ម សឹងតែគ្រប់វិស័យ លើកលែងតែក្រសួងការបរទេស និងក្រសួងហិរញ្ញវត្ថុ ។ តែវិស័យហិរញ្ញវត្ថុក៏មានផ្នែកខ្លះដែរ។ ចាំបាច់ធ្វើយ៉ាងម៉េចឲ្យមូលដ្ឋានស្រុក ក្រុង របស់ខ្លួនដែលជាអ្នកទៅទទួល គេយល់អំពីបញ្ហានេះ ហើយចាប់ផ្ដើមធ្វើ។ ដំណាក់កាលនោះប្រាក់ខែរបស់គ្រូត្រូវបើកនៅឯស្រុក ឯការជ្រើសរើសគ្រូបន្ថែម ក៏ស្រុកជាអ្នកទទួលខុសត្រូវក្នុងការជ្រើសរើស គ្រាន់តែការរើសឲ្យស្របតាមលក្ខខណ្ឌដែលក្រសួងបានកំណត់ ។ ក្រោយពីការជ្រើសរើសបានហើយ ក្រសួងអប់រំជាអ្នកយកទៅបណ្ដុះបណ្ដាល ជាគ្រូដែលរស់នៅក្នុងមូលដ្ឋានថ្នាល់តែម្ដង មិនអាចជាគ្រូមកពីស្រុកផ្សេងដូចមុនទៀតឡើយ ចៀសវាងប៉ះពាល់ដល់ការរស់នៅ និងប៉ះពាល់ទៅដល់គុណភាពអប់រំ ។

សម្ដេចក្រឡាហោម **ស ខេង** បានបញ្ជាក់ជាចុងក្រោយថា នេះជារឿងសំខាន់ណាស់ សូមឲ្យបងប្អូនប្រជាពលរដ្ឋគាំទ្រផង ។ នៅប្រទេសរីកចម្រើនបែបប្រជាធិបតេយ្យ ប្រជាជនមានសិទ្ធិសម្រេចកិច្ចការនេះ។ ឥឡូវនេះគេទម្លាក់មកឲ្យ ហើយបើធ្វើមិនកើត កុំបន្ទោសរាជរដ្ឋាភិបាល កុំបន្ទោសរដ្ឋមន្ត្រីក្រសួងអប់រំ ឬក្រសួងនេះ ក្រសួងនោះ។ យើងជាពលរដ្ឋម្នាក់ៗត្រូវចូលរួមតាមកម្រិតដែលយើងអាចចូលរួមបាន ក្នុងការអភិវឌ្ឍ និងកសាងប្រទេស តាមរយៈការអភិវឌ្ឍមូលដ្ឋានរបស់យើងថ្នាល់ ។ កាលណាមូលដ្ឋានយើងអភិវឌ្ឍនោះ ទូទាំងប្រទេសក៏រីកចម្រើនដែរ ។៖

សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញចុះសួរសុខទុក្ខ និងស្វែងយល់ជីវភាពរស់នៅ របស់បងប្អូនជនជាតិអ៊ីស្លាម នៅភូមិ ខ១ និងភូមិ ក សង្កាត់ច្រាំងចំរេះទី ២ ខណ្ឌឫស្សីកែវ

*សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** អញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខបងប្អូនជនជាតិខ្មែរអ៊ីស្លាម រស់នៅភូមិ ខ១ និងភូមិ ក សង្កាត់ច្រាំងចំរេះទី ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ*

ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១៦ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភាអនុប្រធានគណបក្សប្រជាជនកម្ពុជា បានអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខបងប្អូនជនជាតិខ្មែរអ៊ីស្លាមរស់នៅភូមិ ខ១ និងភូមិ ក សង្កាត់ច្រាំងចំរេះទី ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីស្វែងយល់ពីជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ។ តាមរយៈនេះ បានឲ្យសម្តេចដឹងអំពីជីវភាពប្រជាពលរដ្ឋក្នុងភូមិ រស់នៅដោយសុខដុមរមនា មានសាមគ្គីជួយគ្នាទៅវិញទៅមក ដោយគ្មានការរើសអើងអំពីជាតិសាសន៍។ ជីវភាពខាងស្មារតី និងសម្ភារៈ មានបងប្អូនមួយចំនួននៅជួបការលំបាកខាងជីវភាពប្រចាំថ្ងៃដោយរកចំណូលបានតិច ប៉ុន្តែសមាជិកគ្រួសារជាច្រើនដែលចាំបាច់ត្រូវមានការជួយឧបត្ថម្ភគាំទ្រពីអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ សំដៅលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ដោយឡែកអំពីជីវភាពខាងនយោបាយ ប្រជាពលរដ្ឋភាគច្រើនបានអញ្ជើញទៅចុះឈ្មោះបោះឆ្នោតជាបណ្តើរៗ ។ ចំពោះអ្នកដែលមិនទាន់បានទៅចុះឈ្មោះ ក៏បានត្រៀមលក្ខណៈដើម្បីចុះឈ្មោះនៅពេលខាងមុខ ។

មានមតិសំណេះសំណាលនាឱកាសនោះ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសំណូមពរដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ដែលគ្រប់អាយុបោះឆ្នោតសូមរួសរាន់អញ្ជើញទៅចុះឈ្មោះបោះឆ្នោតឲ្យបានគ្រប់ៗគ្នា ព្រោះជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញផង ហើយក៏ជាការអនុវត្តនូវសិទ្ធិជ្រើសរើសសមាជិកក្រុមប្រឹក្សាសង្កាត់ ដែលយើងពេញចិត្ត និងគាំទ្រក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៧ ខាងមុខ ។

សូមគោរពជូនកន្ដ្រម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព

សូមចូលមក Facebook Page : Pracheachun Magazine-ទស្សនាវដ្ដីប្រជាជន

ហើយចុច Like និង Share ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្ដល់ទស្សនៈ ឬ មតិផ្សេងៗ

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តមបណ្ឌិត **ឌួន ញ៉ិល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី ២ រដ្ឋសភា បានផ្ដួចផ្ដើមពិធីដង្ហែរអង្គធ្លា ដើម្បីប្រមូលបច្ច័យកសាងសមិទ្ធផលក្នុងវត្ត ត្រពាំងជ្រៃ ភូមិត្រពាំងជ្រៃ ឃុំបល្ល័ង្ក ស្រុកបាវាយណ៍ ខេត្តកំពង់ធំ ។ ពិធីនេះប្រារព្ធធ្វើឡើងនៅភូមិគ្រឹះឯកឧត្តមបណ្ឌិត ស្ថិតក្នុងភូមិត្រពាំងស្វាយ ឃុំបល្ល័ង្ក ស្រុកបាវាយណ៍ ខេត្តកំពង់ធំ ។ នៅព្រឹកថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០១៦ អង្គធ្លា បានដង្ហែរប្រទក្សិណព្រះវិហារវត្ត ។ បន្ទាប់មក ឯកឧត្តមបណ្ឌិត **ឌួន ញ៉ិល** បានមានប្រសាសន៍បញ្ជាក់ថាបច្ច័យដែលប្រមូលបានពីសប្បុរសជន ទាំងនៅភ្នំពេញ និងខេត្តកំពង់ធំ សរុបចំនួន ២០៣,៥៨១,០០០ រៀល ស្មើនឹង ៤៩៥៩៣,៤២ ដុល្លារសហរដ្ឋអាមេរិក ដើម្បីកសាងអគារសិក្សាមួយខ្នង មាន ៤ បន្ទប់ បុស្ត៍សុខភាព អគារសម្រាប់បុគ្គលិកពេទ្យ និងចាក់សាបទីធ្លាវត្ត ជួសជុលកុដិថ្ម ២ ខ្នង ដែលកន្លងមកមានការខូចខាត តាមសំណើ និងសំណូមពររបស់ពុទ្ធបរិស័ទ និងប្រជាពលរដ្ឋ ។ ឯកឧត្តមបណ្ឌិត **ឌួន ញ៉ិល** បានថ្លែងអំណរគុណ និងជូនពរចំពោះ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

*ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម នាយឧត្តមសេនីយ៍ **ផ្ងៀ ចាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានខេត្តសៀមរាប បានអញ្ជើញជួបសំណេះសំណាល និងផ្ដល់រង្វាន់លើកទឹកចិត្តជូនដល់ក្មួយៗសិស្សានុសិស្ស ដែលបានប្រឡងជាប់មធ្យមសិក្សាបត្រទុតិយភូមិ និទ្ទេស A ចំនួន ៣៦ រូប ក្នុងខេត្តសៀមរាប នាសម័យប្រឡងថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១៦ ដោយក្នុងម្នាក់ទទួលបានម៉ូតូម៉ាក Honda Wave ២០១៦ មួយគ្រឿង មួកសុវត្ថិភាពមួយ ប្រេងសាំង ៥០ លីត្រ ព្រមទាំងធ្វើស្លាកលេខជូនផងដែរ ។*

ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១៦ លោកជំទាវ **ម៉ែន សំអន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រីរាជការនៃមន្ទីរកិច្ចការនារី និងសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តរតនៈគិរី ។ លោកជំទាវក៏បាននាំមកជាមួយនូវការផ្តាំផ្ញើនូវការសួរសុខទុក្ខពីសំណាក់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធិបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ជូនដល់បងប្អូនជាមន្ត្រីរាជការ និងនារីទាំងអស់នៅទូទាំងខេត្ត និងបានថ្លែងនូវការកោតសរសើរចំពោះការខិតខំរបស់បងប្អូន ដែលបានប្រឹងប្រែងក្នុងរយៈពេលកន្លងមក ។ លោកជំទាវក៏បានមានប្រសាសន៍ថា កម្ពុជាបច្ចុប្បន្ន ក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** បាននុវត្តនូវគោលនយោបាយ ឈ្នះ ឈ្នះ ដែលបានប្រែក្លាយប្រទេសពីមានសង្គ្រាមអ៊ុំរ៉ូ មកជាប្រទេសដែលមានការរីកចម្រើន និងការអភិវឌ្ឍលើគ្រប់វិស័យ ហើយបានធ្វើឲ្យប្រជាជាតិទទួលបានសុខសន្តិភាពពេញលេញនៅទូទាំងប្រទេស និងមានការអភិវឌ្ឍលើគ្រប់វិស័យ ។

*ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **ឯក សំអុល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា និងឯកឧត្តម **យីម សៃលី** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានអញ្ជើញជាអធិបតីក្នុងពិធីបើកការព្យាបាលវះកាត់ជំងឺភ្នែកឡើងបាយ ដោយមិនគិតថ្លៃជូនដល់ប្រជាពលរដ្ឋនៅខេត្តកំពង់ចាម ដោយក្រុមគ្រូពេទ្យស្ម័គ្រចិត្តខេត្តហាយណានៃសាធារណរដ្ឋប្រជាមានិតចិន ។*

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៦ លោកជំទាវ **ឃួន សុជារី** សមាជិកគណៈ-អចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា តំណាងរាស្ត្រមណ្ឌលខេត្តកណ្ដាល និងជាតំណាងឲ្យប្រជាពលរដ្ឋរងគ្រោះចំនួន ១៧ ខ្នងផ្ទះ ដែលទទួលរងគ្រោះដោយបាក់ដីច្រាំងទន្លេមេគង្គ រស់នៅក្នុងភូមិពាមរ៉ាង-ក្រោម ឃុំពាមរ៉ាង ស្រុកលើកដែក ខេត្តកណ្ដាល បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលបានចាត់ឲ្យក្រុមការងារ ដឹកនាំដោយលោកជំទាវ **ម៉ែន ណារីសោភ័ក** អគ្គលេខាធិការរងទី ១ ចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ ដែលក្នុង១ គ្រួសារទទួលបាន អង្ករ ៥០ គីឡូក្រាម មី ១ កេស ត្រីខ ១០ កំប៉ុង តង់កៅស៊ូ ១ មុង ១ ភួយ ១ សារុង ១ ក្រមា ១ និងថវិកា ២០ ម៉ឺនរៀល ។ ដើម្បីលើកទឹកចិត្ត និងអរគុណដល់ ក្រុមយុវជនកាកបាទ-ក្រហម យុវជន ស.ស.យ.ក ចំនួន ៦៧ នាក់ និងអាជ្ញាធរមូលដ្ឋាន ១៧ នាក់ ដែលបានចូលរួមជួយជញ្ជូនសម្ភារៈពីផ្ទះប្រជាពលរដ្ឋរងគ្រោះ ត្រូវបានឧបត្ថម្ភ ក្នុងម្នាក់ៗ ថវិកា ២ ម៉ឺនរៀល ។ ដោយឡែកអ៊ុំចាស់ៗ ចំនួន ១៣ នាក់ ក្នុងម្នាក់ៗ ថវិកា ២ ម៉ឺនរៀល ផងដែរ ។

ថ្ងៃទី ១៧ កញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **ជា សុផារ៉ា** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍តំបន់ឆ្នេរ និងឯកឧត្តម **ថោង ខុន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានដឹកនាំក្រុមមន្ត្រីជំនាញចុះពិនិត្យទីតាំងសាងសង់កំពង់ផែទេសចរណ៍ និងតំបន់ត្រៀមបំរុងអភិវឌ្ឍទីក្រុងកំពតថ្មី ។

*ថ្ងៃ ១៥ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អគ្គលេខាធិការសមាគម ស អ ក បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខសមាជិកសមាគមអតីតយុទ្ធជនកម្ពុជាស្រុកបាទី ខេត្តតាកែវ ចំនួន ៣២០ នាក់ ដោយបាននាំយកអំណោយរបស់សម្ដេចតេជោ ប្រធានសមាគម ជូនចំពោះបងប្អូន ក្នុងម្នាក់ៗ ទទួលបាន មី ១ កេស ត្រីខកំប៉ុង ១ យូរ អង្ករ ២៥ គក្រ ថវិកា ៤ ម៉ឺនរៀល ។ ស្ដៀតឱកាសនោះ ឯកឧត្តមក៏បានអញ្ជើញពិនិត្យសកម្មភាពសាងសង់ផ្ទះដែលជាអំណោយរបស់សម្ដេចតេជោ ជូនចំពោះគ្រួសារអតីតយុទ្ធជន លោកសែម ធីដែលជាជនពិការ នៅឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។*

*ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **អូន ព័ន្ធមុនីរ៉ែត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអញ្ជើញជាអធិបតីក្នុងពិធីកាត់ខ្សែបូសម្ពោធដាក់ឲ្យប្រើប្រាស់ផ្លូវគ្រួសក្រហម ១ ខ្សែ និងបើកការដ្ឋានសាងសង់ផ្លូវក្រាលគ្រួសក្រហមចំនួន ២ ខ្សែ បន្ថែមទៀតសរុបប្រវែង ១៨.៤៩៤ ម៉ែត្រ ព្រមទាំងផ្ដល់រង្វាន់លើកទឹកចិត្តដល់សិស្សនិទ្ទេស A នៅក្នុងស្រុកខ្សាច់-កណ្ដាល និងស្រុកស្វាយរៀង ខេត្តកណ្ដាល ។*

ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **ស៊ុន ចាន់ថុល** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឯកឧត្តមបណ្ឌិត **ឃឹម ប៊ុនសុង** សមាជិកគណៈ កម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងឯកឧត្តម **ឌូ ផណ្ណា** ប្រធានក្រុមប្រឹក្សាខេត្ត ព្រមទាំងមន្ត្រីរាជការ អាជ្ញាធរក្រុងសៀមរាប បានចូលរួមក្នុងធ្វើពិធីក្រុងពាលីដើម្បីកសាងស្ពានថ្មីចំនួនពីរកន្លែងនៅកណ្ដាលក្រុងសៀមរាប គឺស្ពានថ្មីព្រះរាជដំណាក់ និងស្ពានវត្តពោធិលង្កា ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **ទាង សូត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ប្រធានក្រុមការងារចុះស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ និងលោក ជំទាវ ឋានអញ្ជើញជួបសំណេះសំណាលជាមួយសិស្សានុសិស្សដែលទីបបុរឡងជាប់សញ្ញាបត្ររមធ្យមសិក្សា-បត្រទុតិយភូមិឆ្នាំ ២០១៥-២០១៦ និងពិធីប្រកួតបាល់ទាត់មិត្តភាពរវាងស្រុកពញាក្រែក មេមត់ និងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។ ក្នុងឱកាសនោះ ឯកឧត្តម **ទាង សូត** បានឧបត្ថម្ភសម្ភារកីឡា និងថវិកាជូនដល់សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ កីឡាករ និងប្រជាពលរដ្ឋ ។ ដោយឡែក សិស្សានុសិស្សដែលប្រឡងជាប់សញ្ញាបត្ររមធ្យមសិក្សាបត្រទុតិយភូមិ ឆ្នាំ ២០១៥-២០១៦ មកពីស្រុកពញាក្រែក និងស្រុកកំចាយមារ ដែលទទួលបាននិទ្ទេស A ចំនួន ៣៧១ នាក់ ក្នុងម្នាក់ៗទទួលបាន ម៉ូតូ ១ គ្រឿង និងថវិកាមួយចំនួន ។

*ថ្ងៃទី១៤ខែកញ្ញាឆ្នាំ២០១៦លោកជំទាវ**ហានសំអាន**សមាជិកាគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មការទី ៨ នៃព្រឹទ្ធសភា និងឯកឧត្តម **ធីម ផន** សមាជិកគណៈកម្មការទី ៩ នៃព្រឹទ្ធសភា អមដំណើរដោយលោក ម៉ូននី បណ្ឌិត អភិបាលស្រុកស៊ីធរកណ្ដាល បានអញ្ជើញចុះពិនិត្យការដ្ឋានសាងសង់ផ្លូវលំក្រាលគ្រួសក្រហមមួយខ្សែមានទទឹងប្រវែង ០៨ ម៉ែត្រ បណ្ដោយប្រវែង ៣៥៥០ ម៉ែត្រ ស្ថាបនាដោយកងវិស្វកម្ម ក្រុមហ៊ុន សារ៉ាណេ ឆ្លងកាត់ភូមិកោងស្រែ ភូមិព្រំមុន្នី និងភូមិកោងទន្លេលើ នៅឃុំល្ង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ។*

ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តមនាយឧត្តមសេនីយ៍ **អ៊ុ ឈាន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋលេខាធិការក្រសួងការពារជាតិ ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាលចុះខេត្តប៉ៃលិន បានអញ្ជើញជួបសួរសុខទុក្ខ និងបំពាក់ឯកសណ្ឋាន និងវិទ្យុទាក់ទងជូនប្រជាការពារភូមិអ្ករខ្ជីង សង្កាត់អ្ករតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន ចំនួន ១៨ នាក់ ។

*ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មការទី ៣ នៃព្រឹទ្ធសភា ក្រោយបានជួបសំណេះសំណាលនឹងទទួលយកសំណើរបស់ប្រជាជនសុំឲ្យជួយជួសជុល និងកែលម្អផ្លូវលំប្រវែងជាង ៣.០០០ ម៉ែត្រ ដែលតភ្ជាប់ពីភូមិសំរោង លើងភ្នំឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឆ្ពោះទៅកាន់ភ្នំសែនដី កាលពីថ្ងៃទី ៩ ខែសីហាឆ្នាំ ២០១៦ រួចមក ឯកឧត្តមបានបញ្ជូនក្រុមគ្រឿងចក្រឲ្យទៅធ្វើការជួសជុលជូនតាមសំណើរបស់ប្រជាជន ។*

ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១៦ នៅបុរីវប្បធម៌កោះសំពៅមាស ខេត្តពោធិ៍សាត់ ឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា និងលោកស្រី Anne Lemaistre ប្រធានអង្គការយូណេស្កូប្រចាំនៅកម្ពុជា ព្រមទាំងវត្តមានចូលរួមពីឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំ លោក លោកស្រីជាបុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សយ៉ាងច្រើនកុះករបានចូលរួមប្រារព្ធពិធីអបអរសាទរទិវាអក្ខរកម្មជាតិ-អន្តរជាតិ ៨ កញ្ញា លើកទី១៦ ក្រោមប្រធានបទ "អក្ខរកម្មជួយបង្កើនសេដ្ឋកិច្ចគ្រួសារ" ។

*ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **ម៉ម ប៊ុនធាង** ប្រធានស្តីទីគណៈកម្មការទី ១០ ព្រឹទ្ធសភា និងជាសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី ៣ (ខេត្តកណ្ដាល) បានអញ្ជើញជាអធិបតីភាពក្នុងពិធីបញ្ចុះបឋមសិលាសាងសង់សាលាធម្មសភា ១ ខ្នង នៅវត្តក្រូចសើច ស្ថិតក្នុងឃុំទ្រា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។*

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ព្រឹកថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **អ៊ុន ចាន់ដា** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ បានអញ្ជើញដោះស្រាយជម្លោះដែលកំពុងកើតឡើង និង ណែនាំលើការកំណត់ដែនរដ្ឋបាលស្រុកត្បែងមានជ័យ និងដែនរដ្ឋបាលស្រុកឆែប ដល់ប្រជាពលរដ្ឋទាំងពីរស្រុក ដោយមានការអញ្ជើញចូលរួមពីមេបញ្ជាការអាវុធហត្ថខេត្ត លោកអភិបាលស្រុកឆែប និងស្រុកត្បែងមាន-ជ័យ និងប្រជាពលរដ្ឋដែលមានជម្លោះទាំងពីរស្រុក ។

*ថ្ងៃទី៧ខែកញ្ញាឆ្នាំ២០១៦ឯកឧត្តម**ប៉ាសុជាតិវង្ស**សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានអញ្ជើញចូលរួមក្នុងវេទិកាសាធារណៈជាមួយបងប្អូនរស់នៅសហគមន៍បឹងកក់ រួមទាំងបងប្អូនសាសនិកនៃព្រះវិហារអិស្លាមបឹងកក់ ដែលក្នុងកម្មវិធីនេះមានបងប្អូនជាច្រើនបានគាំទ្រឲ្យមានការអភិវឌ្ឍក្នុងសហគមន៍ខ្លួន ។ វេទិកាសាធារណៈបានពិភាក្សាឯកភាពលើចំណុចសំខាន់ៗមួយចំនួនមាន ១-ឯកភាពរៀបចំប្រព័ន្ធផ្លូវ-លូ ដើម្បីតភ្ជាប់ទៅតំបន់ផ្សេងៗទៀត ២-ឯកភាពរៀបចំឡើងវិញប្រព័ន្ធរចនាសម្ព័ន្ធសំណង់នានាឲ្យមានរបៀបរៀបរយត្រឹមត្រូវ ៣-ឯកភាពបង្កើតគណៈកម្មការតំណាងមួយដោយសហការជាមួយក្រុមការងារបច្ចេកទេសរបស់រដ្ឋបាលរាជធានីភ្នំពេញ ដើម្បីធ្វើការអភិវឌ្ឍសហគមន៍ ហើយរដ្ឋបាលរាជធានីភ្នំពេញនានាទទួលខុសត្រូវរៀបចំជូនសហគមន៍នូវប្រព័ន្ធផ្លូវ ប្រព័ន្ធលូ ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធអគ្គិសនី ។*

ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **ហ៊ៅ ធនិន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ និងជាអនុប្រធានគណៈកម្មាធិការគណបក្សខេត្ត បាននាំយកគ្រឿងឧបភោគបរិភោគរបស់ក្រុមការងារចុះជួយស្រុកក្រគរ ចែកជូនដល់ដែប្រជានេសាទក្នុងភូមិកំពង់ប្រាក់ ចំនួន ៦៦ គ្រួសារ សម្រាប់ជាស្បៀងទប់ទល់ក្នុងរដូវបិទនេសាទ ។ ពិធីនេះប្រារព្ធធ្វើឡើងក្នុងសាលាបុណ្យបណ្ដែតទឹក(លើផ្ទៃទឹកបឹងទន្លេសាប)ស្ថិតក្នុងភូមិកំពង់ប្រាក់ ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមបណ្ឌិត **ជ្រាំង ជលសា** អគ្គនាយករងអគ្គិសនីកម្ពុជា និងជាប្រធានក្រុមការងារចុះឃុំស្នាអន្សា អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋជាច្រើននាក់ផងដែរ ដោយក្នុងមួយគ្រួសារទទួល បានអង្ករ ២៥ គីឡូក្រាម, ធុងបណ្ដែតទឹក ២ ធុង, សៀង ២ គីឡូក្រាម, ឆៃប៉ូវ ២ គីឡូក្រាម, ទឹកត្រី ៣ ដប, ទឹកស៊ីអ៊ីវ ៣ ដប, ប្រេងឆា ១ ដប, ប្រេងកូឡា ១ ខ្ងង, ថ្នាំវាគ ២ បន្ទះ និងសាវុង ១ ។ ព្រមទាំងបានបន្ដចុះទៅពិនិត្យស្ពានសាមគ្គីក្រគរ បន្ដពិនិត្យទំនប់ស្ដាក់ទឹកដំណាក់ក្រាញ់ ព្រមទាំងចំការស្រកានាគ ដែលស្ថិតក្នុងភូមិអន្សាក្ដាម ឃុំ ស្នាអន្សា ស្រុកក្រគរផងដែរ ។

*ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **ហ៊ៅ ឥន្ទ្រា** អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល បានអញ្ជើញជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងជូនរង្វាន់សិស្សជ័យលាភីប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបត្រទុតិយភូមិ ចំនួន ៦៨០ នាក់ ក្នុងក្រុងតាខ្មៅ នាសម័យប្រឡងថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១៦ ដែលក្នុងឱកាសនោះ ឯកឧត្តម **ហ៊ៅ ឥន្ទ្រា** បានឧបត្ថម្ភលោកគ្រូ អ្នកគ្រូចំនួន ១២៥ នាក់ ក្នុងម្នាក់ៗទទួលបានថវិកាចំនួន ១០ ម៉ឺនរៀល ។ សិស្សជ័យលាភីចំនួន ៦៨០ នាក់ ក្នុងម្នាក់ៗទទួលបានថវិកាចំនួន ១០ ម៉ឺនរៀល ។ សិស្សនិទ្ទេស A ចំនួន ១២ នាក់ ក្នុងម្នាក់ៗទទួលបាន ម៉ូតូ Zoomer X ស៊ីរី ២០១៧ ក្នុងម្នាក់ៗ ០១ គ្រឿង ។ គួរបញ្ជាក់ថា ក្នុងសម័យប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា ២០១៥-២០១៦ នេះ ក្រុងតាខ្មៅ បេក្ខជនមកប្រឡងចំនួន ១០៤៦ នាក់ ប្រឡងជាប់ចំនួន ៦៨០ នាក់ ស្មើ ៦៥% កើន ៧,៩៨% ក្នុងនោះ និទ្ទេស A ចំនួន ១២ នាក់ (មកពីវិទ្យាល័យ **ហ៊ុន សែន** សេរីភាពចំនួន ១០ នាក់ និងសាលារៀនសុវណ្ណភូមិ ០២ នាក់) និទ្ទេស B ចំនួន ៣៧ នាក់ និទ្ទេស C ៦១ នាក់ និទ្ទេស D ចំនួន ៨៣ នាក់ និងនិទ្ទេស E ចំនួន ៤៨៧ នាក់ ។*

ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៦ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជា-ជនកម្ពុជា ប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្ដេចតេជោ និងមានការចូលរួមពីអាជ្ញាធរខេត្ត ស្រុក ក្រុមការងារសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្ដេចតេជោ អង្គការ Kotra យុវជន បានដឹកនាំគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្ដេចតេជោទៅពិនិត្យព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋចំនួន ៣៧៦៧ នាក់ នៅក្នុងខេត្តកំពង់ធំ ។ ការពិនិត្យ និងព្យាបាលជំងឺនេះធ្វើឡើងក្នុងភូមិទីពោ ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ ។

*ថ្ងៃទី១០ខែកញ្ញាឆ្នាំ២០១៦ឯកឧត្តម**ផៃ ប៊ុនឈឿន**សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋលេខាធិការក្រសួងបរិស្ថាន បានដឹកនាំគណៈប្រតិភូបំពេញបេសកកម្មនៅតំបន់ការពារធម្មជាតិ ដើម្បីពិនិត្យលើការការពារ និងអភិរក្សធនធានធម្មជាតិ ក្នុងភូមិសាស្ត្រស្រុកវាលវែង ខេត្តពោធិ៍សាត់ ។*

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តម **ជា ចាន់ឌូ** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះជួយស្រុកសន្ទុក បានចូលរួមជាអធិបតីក្នុងពិធីចិទវគ្គអប់រំនយោបាយ ជូនដល់សកម្មជនយុវជនស្រុកសន្ទុក ចំនួន ១០១ នាក់ ពីលើជួរសកម្មជនយុវជនដែលបានទទួលបណ្ដុះបណ្ដាលរួចហើយ ចំនួន៦៥០នាក់ ក្នុងទូទាំងស្រុក ។

*នាស្នាក់ការកណ្ដាលគណបក្ស នៅថ្ងៃទី១០ខែកញ្ញា ឆ្នាំ២០១៦ ដោយមានការគាំទ្រពីគណៈកម្មាធិការគណបក្សក្រសួង ក្រុមសកម្មជនយុវជនគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយលោក **ច័យ រ៉ិចត្ត** ប្រធានក្រុមសកម្មជនយុវជនគណបក្សក្រសួង បានរៀបចំវគ្គអប់រំនយោបាយជូនសមាជិក-សមាជិកាសកម្មយុវជនគណបក្សក្រសួង ចំនួន ១០០នាក់ ក្រោមអធិបតីភាពឯកឧត្តម **អ៊ីច ចូរិទ្ធ** សមាជិកគណៈកម្មាធិការកណ្ដាល និងជាអនុប្រធានគណៈកម្មាធិការគណបក្សក្រសួង និងឯកឧត្តម **ពាក់ ស៊ីនអ៊ី** សមាជិកគណៈ-កម្មាធិការកណ្ដាលប្រធានគណៈយោសនាអប់រំគណៈកម្មាធិការកណ្ដាលខេត្តសនាមពីឯកសារស្ដីពីប្រវត្តិសកម្មភាពស្នាដៃគណបក្ស និងឯកឧត្តម **សោមសឿន**សមាជិកគណៈកម្មាធិការកណ្ដាលប្រធានគណៈចាត់តាំង នៃគណៈកម្មាធិការកណ្ដាលខេត្តសនាម ឯកសារលក្ខន្តិកៈគណបក្ស ។*

នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តម **ជាម ច័ន្ទសោភ័ណ** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្ស សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងជាប្រធានក្រុមការ-ងារយុវជនគណបក្សខេត្តព្រមទាំងសមាជិក សមាជិកាគណបក្សខេត្ត បានអញ្ជើញចូលរួមក្នុងពិធីប្រកាសកែសម្រួលបំពេញបន្ថែម សមាសភាពក្រុមការងារយុវជនគណបក្សស្រុក រតន-មណ្ឌល និងនៅស្រុក ឯកភ្នំ ចំនួន ៣៣រូប នៅទីស្នាក់ការគណបក្សស្រុក ។

នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៦ លោកជំទាវ **ពុប ម៉ារីយ៉ាស** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល ប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយឃុំឈូកស និងឯកឧត្តម **ញាណ ឡេង** ប្រធានក្រុមការងារចុះជួយស្រុក បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំត្រីមាស និងមានមតិសំណេះសំណាលជាមួយក្រុមសកម្មជនយុវជនឃុំ សំដៅលើកកម្ពស់បន្តការសិក្សា ពង្រឹងសមត្ថភាពខ្លួន ជៀសផុតពីគ្រឿងញៀន និងរំឭកពីការចុះឈ្មោះបោះឆ្នោតផងដែរ ដែលមានសមាជិក សមាជិកា ចូលរួមចំនួន ១១០រូប ។

នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តម **កែ ប៊ុនខៀង** សមាជិកគណៈកម្មាធិការកណ្ដាល និងជាប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល បានអញ្ជើញចូលរួមក្នុងពិធីប្រកាសប្រធានក្រុមការងារយុវជនគណបក្ស ស្រុក-ឃុំ ក្នុងគណៈអចិន្ត្រៃយ៍គណបក្ស និងចូលរួមចិទវគ្គអប់រំនយោបាយសម្រាប់ក្រុមការងារយុវជនគណបក្សស្រុក សកម្មជនយុវជនគណបក្ស ឃុំ-ភូមិ នៅទីស្នាក់ការគណបក្សស្រុកអង្គរធំ ក្រោមអធិបតីភាព ឯកឧត្តម ឈឹម ម៉ា អ្នកតំណាងរាស្ត្រខេត្តសៀមរាបឯកឧត្តម កៅ សោភ័ណ ប្រធានយោសនាអប់រំខេត្ត ដែលមានសិក្ខាកាមចូលរួមបណ្ដុះបណ្ដាលចំនួន ១៣៥នាក់ ។ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦បានចូលរួមក្នុងពិធីប្រកាសប្រធានក្រុមការងារយុវជនគណបក្ស ស្រុក-ឃុំ ក្នុងសមាជិកគណៈអចិន្ត្រៃយ៍គណបក្សស្រុក-ឃុំ និងបើកវគ្គអប់រំនយោបាយសម្រាប់ក្រុមការងារយុវជនគណបក្សស្រុក សកម្មជនយុវជនគណបក្ស ឃុំ-ភូមិ នៅស្រុកវ៉ាមិន ដែលមានសិក្ខាកាមសរុប ចំនួន ១៩៥នាក់ ស្ត្រី ៦២នាក់។

*នៅទី១៨ ខែកញ្ញា ឆ្នាំ២០១៦ ពិធីប្រកាសសេចក្ដីសម្រេចទទួលស្គាល់ក្រុមវាក្ខិនយុវជនគណបក្សឃុំ សង្កាត់ មន្ទីរ អង្គភាព នៃខេត្តព្រៃវែង ក្រោមអធិបតីភាព ឯកឧត្តម **ស សុខា** សមាជិកគណៈកម្មាធិការកណ្ដាល និងជាតំណាងរាស្ត្រមណ្ឌលព្រៃវែង ។*

*ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៦ ក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាលដឹកនាំដោយឯកឧត្តម **យស ជានីឦ** និងលោក **គង់ ឫ៉ា** សហការជាមួយក្រុមការងារយុវជនគណបក្សរាជ-ធានី-ខណ្ឌ បានបើកវគ្គអប់រំនយោបាយជូនសកម្មជនយុវជនគណបក្សភូមិទាំង៤៩ ក្នុងសង្កាត់ទាំង៨របស់ខណ្ឌចតុមុខ ចំនួន១០០នាក់ ក្រោមអធិបតីភាព លោកជំទាវ **ខ្ចោក ខេង** តំណាងរាស្ត្រមណ្ឌលភ្នំពេញ និងជាប្រធានក្រុមការងារថ្នាក់កណ្ដាលចុះពង្រឹងខណ្ឌចតុមុខ និងគណៈកម្មាធិការគណបក្សខណ្ឌ ដែលមានការធ្វើបទឧទ្ទេសនាមដោយ ឯកឧត្តម **ឧយ ស៊ីដាន់** និងឯកឧត្តម **ឆ្លូច រ៉ែងស្ម៊ីន** ។*

*ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៦ ពិធីប្រកាសគណៈកម្មាធិការសាខាគណបក្សប្រចាំរដ្ឋមីនីសូតា សហរដ្ឋអាមេរិក ក្រោមអធិបតីភាព ឯកឧត្តម **ជុំ ប៊ុនរ៉ុង** ប្រធានគណៈកម្មាធិការគណ-បក្សប្រចាំនៅសហរដ្ឋអាមេរិក និងឯកឧត្តម **ចាយ ចូរិន** សមាជិកគណៈកម្មាធិការកណ្ដាលអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម និងជាសមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាលអនុប្រធានក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅសហរដ្ឋអាមេរិក ។*

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តម **ពុន សារពេជ្រ** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្ត បានដឹកនាំ ក្រុមការងារយុវជនគណបក្សខេត្ត ប្រធានក្រុមការងារយុវជនក្រុង-ស្រុក ចូលរួមកិច្ចប្រជុំជាមួយប្រធានគណៈកម្មាធិការគណបក្សខេត្តក្រុង-ស្រុក ដើម្បីជំរុញការធ្វើបច្ចុប្បន្នភាពច្បាស់លាស់ និងប្រកាសគណៈចលនាយុវជន ព្រមទាំងកំណែទម្រង់មួយចំនួនរបស់ក្រុមការងារយុវជនខេត្តកំពត និងបានប្រជុំពិភាក្សាគ្នារកចំណុចល្អ ដើម្បីទទួលបានប្រសិទ្ធភាពការងារដោយជោគជ័យ ។

ថ្ងៃទី០៤ដល់ទី១៧ ខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តម **ពៅ ប៉ូលីណែល** សមាជិកក្រុមការងារយុវជនបក្សថ្នាក់កណ្ដាល និងជាអនុប្រធានក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ និងឯកឧត្តម **មាស សុកំណូ** ប្រធានក្រុមចល័ត នៃក្រុមការងាររៀបចំអង្គការចាត់តាំងយុវជននៅប្រទេសអូស្ត្រាលី និងណូវ៉ែលហ្សេឡង់ បានចូលរួមជាវាគ្មិនធ្វើបទឧទ្ទេសនាមក្នុងវគ្គអប់រំនយោបាយដល់ក្រុមការងារយុវជនប្រចាំទីក្រុង កេស៍ប៊ិច,Melbourne, Sydney, Canberra, Adelaide, Brisbane ប្រទេសអូស្ត្រាលី និងទីក្រុង Hamilton,Auckland,Wellington, Palmerstone North ប្រទេសណូវ៉ែលហ្សេឡង់ លើប្រធានបទ ប្រវត្តិ សកម្មភាព ស្នាដៃ និងបទពិសោធន៍របស់គណបក្សពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស ។

ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៦ ឯកឧត្តម **ព្រុន ថេរ៉ាវ៉ាត** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល អនុប្រធានក្រុមការងារស្រុក ល្វាឯម និងជាប្រធានក្រុមការងារចុះជួយឃុំ កោះកែវ និងសហការី បានចុះតាមខ្នងផ្ទះប្រជាពលរដ្ឋ ធ្វើការបោះឆ្នោតស្វាបស្ងង់សមាសភាពក្រុមប្រឹក្សាឃុំ នីតិកាលទី៨ ដោយបានសហការជាមួយលោកអភិបាលស្រុក ប្រធានក្រុមប្រឹក្សាស្រុក ប្រជាការពារ និងសកម្មជនឃុំ ។

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តម **ស្រី សុភ័ក្ត្រ** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារយុវជនខេត្តកំពង់ចាម បានបើកវគ្គបណ្តុះបណ្តាលបំប៉នលើការពង្រឹងសមត្ថភាព ជូនដល់ក្រុមសកម្មជនយុវជនគណបក្ស នៅស្រុកចំការលើ ក្រោមការឧបត្ថម្ភគាំទ្ររបស់ ឯកឧត្តម **ហ្ជូ ហាក់** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល ប្រធានក្រុមយុវជនបង្គោលស្រុកចំការលើ ។

នៅយប់ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៦ សហគមន៍សង្ការីខ្មែរ-បារាំង GFC PHARMA និងសហគមន៍សង្ការីខ្មែរ-បារាំង រួមសហការជាមួយក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រចាំទ្វីបអឺរ៉ុប បានរួមគ្នាបង្កើតកម្មវិធីសប្បុរសធម៌ភ្លេងត្រី **រ៉ង់ដេវូ** នៅសណ្ឋាគារ **សុខា** ភ្នំពេញ ដើម្បីស្វែងរកថវិកាឧបត្ថម្ភជួយដល់មូលនិធិមន្ទីរពេទ្យ គន្ធបុប្ផា បានទឹកប្រាក់ចំនួន ៩២,៦២២ $ ។

*ព្រឹកថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៦ ឯកឧត្តម **ស្ងួន ឋារ** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល អនុប្រធានគណបក្សខេត្ត និងជាប្រធានក្រុមការងារយុវជនខេត្ត ឯកឧត្តម **ឡាយ គឹមលី** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកការងារយុវជនគណបក្សថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារចុះជួយស្រុក ភ្នំស្រុក បានចុះជួបសំណេះសំណាល វេទិកាថ្នាក់ដឹកនាំគណបក្សស្តាប់យុវជននិយាយ និងអប់រំផ្សព្វផ្សាយ ប្រវត្តិសង្ខេបគណបក្ស សភាពការណ៍បច្ចុប្បន្ន និងការកិច្ចចំពោះមុខដែលមានសមាជិកចូលរួមសរុប 412 នាក់ ស្រី 112 នាក់។*

*ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៦ ឯកឧត្តម **ងិន ចាណាល់** ប្រធានក្រុមការងារយុវជនគណបក្សខេត្ត បានរៀបចំវេទិកាថ្នាក់ដឹកនាំស្តាប់យុវជននិយាយនៅស្រុក កំចាយមារ ខេត្តព្រៃវែង ដោយមានការចូលរួមពីសកម្មជនយុវជនគណបក្សឃុំ និងវាគ្មិនយុវជនគណបក្ស ។*

*នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៦ ឯកឧត្តម **ស្វាយ សំអ៊ាង** ប្រធានគណបក្សខេត្ত ប្រធានគណៈចលនាយុវជន និងជាអភិបាលខេត្តមណ្ឌលគិរី បានអញ្ជើញចូលរួមជាអធិបតីភាពក្នុងពិធីប្រកាសទទួលស្គាល់ សកម្មជនយុវជនគណបក្សឃុំ ក្រងគោ: ស្រុក ពេជ្រដា ចំនួន ២៦៤-នាក់ ស្រី ១២៥នាក់ ។*

ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦ ក្រុមការងារយុវជនបក្សខេត្តព្រៃវែង បានអនុវត្តតាមផែនការសកម្មភាពដែលបានអនុម័ត ចាប់ផ្តើមធ្វើការចុះពង្រឹងសកម្មជនយុវជននិងវាគ្មិនតាមឃុំ បាន ៤ ឃុំ ក្នុងស្រុក កំពង់ត្រាំបែក និង ៤ឃុំ ទៀតក្នុងស្រុក ចាភ្នំ ដោយធ្វើសកម្មភាពនេះបន្តរហូតដល់គ្រប់ទាំង ១១៦ឃុំ ។

លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

ចំណូលពន្ធដារខែសីហា

អគ្គនាយកពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឲ្យដឹងថា កាលពីខែសីហាកន្លងទៅនេះ ពន្ធដារប្រមូលចំណូលបានប្រមាណជាង ៤៨៣ ពាន់លានរៀល គិតជាដុល្លារជិត ១២១ លានដុល្លារអាមេរិក ។ សម្រាប់រយៈពេល ៨ ខែឆ្នាំនេះ ចំណូលពន្ធសរុបដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានមានចំនួន ៤៣០៣,៧៩ ពាន់លានរៀល ឬប្រមាណ ១០៧៥,៩ លានដុល្លារ ស្មើនឹង ៧៥,៦៩% នៃគោលដៅដែលកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ។

ក្នុងរយៈពេលដូចគ្នានេះដែរមានការកត់សម្គាល់ឃើញថា មានការកើនឡើងផងដែរនូវចំណូលពន្ធអាករតាមប្រភេទពន្ធសំខាន់ៗមួយចំនួន ដូចជាពន្ធលើប្រាក់ចំណេញកើនឡើងប្រមាណ ២២,៦% ,ពន្ធលើប្រាក់បៀវត្សរ៍កើនប្រមាណ ២៥,៨% ,អាករលើតម្លៃបន្ថែម កើនប្រមាណ ២១,៩% និងអាករពិសេសមានការកើនឡើងប្រមាណ ២២,១%។ ចំណែកឯចំណូលពន្ធតាមសកម្មភាពអាជីវកម្ម ក៏មានការកើនឡើងស្ទើរតែទាំងអស់ ។

ទេសចរណ៍រយៈពេល ៧ ខែ

រយៈ ៧ ខែ ឆ្នាំ ២០១៦ នេះ ភ្ញៀវទេសចរអន្តរជាតិដែលមកទស្សនាកម្ពុជាមានចំនួនជាង ២,៧ លាននាក់ គឺកើនឡើងប្រមាណ ៣,៤% បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៥ ។

ពិនិត្យស្ថានភាពចរន្តឆ្លងកាត់របស់ភ្ញៀវទេសចរចូលមកកម្ពុជា ពុំមានអ្វីជាឧបសគ្គនោះទ ហើយករណីផ្ទុះជំងឺហ្សីកានៅប្រទេសថៃ និងប្រទេសសិង្ហបូរី ក៏មិនជះឥទ្ធិពលដល់ភ្ញៀវចូលមកកម្ពុជាដែរ ។ ក្នុងរយៈពេលនេះ ភ្ញៀវវៀតណាមនៅតែជាទីផ្សារទេសចរណ៍លំដាប់លេខ ១ ក្នុងចំណោមទីផ្សារទេសចរណ៍ធំៗ ១០ ដែលមកកម្ពុជា ភ្ញៀវចិនឈរនៅលំដាប់ទី ២ កូរ៉េខាងត្បូងនៅលំដាប់ទី ៣ ។

ការវិនិយោគរបស់ជប៉ុន

យោងតាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) គម្រោងវិនិយោគនៃក្រុមហ៊ុនជប៉ុននៅកម្ពុជា ដែលត្រូវបានទទួលស្គាល់ចាប់ពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០១៥ មានទឹកប្រាក់ ៨០១ លានដុល្លារអាមេ-រិក ។ ការនាំចូលពីជប៉ុនមកកម្ពុជាកើនពីចំនួន ១៥៨ លានដុល្លារអាមេរិកនៅឆ្នាំ ២០១០ មក ៣០២ លានដុល្លារនៅឆ្នាំ ២០១៥ ។ រីឯការនាំចេញពីកម្ពុជាទៅជប៉ុនកើនពី ២០៨ លានដុល្លារនៅឆ្នាំ ២០១០ ទៅ ៩៦៨ លានដុល្លារនៅឆ្នាំ ២០១៥ ។

កាលពីថ្ងៃទី ១ ខែកញ្ញា កន្លងទៅ ក្រុមហ៊ុនអាកាសចរណ៍ជប៉ុន ANA បានចាប់ផ្ដើមហោះហើរជាលើកដំបូងបំផុត តូក្យូ-ភ្នំពេញ ។ គេរំពឹងថាចំនួនវិនិយោគិន និងអ្នកទេសចរជប៉ុននឹងមានចំនួនកើនឡើងថែមទៀត។ នៅពេលនេះទេសចរជប៉ុនបានស្ថិតនៅលំដាប់ទី ៧ ក្នុងចំណោមទីផ្សារទេសចរណ៍ធំៗទាំង ១០ របស់កម្ពុជា ។

វិស័យសំណង់រយៈពេល ៨ ខែ

របាយការណ៍របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានឲ្យដឹងថា រយៈពេល ៨ ខែឆ្នាំ ២០១៦ ការវិនិយោគលើវិស័យសំណង់ មាន ១ ៧៥៣ គំរោង,ផ្ទៃក្រឡាសំណង់សរុប ១១.៤៣២.៥១២ ម៉ែត្រក្រ-ឡា និងមានតម្លៃប៉ាន់ស្មាន ៧.២១៨,១៧៧ ដុល្លារអាមេរិក ។ តួលេខនេះ បើប្រៀបធៀបនឹងរយៈពេល ៨ ខែ ដូចគ្នានាឆ្នាំ ២០១៥ មានការកើនឡើង ៤០៤.៣៤% ។

មកដល់រយៈពេលនេះ នៅទូទាំងប្រទេសមានសំណង់អគារខ្ពស់ចាប់ពី ៥ ជាន់ឡើងទៅមានចំនួន ៧៤២ អគារ ។ ដោយឡែកនៅរាជធានីភ្នំពេញ មានសំណង់អគារខ្ពស់ចាប់ពី ៥ ជាន់ឡើងទៅមានចំនួនសរុប ៦២៨ អគារ ។

បើគិតចាប់ពីឆ្នាំ ២០០៣ មកដល់ពេលនេះ នៅទូទាំងប្រទេសមានទីក្រុងរណបបុរីលំនៅឋាន និងលំនៅឋានមានលក្ខណៈបុរីសរុបចំនួន ១៤៦ ទីតាំង ។ ដោយឡែក នៅរាជធានីភ្នំពេញមានទីក្រុងរណបបុរីលំនៅឋាន និងលំនៅឋានមានលក្ខណៈបុរីសរុបចំនួន ១៣៤ ទីតាំង ។

ទំហំពាណិជ្ជកម្ម កម្ពុជា ចិន

ទំហំសេដ្ឋកិច្ចសរុបរវាងប្រទេសទាំងពីរ កម្ពុជា-ចិន មានចំនួនប្រហែល ៤,៤ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៥ ។ ប្រទេសចិនបាននាំទំនិញចូលមកកម្ពុជាមានទំហំទឹកប្រាក់សរុប ៣,៧ ពាន់លានដុល្លារ និងកម្ពុជានាំចូលទៅកាន់ប្រទេសចិនមានទំហំទឹកប្រាក់ ៦៦៦,២ លានដុល្លារ ។ ទំហំសេដ្ឋកិច្ចរវាងប្រទេសទាំងពីរត្រូវបានរំពឹងថានឹងកើនឡើងរហូតដល់ ៥ ពាន់លានដុល្លារនៅឆ្នាំ ២០១៧ ខាងមុខ ។

ការនាំអង្ករចេញ

យោងតាមស្ថិតិនៃរបាយការណ៍នាំចេញអង្ករកម្ពុជាប្រចាំខែសីហា ឆ្នាំ ២០១៦ របស់សហព័ន្ធស្រូវអង្ករកម្ពុជាបានឲ្យដឹងថា សាធារណរដ្ឋប្រជា-មានិតចិននៅតែឈរលេខរៀងទី ១ ក្នុងនាមជាប្រទេសដែលបាននាំចូលអង្ករពីព្រះរាជាណាចក្រកម្ពុជាដោយគិតតាំងពីខែមករាមកដល់ខែសីហាឆ្នាំនេះបាននាំអង្ករពីកម្ពុជាជាង៥ម៉ឺន២ពាន់តោនស្មើនឹង១៦,៣១%។ ខែសីហាចិនបាននាំចូលអង្ករពីកម្ពុជា ៣៣៩១ តោន បើប្រៀបធៀបនឹងខែកក្កដាដែលមានតែ ១៨០១ តោន ។ ថ្មីៗនេះថ្នាក់ដឹកនាំចិនបានសន្យានាំចូលអង្ករកម្ពុជាចំនួន ២០ ម៉ឺនតោននៅឆ្នាំក្រោយ ។

បន្ទាប់ពីចិនគឺប្រទេសបារាំងឈរនៅលំដាប់លេខ២ដែលនាំចូលអង្ករពីកម្ពុជាជាង ៤ ម៉ឺន ៨ ពាន់តោន ប៉ូឡូញលេខ ៣ មានជាង ៤ ម៉ឺន ៥ ពាន់តោន ប៊ែលហ្ស៊ិកលេខ ៤ មានជាង ១ ម៉ឺន ៦ ពាន់ ៧ រយតោន ម៉ាឡេស៊ីលេខ ៥ មានជាង ១ ម៉ឺន ៦ ពាន់តោន ហុលង់លេខ ៦ មានជាង ១ ម៉ឺនតោនចក្រភពអង់គ្លេសមានជាង ១ម៉ឺន ៥ ពាន់តោន សាធារណរដ្ឋឆេកមានជាង ១ ម៉ឺន ៤ ពាន់តោន អ៊ីតាលីលេខ ៧ មានជិត ១ ម៉ឺន ៣ ពាន់តោន និងហុងគ្រីឈរនៅលេខរៀងទី ១០ មានជាង ៩ ពាន់តោន ។

គិតត្រឹមខែសីហាកន្លងទៅនេះដែរ កម្ពុជាបាននាំចេញអង្ករជាង ២៧ ម៉ឺនតោន បើប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៥ ដែលមានជាង ២៩ ម៉ឺនតោន ។

តាមទិសដៅក្នុងឆ្នាំ ២០១៦ នេះ កម្ពុជាគ្រោងនាំចេញអង្ករទៅកាន់បណ្ដាប្រទេសជាសមាជិកសហគមន៍អ៊ីរ៉ុបជិត ២៣ ម៉ឺនតោន ស្មើ ៧០ % ,ទៅប្រទេសចិនជាង ៥ ម៉ឺនតោន ស្មើ ១៦%,ទៅកាន់អាស៊ានជាង ២ ម៉ឺន ៦ ពាន់តោន ស្មើ ៨% និងគោលដៅផ្សេងៗទៀត ៣% ។

រួមគ្នាប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម និងស្តារគុណភាពដី ដើម្បីបង្កើនផលិតកម្មកសិកម្ម

ដោយ: ឯកឧត្តម **ភេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែសីហា ឆ្នាំ២០១៦

*ឯកឧត្តម **ភេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម ឬ ឱនភាពដី នៅភូមិត្រពាំងឈូក ឃុំពោធិ៍អង្ក្រង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ*

*ឯកឧត្តម **ភេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញទស្សនាពិព័រណ៍ផលិតផលកសិកម្ម*

I. សេចក្ដីផ្ដើម

យើងទាំងអស់គ្នាបានជ្រាបរួចហើយថា ទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម ឬឱនភាពដី តែងតែត្រូវបានប្រារព្ធធ្វើជារៀងរាល់ឆ្នាំ នៅថ្ងៃទី ១៧ ខែមិថុនា ចាប់តាំងពីឆ្នាំ ១៩៩៥ រៀងរហូតមក ក្នុងគោលបំណងបង្កើនចំណាប់អារម្មណ៍របស់សាធារណជនអំពីមូលហេតុផ្សេងៗ ដែលបង្ក ឲ្យមានរហោស្ថានកម្ម ឬឱនភាពដី និងគ្រោះរាំងស្ងួត ព្រមទាំងផលវិបាកផ្សេងៗដែលជះឥទ្ធិពលមកលើជីវិតសត្វលោកនៅលើភពផែនដីយើងនេះ ពិសេសជីវភាពរស់នៅរបស់បងប្អូនកសិករនៅតំបន់ជនបទ ដែលពឹងអាស្រ័យលើការងារបង្កបង្កើនផលកសិកម្ម ។ ជាការពិត រហោស្ថានកម្ម ឬ ឱនភាពដីដែលនាំឲ្យមានការថយចុះ ឬបាត់ផលិតភាពសេដ្ឋកិច្ចនៃដីស្រែ ចម្ការ វាលស្មៅ និងព្រៃឈើ។ល។ តែងតែកើតឡើងដោយសារសកម្មភាពរបស់មនុស្ស រួមមាន ការកាប់បំផ្លាញព្រៃឈើ ការរុករករ៉ែ ការធ្វើកសិកម្ម លើសកម្រិត មិនត្រឹមត្រូវតាមបច្ចេកទេស ព្រមទាំងដោយសារកត្តាធម្ម-ជាតិផ្សេងៗ ដូចជាការប្រែប្រួលនៃធាតុអាកាសជាដើម ។ បញ្ហាទាំងអស់នេះបានទាញនូវចំណាប់អារម្មណ៍ជាច្រើន ជាពិសេសរបស់សហគមន៍ជាតិ និងអន្តរជាតិ ចំពោះផលប៉ះពាល់លើផ្នែកសេដ្ឋកិច្ចសង្គម និងបរិស្ថានដែលធ្វើឱ្យមនុស្សជាតិនៅលើពិភពលោករាប់រយលាននាក់ (**ជាង២៥០ លាននាក់**) **បាននិងកំពុងទទួលរងនូវផលប៉ះពាល់នេះ។ ជាក់ស្តែងកម្ពុជា**

យើងក៏ទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរផងដែរ ពីការប្រែប្រួលអាកាសធាតុ ដូចជាការកើនកម្តៅ និងគ្រោះរាំងស្ងួតដែលយើងទាំងអស់គ្នាបានជួបប្រទះ: កាលពីឆ្នាំកន្លងមកនេះ ។

យ៉ាងណាមិញ រហោស្ថានកម្ម ឬឱនភាពដីមិនទាន់ត្រូវបានពិភពលោកយកចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់នៅឡើយ នៅពេលដែលអ្នកវិទ្យាសាស្ត្រ និងប្រទេសជាច្រើនបានអះអាងថា មនុស្សជាតិអាចទប់ស្កាត់ ឬប្រយុទ្ធប្រឆាំងនឹងបញ្ហាទាំងនោះបាន ជាពិសេសតាមរយៈការពង្រឹងការចូលរួមរបស់សហគមន៍ និងការធ្វើកិច្ចសហប្រតិបត្តិការនៅគ្រប់កម្រិត។ គួរបញ្ជាក់ថា ក្នុងចន្លោះឆ្នាំ ២០១២ និង ២០១៤ មានមនុស្សនៅក្នុងពិភពលោកជាង ៨០០ លាននាក់ ឬ ១ នាក់ ក្នុងចំណោមមនុស្ស ៨ នាក់ ពុំមានស្បៀងអាហារ ឬពុំមានអាហារូបត្ថម្ភគ្រប់គ្រាន់ឡើយ ហើយការយកចិត្តទុកដាក់អំពីគុណ-ភាពដីកសិកម្មនៅតែមានសារៈសំខាន់ ដោយសារថាមពលក្នុងអាហារដែលយើងទាំងអស់គ្នាបរិភោគច្រើនជាង ៩៩% គឺបានមកពីដីកសិកម្ម ។ ដូច្នេះ រហោស្ថានកម្ម ឬការប្រែក្លាយដីមានជីជាតិទៅជាវាលខ្សាច់ដែលមិនអាចអនុគ្រោះឲ្យយើងប្រកបរបរកសិកម្ម និងរស់នៅបាននោះ កំពុងត្រូវបានពិភពលោកទាំងមូលទទួលស្គាល់ថា ជាបញ្ហាបរិស្ថានមួយយ៉ាងចម្បងដែលជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ ទៅលើស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងតំបន់ជាច្រើននៃពិភពលោកទាំងមូល ហើយបានវាយតម្លៃថា ដីមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ក្នុងការផ្ដល់នូវដំណោះស្រាយចំពោះបញ្ហា

ប្រឈមនានានៅក្នុងការអភិវឌ្ឍ ដូចជាការកាត់បន្ថយ និងការបន្សាំទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ការរក្សាធនធានទឹក និងថាមពល ការជំរុញកំណើនប្រកបដោយបរិយាប័ន្ន។ល។

II.ភាពឫកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា បានក្លាយជាហត្ថលេខីនៃអនុសញ្ញាសហ-ប្រជាជាតិទប់ស្កាត់រហោស្ថានកម្ម ឬឱនភាពដី នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩៤ ហើយបានផ្ដល់សច្ចាប័ននៅថ្ងៃទី ១៣ ខែសីហា ឆ្នាំ ១៩៩៧ ដោយមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នបង្គោល ។ មកដល់ពេលនេះ អនុសញ្ញានេះមានសមាជិក ឬភាគី (Party) ចំនួន ១៩៥ ។ ក្នុងក្របខ្ណឌនៃការអនុវត្តអនុសញ្ញាយើងមានកាតព្វកិច្ចចូលរួមនិងសហ-ការជាមួយពិភពលោក អនុវត្តសកម្មភាពនានាដែលមានចែងក្នុងអនុសញ្ញានេះ ដើម្បីប្រយុទ្ធប្រឆាំង ឬទប់ស្កាត់រហោស្ថានកម្ម ឬឱនភាពដី ពោលគឺ ថែរក្សាបរិស្ថាន ជីវៈចម្រុះ និងធនធានធម្មជាតិ ដែលក្នុងនោះក៏មានធនធានដីកសិកម្ម សំដៅអភិវឌ្ឍវិស័យកសិកម្ម និងសេដ្ឋកិច្ចជាតិ ព្រមទាំងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ជាមួយនឹងការពង្រឹងសមត្ថភាពការបង្កើនចំណាប់អារម្មណ៍ ការបញ្ជ្រាបអំពីបញ្ហា និងការគ្រប់គ្រងដីដោយនិរន្តរភាព ការរាយការណ៍អំពីវឌ្ឍនភាព ព្រមទាំងការអនុវត្តកិច្ចការពាក់-ព័ន្ធផ្សេងទៀតជាបន្តបន្ទាប់នោះ យើងក៏បានប្ដេជ្ញារៀបចំចងក្រងកម្មវិធីសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងនឹងឱនភាពដី ដែលរំពឹងថានឹងចប់សព្វគ្រប់ក្នុងពេលដ៏ខ្លីខាងមុខនេះ ។

អនុលោមតាមអនុសញ្ញាពាក្យថាការក្លាយដីជាវាលខ្សាច់ឬរហោស្ថាន-កម្ម មានន័យថាជាការធ្វើឲ្យមានឱនភាពដីនៅតំបន់ដីស្ងួត ពោលគឺតំបន់ដែលមានភ្លៀងធ្លាក់តិចតួច ឬគ្មានភ្លៀងសោះ ដូចជានៅតំបន់វាលខ្សាច់ជាដើម ដែលនាំឲ្យមានការប្រែប្រួលខ្លាំង នូវលក្ខខណ្ឌអាកាសធាតុ (Extreme Cli mate Variation) និងសកម្មភាពរបស់មនុស្ស ។ ប៉ុន្តែព្រះ-រាជាណាចក្រកម្ពុជា ដែលស្ថិតនៅតំបន់ត្រូពិក ដែលមានអាកាសធាតុក្ដៅ ហើយសើម មិនមានបញ្ហារហោស្ថានកម្មទេ ដោយសារធម្មជាតិនៅទីនេះ នៅមានសមត្ថភាពអាចផលិត ឬបង្កើតឡើងវិញនូវរុក្ខជាតិ និងជីវៈចម្រុះ ។ អនុសញ្ញាក៏បានបញ្ជាក់ផងដែរថា មូលហេតុសំខាន់ៗដែលបង្កឲ្យមានឱនភាពដី មានដូចជា៖ ការបាត់បង់ព្រៃឈើ និងប្រព័ន្ធបរិស្ថានព្រៃឈើ ការធ្វើសកម្មភាពលើសកំណត់ ឬលើសសមត្ថភាពរបស់ដី ការដាំដំណាំតែមួយមុខ ការប្រើជី និងថ្នាំកសិកម្ម លើសកម្រិត ឬមិនត្រឹមត្រូវ ការបណ្ដោយឲ្យសត្វស៊ីលើសសមត្ថភាពដុះលូតលាស់របស់ស្មៅ និងរុក្ខជាតិ ការជីកយករ៉ែ ការសាងសង់ទំនប់ និង ប្រឡាយមិនត្រឹមត្រូវ ការពង្រីកវិសាលភាពទីប្រជុំជនធំៗ និងកត្តាធម្មជាតិនានាជាដើម ជាពិសេសគឺការប្រែប្រួលអាកាសធាតុ ។

គួរកត់សម្គាល់ថា ក្រោយការបោះឆ្នោតជាសកលឆ្នាំ ១៩៩៣ ជាមួយនឹងស្មារតីបង្រួបបង្រួមជាតិ និងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានបញ្ចប់ទាំងស្រុងនូវសង្គ្រាមស៊ីវិលដែលអូសបន្លាយរាប់ទសវត្សរ៍កន្លងមក តាមរយៈគោលនយោបាយ **ឈ្នះ-ឈ្នះ** ធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាទាំងមូល មានសុខសន្តិភាព ស្ថេរភាពនយោបាយពេញលេញ និងមានអតិរេកស្បៀង ។ បច្ចុប្បន្ននេះ កម្ពុជាទទួលបាននូវការអភិវឌ្ឍរីកចម្រើនជាបន្តបន្ទាប់លើគ្រប់វិស័យ ។

សូមជម្រាបជូនផងដែរថា កម្ពុជាត្រូវបានវាយតម្លៃនៅក្នុងសន្និសីទលើកទី ៣៨ ក្នុងឆ្នាំ ២០១៣ របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជា-ជាតិ (FAO) ថាបានសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ១ លើផ្នែកកង្វះអាហារូបត្ថម្ភ និងនៅក្នុងសន្និសីទលើកទី ៣៩ ដែលបានប្រព្រឹត្ត ទៅនៅប្រទេសអ៊ីតាលី កាលពីខែមិថុនា ឆ្នាំ ២០១៥ ថាបានសម្រេចគោលដៅទី ១ នៃគោលដៅសហសវត្សរ៍ ក្នុងការប្រយុទ្ធនឹងភាពក្រីក្រ និងគ្រោះអត់ឃ្លាន ជាមួយនឹងប្រទេសផ្សេងទៀតចំនួន ៣៨ នៅលើពិភពលោក តាំងពីឆ្នាំ ២០១២ កន្លងមក ព្រមទាំងបានប្រគល់ពានរង្វាន់ជូនរដ្ឋាភិបាលយើងផងដែរ ។

ទោះជាយ៉ាងណា គុណភាពដីត្រូវបានពិភពលោកចាប់អារម្មណ៍ជាងគេបំផុតនៅក្នុងគោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាព។ ដូច្នេះដើម្បីរួមចំណែកសម្រេចឲ្យបាននូវគោលដៅខាងលើនេះ ការបំបាត់ ឬការទប់ស្កាត់មិនឲ្យមានកំណើនឱនភាពដី គួរត្រូវបានចាត់ជាកិច្ចការដ៏មានអាទិភាពបំផុត ដើម្បីឈានទៅឆ្លើយតបឲ្យបាននូវតម្រូវការផ្សេងៗ របស់មនុស្សជាតិ និងការធ្វើឲ្យសម្រេចនូវការអភិវឌ្ឍប្រកបដោយសក្តានុពល ហើយជាកត្តាសក្សានុម័ត យើងទាំងអស់គ្នាត្រូវចូលរួមបញ្ជ្រាបព័ត៌មាន និងបង្កើនការយល់ដឹងរបស់មនុស្សជាតិ អំពីការគ្រប់គ្រង ថែរក្សា និងអភិរក្សធនធានធម្មជាតិជាពិសេសធនធានដីកសិកម្មរបស់យើងប្រកបដោយចីរភាព។ គួររំលឹកផងដែរថា នៅឆ្នាំ ២០១៥ កន្លងទៅ យើងបានប្រារព្ធទិវានេះនៅស្រុកឱរ៉ាល់ និងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលជាតំបន់ខ្សែទឹកខាងលើនៃទីជម្រាលស្ទឹងព្រៃកត្នោត ។ នៅទីនោះយើងបានឃើញ និងទទួល ស្គាល់ថាមានព្រៃឈើ និងជីវៈចម្រុះដ៏ល្អជាច្រើនរបស់យើងត្រូវបានបាត់បង់ ហើយដីជាច្រើននៅទីនោះបានក្លាយចម្ការដំណាំ និងភូមិការរបស់ប្រជាពលរដ្ឋ ។

III. ស្ថានភាពឱនភាពដីនៅជុងស្ទឹងព្រៃកត្នោត

ឆ្នាំនេះការជ្រើសរើសយកទីតាំងនេះ ដែលជាតំបន់ខ្សែទឹកខាងក្រោមនៃទីជម្រាលស្ទឹងព្រៃកត្នោត សម្រាប់ប្រារព្ធទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម ឬឱនភាពដី ឆ្នាំ២០១៦ នាពេលនេះ គឺយើងមានបំណងបង្ហាញជូន និងបងប្អូនជនរួមជាតិទាំងអស់ឲ្យបានឃើញ និងជ្រាបផ្ទាល់អំពីផលវិបាកនៃការបាត់បង់ព្រៃឈើ និងការគ្រប់គ្រងដីមិនត្រឹមត្រូវនៅតំបន់ខ្សែទឹកខាងលើ និងធនធានធម្មជាតិនៅតំបន់ខ្សែទឹកខាងក្រោម ។ ទស្សនកិច្ច និងការស្តាប់បទឧទ្ទេសនាមដែលយើងបានឃើញផ្ទាល់នៅ តាមដងស្ទឹងស្លាគូនេះអាចធ្វើឲ្យយើងឃើញ និងយល់ច្បាស់ជ្រាបថាដងស្ទឹងស្លាគូ បានបាត់បង់សម្រស់ខូចរូបរាង ដោយសារលំហូរខ្សាច់ពីខ្សែទឹកខាងលើ មកធ្វើឲ្យពួនកកនៅបាតស្ទឹង និងលើដីស្រែចម្ការក្បែរខាង ។ ដូច្នេះ ប្រសិន បើយើងនៅតែបណ្ដោយឲ្យបញ្ហាទាំងនេះបន្ដកើតមានតទៅទៀតនោះ ស្ទឹងស្លាគូនឹងឈប់ហូរ ពេញមុខងារជាខ្សែទឹក ឈប់នាំទឹកពីតំបន់ខាងលើសម្រាប់ប្រើប្រាស់នៅតំបន់ខាងក្រោម ជាកត្តានាំឲ្យមានឱនភាពដីយ៉ាងធ្ងន់ធ្ងរទាំងនៅតំបន់ធ្លាប់មានព្រៃឈើ និងនៅតំបន់វាលទំនាប ហើយនៅទីបំផុតដីកសិកម្មរបស់យើងអាចនឹងគ្មានផលិតភាពទាំងស្រុងតែម្ដង។ នេះជាកត្តាសក្សានុម័ត ដែលយើងទាំងអស់គ្នាត្រូវចូលរួមរក្សាសម្រស់ធម្មជាតិដងស្ទឹងស្លាគូ ។

ក្នុងន័យនេះ យើងក៏មានបំណងបញ្ជូន និងផ្ញើសារជូនដល់អ្នកពាក់ព័ន្ធ និងសាធារណជនទាំងអស់ថា យើងទាំងអស់គ្នាចាំបាច់ត្រូវធ្វើកិច្ចសហ-

ប្រតិបត្តិការទាំងក្នុងកម្រិតអន្តរជាតិតំបន់ និងនៅក្នុងប្រទេស ហើយចូលរួមដោយយកចិត្តទុកដាក់ និងយ៉ាងសកម្ម ដើម្បីស្តារគុណភាពដី ឬស្តារដីដែលមានឱនភាពរួចទៅហើយ សំដៅរួមចំណែកសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាព ។ ជាការពិត ការគ្រប់គ្រងដីដោយនិរន្តរភាពមានន័យថាជាការអនុវត្តឲ្យបានត្រឹមត្រូវ សំដៅគ្រប់គ្រងរួមនូវដី ទឹក ជីវៈចម្រុះ និងធនធានបរិស្ថានផ្សេងទៀតឲ្យនៅរក្សាគុណភាពបានយូរអង្វែង ដើម្បីឆ្លើយតបនឹងតម្រូវការរបស់មនុស្ស ដូចជាអាហារជាដើម ។ ការគ្រប់គ្រងដីដោយនិរន្តរភាពគឺជាកិច្ចការដ៏ចាំបាច់ សម្រាប់ឆ្លើយតបនឹងតម្រូវការរបស់មនុស្សជាតិ ដែលចេះតែបន្តកើនឡើងជាលំដាប់ ។ ផ្ទុយទៅវិញការគ្រប់គ្រងដីមិនត្រឹមត្រូវនឹងធ្វើឲ្យដីមានឱនភាព ឬទុព្វលភាពហើយថយមុខដារក្នុងការផ្តល់ផលិតភាពផ្តល់ជាជម្រកដល់ជីវៈចម្រុះរក្សាប្រព័ន្ធជលសាស្ត្រ រួមទាំងក្នុងការស្រូប និងរក្សាកាបូនផងដែរ ។ ដោយមើលឃើញអំពីអត្ថប្រយោជន៍ ដូចបានរៀបរាប់ខាងលើនេះ យើងអាចវាយតម្លៃបានថាដីគឺជាមូលដ្ឋានដែលមានជីវិតសម្រាប់មនុស្ស សត្ត រុក្ខជាតិគ្រប់ប្រភេទនៅលើភពផែនដី ។

IV. តើយើងទាំងអស់គ្នាមានភាពកិច្ចយ៉ាងណា ដើម្បីកាត់បន្ថយរហោស្ថានកម្ម ឬឱនភាពដី

ទី១.ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិទាំងអស់ សូមបន្តគាំទ្រការលើកកម្ពស់ និងជំរុញការអភិវឌ្ឍវិស័យកសិកម្មតាមគ្រប់រូបភាពដើម្បីធានាឲ្យមានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងនៅក្នុងកម្រិតគ្រួសារ សហគមន៍ និងថ្នាក់ជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ ពាណិជ្ជបនីយកម្មកសិកម្មស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ខ្ញុំសូមអំពាវនាវដល់បងប្អូនកសិករ ក៏ដូចជាអង្គភាពជំនាញក្រោមឱវាទមន្ទីរកសិកម្មរាជធានី ខេត្ត អាជ្ញាធរ ថ្នាក់ក្រោមជាតិខិតខំយកចិត្តទុកដាក់ ដោយមិនត្រូវមើលរំលងអំពីការជំរុញការងារដាំដុះដំណាំគ្រប់មុខព្រួញឲ្យបានទាន់ពេលវេលា ពិសេសដំណាំស្រូវ រដូវវស្សា ដើម្បីលើកកម្ពស់ផលិតភាពកសិកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងរក្សាទឹកទុកបង្ការការខ្វះខាតជាយថាហេតុនៅចុងរដូវស្រូវ ជាមួយនឹង**ដំបូន្មានរបស់ភ្លាមៗ ង៉ុយ** ដែលបានពោលថា "**ធ្វើស្រែចង់បានស្រូវដើម រដូវធ្វើស្រែ ទួលស្រែ ទាបមើលទំនួល លើកទំនប់ឲ្យមាំមួន**" ។

ទី២.អាជ្ញាធរមូលដ្ឋាន ជាពិសេស ភូមិ-ឃុំ ត្រូវគ្រប់គ្រងតាមដាន និងរាយការណ៍ចំពោះជនចំណាកស្រុក ដែលទើបចាប់ផ្តើមមានចំនួនតិចឲ្យបានទាន់ពេលវេលា ដោយអនុវត្តតាមពាក្យស្លោក "**ប៉ីមិនមួយរាយការណ៍**" ព្រមទាំងត្រូវចាត់វិធានការ ប្រកបដោយប្រសិទ្ធភាពចំពោះសកម្មភាពដែលកំពុងកាប់រានដីព្រៃឈើដើម្បីធ្វើកម្មសិទ្ធិ កុំឲ្យរីករាលដាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ទី៣.ត្រូវអនុវត្តកសិកម្មប្រកបដោយស្ថិរភាព និងមានភាពធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ ដោយដាក់បញ្ចូលគោលការណ៍ប្រព័ន្ធអេកូឡូស៊ីជាមូលដ្ឋាន។ ទន្ទឹមនឹងនេះ ក៏ត្រូវកំណត់អត្តសញ្ញាណ និងផ្សព្វផ្សាយអំពីការអនុវត្តកសិកម្មល្អ ប្រកបដោយភាពឆ្លាតវៃ ដើម្បីធានាឱ្យមានការផ្លាស់ប្តូរបទពិសោធន៍រវាងកសិករ និងកសិករ និងត្រូវធ្វើឲ្យប្រសើរឡើងដល់ការកំណត់និងការគ្រប់គ្រងហានិភ័យធម្មជាតិ និងសមត្ថភាពទាំងឡាយ ត្រូវឲ្យស្របទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌអាកាសធាតុនៅគ្រប់កម្រិត ។

ទី៤.ត្រូវអនុវត្តវាស់វិធានការនានា ដើម្បីកាត់បន្ថយការបំផ្លាញគុណភាពដីការប្រើប្រាស់ដីគ្មាននិរន្តរភាព និងការបំផ្លាញដល់ប្រព័ន្ធអេកូឡូស៊ី។ ជាមួយនេះ អង្គភាពជំនាញ ត្រូវឈ្មុសឈ្មុល រៀបចំច្បាប់ស្តីពីការគ្រប់គ្រងធនធានដីកសិកម្មឲ្យបានឆាប់ និងរៀបចំកំណត់តំបន់ដីកសិកម្មឲ្យបានសមស្រប សម្រាប់ទិសដៅយូរអង្វែង។ ត្រូវអនុវត្តគោលការណ៍ពាក់ព័ន្ធ ដើម្បីឈានដល់ការគ្រប់គ្រងប្រភពធនធានធម្មជាតិ ដែលកើតចេញពីវិធានការអភិវឌ្ឍន៍ប្រកបដោយស្ថិរភាព ដោយប្រមូលផ្តុំនៅក្នុងប្រព័ន្ធគ្រប់

គ្រងអេកូឡូស៊ី និងការអភិវឌ្ឍផ្អែកលើមូលដ្ឋានជីវៈចម្រុះ។ ជាមួយនេះ ក៏ត្រូវលើកកម្ពស់ដល់គោលនយោបាយប្រើប្រាស់ដីធ្លី ដើម្បីជួយដល់កសិករដែលមានដីស្រែចម្ការតិចតួចប្រកបដោយសមធម៌ និងរក្សាបាននូវស្ថិរភាពនៃការប្រើប្រាស់ដី និងប្រភពធនធានធម្មជាតិតាមរយៈការធ្វើកសិកម្មចម្រុះឲ្យអស់លទ្ធភាពដោយមិនត្រូវទុកដីឱ្យនៅទំនេរ និងកាត់បន្ថយការធ្វើចំណាកស្រុក ។

ទី៥.បងប្អូនជនរួមជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមការពារ ស្តារ និងអនុវត្តការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានធម្មជាតិ និងប្រព័ន្ធបរិស្ថាន ជាពិសេសគឺចូលរួមទប់ស្កាត់ការអនុវត្ត ឬសកម្មភាពដែលបង្ក ឲ្យមានរហោស្ថានកម្ម ឬមានឱនភាពដី ពោលគឺត្រូវបង្វែរពីការរស់នៅដោយពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ព្រមទាំងការអនុវត្តធ្វើកសិកម្មតាមទម្លាប់ មកធ្វើកសិកម្មតាមបែបប្រពលវប្បកម្មទំនើបចម្រុះ ទាន់សម័យ និងសមស្រប ហើយចូលរួមគ្រប់គ្រងដីឲ្យមាននិរន្តរភាពដើម្បីលើកកម្ពស់ជីវភាពរស់នៅ ពោលគឺត្រូវរក្សា ស្តារ ឬកែប្រែទឹកដីរបស់យើងឲ្យមានភាពបៃតងស្រស់ មានភាពមនោរម្យយូរអង្វែង សម្រាប់ជីវិតរបស់យើងគ្រប់ៗគ្នា ។

V.សេចក្ដីសន្និដ្ឋាន

ការចូលរួមយ៉ាងសកម្មរបស់សហគមន៍មូលដ្ឋាន និងកិច្ចសហប្រតិបត្តិការនៅគ្រប់កម្រិត ក្នុងការបញ្ឈប់ ឬទប់ស្កាត់មិនឲ្យមានកំណើនឱនភាពដីជាកត្តាដ៏សំខាន់ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាពិសេស គឺដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានបេសកកម្មក្នុងការចូលរួមកែលម្អជីវភាពរស់នៅរបស់ប្រជាកសិករ តាមរយៈការលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្មលើគ្រប់ផ្នែក ។ ក្រោមការដឹកនាំ និងការចង្អុលបង្ហាញជាបន្តបន្ទាប់ ប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែងបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ក្នុងភាពជាដៃគូជាមួយអង្គការជាតិ និងអន្តរជាតិ បង្កើនថែមលើ សមត្ថភាព និងលទ្ធភាពដែលមានស្រាប់ ដើម្បីបម្រើឲ្យឧត្តមប្រយោជន៍ របស់ប្រជាជនកម្ពុជា ស្របតាមបេសកកម្មខាងលើ ។ ភាពជាដៃគូនេះ មានគោលដៅក្នុងការបង្កើនផលិតភាពកសិកម្ម បង្កើនប្រភពចំណូលរបស់ប្រជាជន ផ្តល់ភាពអង់អាច និងភាពជាម្ចាស់ដល់សហគមន៍នៅជនបទ ។

ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះដៃគូពាក់ព័ន្ធទាំងអស់ដែលបាន និងកំពុងបន្តចូលរួមគាំទ្រ និងសហការទាំងបច្ចេកទេស និងថវិកា ក្នុងការទប់ស្កាត់ បញ្ហានានាដូចដែលបានរៀបរាប់ពីខាងដើម ពិសេសការអភិវឌ្ឍវិស័យកសិកម្ម និងសូមអំពាវនាវដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ សូមមេត្តាជួយបន្តការគាំទ្រ ព្រមទាំងជួយផ្សព្វផ្សាយ បុព្វហេតុខាងលើនេះ ឲ្យបានទូលំទូលាយ និងឲ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់មជ្ឈដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីក្តីសង្ឃឹមនៃអនាគតរួមរបស់យើងទាំងអស់គ្នា ក៏ដូចជាសត្តនិករទាំងឡាយដែលមានជីវិតរស់នៅលើភពផែនដីដ៏ធំទូលាយនេះ ។

ផ្លែផ្កាជាវិជ្ជមានតៅក្នុងការអនុវត្ដផែនការយុទ្ធសាស្ដ្រ វិស័យអប់រំឆ្នាំ ២០១៤-២០១៨

*ឯកឧត្ដមបណ្ឌិត **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្ដកម្មវិធីសាលាកុមារមេត្រី និងសហគមន៍ចូលរួមអភិវឌ្ឍវិស័យអប់រំ*

សាកលវិទ្យាល័យវិទ្យាសាស្ដ្រសុខាភិបាល ជាផ្នែកមួយនៃការបណ្ដុះបណ្ដាលធនធានមនុស្ស សម្រាប់រួមចំណែកដល់ការអភិវឌ្ឍនៅកម្ពុជា

មកដល់បច្ចុប្បន្ននេះក្រសួងអប់រំយុវជននិងកីឡាបាននិងកំពុងបន្ដខិតខំប្រឹងប្រែងយ៉ាងសកម្មនៅក្នុងការអនុវត្ដន៍ផែនការយុទ្ធសាស្ដ្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ដោយផ្ដោតការយកចិត្ដទុកដាក់ខ្ពស់ដល់ការពង្រីកការអប់រំកុមារតូច ការបង្កើនលទ្ធភាពទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សាប្រកបដោយគុណភាព ព្រមទាំងការពង្រីកការអប់រំក្រៅប្រព័ន្ធការអប់រំបច្ចេកទេស ការអភិវឌ្ឍការងារយុវជន និងការអប់រំកាយ និងកីឡា ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ដ្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល និងអាទិភាពអប់រំនៅក្នុងផែនការយុទ្ធ-សាស្ដ្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ ។

តាមរបាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា បានឲ្យដឹងថារហូតមកដល់ពេលបច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជាមានសិស្សសរុបចំនួន ៣.១៧១.៦៦៨ នាក់ និស្សិតសរុបចំនួន ២២៧.៣៨៥ នាក់ និងមានបុគ្គលិកអប់រំនៅទូទាំងប្រទេសចំនួន ១១៥.៣០៥ នាក់ ក្នុងនោះស្រីមាន ៥០ ១៨៥ នាក់ ត្រូវជា ៨៣,៨៩%។ រាជរដ្ឋាភិបាលបានខិតខំកសាងអគារសិក្សាជាច្រើននៅទូទាំងប្រទេស ពិសេសតាមតំបន់ព្រំដែន និងតំបន់ជួបការលំបាក ក្នុងគោលដៅបង្ហិតសាលារៀនឲ្យទៅជិតលំនៅឋានរបស់ប្រជាជន ជាលទ្ធផលនៅទូទាំងប្រទេសនាពេលបច្ចុប្បន្នមានសាលាមត្ដេយ្យសិក្សា និងសាលារៀនចំណេះទូទៅ ទាំងសាធារណៈ និងឯកជនសរុប ១៣.៣៣៣ ក្នុងនេះរួមមាន សាលាមត្ដេយ្យសិក្សា ៤.០២៦ សាលាបឋមសិក្សា ៧.៤៤២ អនុវិទ្យាល័យ ១.២៩៤ និងវិទ្យាល័យ ៥៧១ ដែលក្នុងនោះមានអគារចំនួន ៣.៦២៣ ខ្នងស្មើនឹង ១៨.៨៨៦ បន្ទប់ ។

តាមរបាយការណ៍ឲ្យដឹងទៀតថាអត្រាពិតនៃការសិក្សារបស់កុមារនៅសាលាបឋមសិក្សាសាធារណៈ និងឯកជនមាន ៩៨,៤% (ស្រី ៩៩,៣%)។ ក្នុងនោះ សិស្សសរុបនៅគ្រប់ភូមិសិក្សាសាធារណៈ និងឯកជន មត្ដេយ្ય-សិក្សាដល់មធ្យមសិក្សាមានចំនួន ៣.១៧១.៦៦៨ នាក់ ស្រី ១.៥៥៧.៦០១ នាក់ ស្មើនឹង ៤៩,១១%។ គ្រឹះស្ថានឧត្ដមសិក្សាមានចំនួន ១១៨ ក្នុងនោះគ្រឹះស្ថានឧត្ដមសិក្សារដ្ឋ ៤៦ និងឯកជន ៧២ ដែលមានទីតាំងស្ថិតនៅតាមរាជធានី ខេត្ដចំនួន ១៩ ។ គ្រឹះស្ថានឧត្ដមសិក្សាទាំងនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នចំនួន ១៥ ។ សម្រាប់គ្រឹះស្ថានឧត្ដមសិក្សាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា មានចំនួន ៧១ ក្នុងនោះ រដ្ឋ ១២ និងឯកជន ៥៩។ និស្សិតចាប់ពីថ្នាក់បរិ-ញ្ញាបត្ដ្ររងដល់បណ្ឌិតមានចំនួន ២២៧.៣៨៥ នាក់ នារី ១០០.៤២៤ នាក់ ស្មើនឹង ៤៤,១៦ %។ នៅក្នុងការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បានកែលម្អ និងដាក់ឲ្យអនុវត្ដកម្មវិធីសិក្សាថ្មី និងផ្ដល់សៀវភៅសិក្សា សម្ភារបច្ចេកទេស ដើម្បីបម្រើឲ្យការរៀន ការបង្រៀន និងការស្រាវជ្រាវនៅតាមគ្រឹះស្ថានសិក្សា និងបានយកចិត្ដទុកដាក់ដល់ការងារតម្រង់ទិសវិជ្ជាជីវៈនៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ។

ទន្ទឹមនេះ ក្រសួងបានធ្វើវិក្រឹតការគ្រូបង្រៀនជាប្រចាំ ដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀនដែលជាអ្នកផ្ដល់ការអប់រំយុវជនជំនាន់ក្រោយ ឲ្យកាន់តែមានចំណេះដឹង បំណិន និងសីលធម៌ខ្ពស់ ស្របតាមចតុស្ដម្ភទាំងបួននៃការអប់រំគឺ " រៀនដើម្បីមានចំណេះដឹង រៀនដើម្បីមានចំណេះធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនដើម្បីចេះរស់នៅជាមួយគ្នា" ព្រមទាំងបណ្ដុះបណ្ដាលមន្ត្រីគ្រប់គ្រងគ្រប់កម្រិត ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យអប់រំ ។ លើសពីនេះទៀត យន្ដការធានាគុណភាពអប់រំ ត្រូវបានរៀបចំ និងកំពុងអនុវត្ដជាជំហានៗ ដើម្បីពិនិត្យ និងវាយតម្លៃលើការសិក្សារបស់សិស្សានុសិស្ស និងការងារគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សាទូទាំងប្រទេស ។

ជាមួយគ្នានេះដែរដោយមានកិច្ចសហការល្អពីដៃគូអភិវឌ្ឍក្រសួងបានបើកយុទ្ធនាការអក្ខរកម្ម ដើម្បីបង្កើនការចូលរៀនថ្នាក់អក្ខរកម្ម។ ជាលទ្ធ-ផល នៅឆ្នាំសិក្សា ២០១៤-២០១៥ មានគ្រូអក្ខរកម្មចំនួន ៣ ៥៣៤ នាក់ ស្រី ១ ២២៥ នាក់ និងមានអ្នកចូលរួមរៀនចំនួន ៧៤ ៨៩៩ នាក់ ស្រី ៥២ ៧៤១ នាក់ ស្មើនឹង ៧០,៤២%។ មជ្ឈមណ្ឌលសិក្សាសហគមន៍ មាន

សិស្សានុសិស្សនៃសាលាបឋមសិក្សា

*វិទ្យាល័យ **ជ៊ុន ហ៊ានី ហ៊ុន សែន** អម្ពរ៉ានជំនីក ស្ថិតក្នុងឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តតាត្រាងឃ្មុំ*

វិទ្យាល័យថ្មគ្រែ ស្ថិតក្នុងស្រុកចិត្របុរី ខេត្តក្រចេះ កសាងដោយមូលនិធិសប្បុរសធម៌នៃប្រទេសសិង្ហបុរី និងមូលនិធិសប្បុរសធម៌ក្នុង និងក្រៅស្រុក

៣៤២ កន្លែង ក្នុងនោះ ៣២៤ កន្លែង គ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឬា និងចំនួន ១៨ កន្លែងទៀត គ្រប់គ្រងដោយដៃគូអភិវឌ្ឍន៍និងមានអ្នករៀនជំនាញមុខរបរចំនួន ៨ ០៩០ នាក់ ស្រី ៥ ១១២ នាក់ ស្មើនឹង ៦៣,១៩ % ។

ឆ្នាំសិក្សាកន្លងទៅ នៅក្នុងកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្រសួងបានធ្វើការប្រកាសលទ្ធផលប្រឡងប្រកបដោយជោគជ័យ ឈរលើគោលការណ៍ច្បាប់ យុត្តិធម៌ ឥម្លាភាព និងលទ្ធផលអាចទទួលយកបាន ស្របតាមពាក្យស្លោកដែលថា"អ្នកចេះគឺជាប់" ។ នៅក្នុងកំណែទម្រង់នេះ បានបង្កើនជំនឿទុកចិត្តរបស់មហាជនមកលើការដឹកនាំរបស់រាជរដ្ឋាភិបាល និងបានធ្វើឲ្យមានការប្រែប្រួលជាវិជ្ជមានដល់ឥរិយាបថរបស់សិស្សនៅក្នុងការសិក្សារៀនសូត្រ ។

នៅឆ្នាំ២០១៦នេះ ក្រសួងអប់រំយុវជននិងកីឬាបានប្រកាសឱ្យដឹងថា ក្រសួងបានកំណត់មណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(បាក់ឌុប) ទូទាំងប្រទេសចំនួន ១៨០ មណ្ឌល ស្មើនឹង ៣៧៨១ បន្ទប់ នៅទូទាំងប្រទេស ។ បើប្រៀបធៀបកាលពីឆ្នាំមុន ដែលក្រសួងអប់រំយុវជននិងកីឬាបានរៀបចំប្រឡងបាក់ឌុបនៅថ្ងៃទី ២៤ សីហា ឆ្នាំ ២០១៥ មណ្ឌលប្រឡងមានចំនួន ១៥០ មណ្ឌល ក្នុងនោះថ្នាក់វិទ្យាសាស្ត្រមាន ១២៦ មណ្ឌល និងថ្នាក់វិទ្យាសាស្ត្រសង្គមមាន ២៤ មណ្ឌល ត្រូវជា ៣៨២៧ បន្ទប់ទូទាំងប្រទេស ។ មានន័យថា ទាំងមណ្ឌល និងបន្ទប់ប្រឡងមានការកើនឡើងជាងឆ្នាំមុន ។ ការកើនឡើងចំនួនបន្ទប់ និងមណ្ឌលប្រឡងនេះ ដោយសារតែចំនួនបេក្ខជនប្រឡងមានការកើនឡើង ។

ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំនេះ ក្រសួងបានបង្ហាញជំហរបន្តរឹតបន្តឹងដូចឆ្នាំមុនដដែល ដោយឈរលើគោលការណ៍ ៤ ចំណុច គឺការប្រឡងត្រូវតែឈរលើការគោរពច្បាប់ ឥម្លាភាព យុត្តិធម៌ និងសុចរិតភាព ។

សមិទ្ធផលទាំងនេះ គឺពិតជាកើតមានឡើងដោយសារការខិតខំប្រឹងប្រែងរបស់ក្រសួង ព្រមទាំងផ្នែកឯកជន និងបណ្ដាដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចូលរួមជាមួយរាជរដ្ឋាភិបាល ដើម្បីដឹកនាំនាវាកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍ ជាមួយនឹងធនធានមនុស្សប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់បន្តវេនកសាងការពារអភិវឌ្ឍសង្គមជាតិ ឲ្យឆ្លើយតបបានទៅនឹងបរិបទនៃការវិវត្តក្នុងតំបន់ និងពិភពលោក។ ជាងនេះទៀត រាជរដ្ឋាភិបាល បាននិងកំពុងបន្តខិតខំប្រឹងប្រែងកសាងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធរូបវន្តអប់រំ និងការបង្កើតសាលារៀនឲ្យបានច្រើនថែមទៀត ដែលជាការវិនិយោគរយៈពេលវែងដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋទាំងអស់ សំដៅរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងលុបបំបាត់នូវភាពក្រីក្រ តាមរយៈការផ្ដល់ឱកាសទទួលបានសេវាអប់រំ និងចំណេះដឹងដល់ប្រជាជនទូទៅទាំងអស់គ្នា ។

ទិដ្ឋភាពទូទៅនៅមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី ២២-២៣ ខែសីហា ឆ្នាំ ២០១៦

នៅក្នុងទិសដៅសម្រាប់បណ្ដាឆ្នាំខាងមុខទៀត ក្រសួងអប់រំ យុវជន និងកីឬា នឹងបន្តការខិតខំនៅក្នុងការអនុវត្តន៍ផែនការ ធ្វើឲ្យសម្រេចគោលនយោបាយ និងយុទ្ធសាស្ត្រ នានាក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០១៤-២០១៨ ។ យកចិត្តទុកដាក់ជំរុញការរៀបចំ និងអនុវត្តស្តង់ដាសេវាសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សារដ្ឋ និងឯកជន ។ លើកកម្ពស់ការអនុវត្តគោលនយោបាយឲ្យមានប្រសិទ្ធភាព ដើម្បីការចុះឈ្មោះចូលរៀន ការបន្តការសិក្សា និងការបញ្ចប់ការសិក្សានៅមធ្យមសិក្សា។ ចំណែកឯការអប់រំនៅឧត្តមសិក្សាវិញ ខិតខំបន្តការរៀបចំយន្តការធានាគុណភាពឲ្យមានប្រសិទ្ធភាព សម្រាប់ការបង្រៀន និងរៀន ការស្រាវជ្រាវ ទាំងប្រព័ន្ធធានាគុណភាពខាងក្នុង និងខាងក្រៅ ។ ចំពោះការអប់រំក្រៅប្រព័ន្ធ គឺបន្តការលើកកម្ពស់ដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍ ដើម្បីផ្ដល់ជំនាញអប់រំក្រៅប្រព័ន្ធស្របនឹងស្តង់ដាព្រមទាំងកែលម្អការអនុវត្តការងារអប់រំក្រៅប្រព័ន្ធ រួមមាន ៖ កម្មវិធីអក្ខរកម្ម កម្មវិធីសមមូល និងកម្មវិធីចូលរៀនឡើងវិញ ។

នៅក្នុងពិធីជួបសំណេះសំណាលជាមួយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិទ្ទេស "A" ឆ្នាំ ២០១៦ នៅទូទាំងប្រទេសចំនួន ៤០៥ នាក់ នៅវិមានសន្តិភាព សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្ដែងនូវការអបអរសាទរ និងកោតសរសើរដល់បេក្ខជនជ័យលាភី ចំពោះលទ្ធផលគួរជាទីមោទនៈនេះដែលបានមកពីការខិតខំប្រឹងប្រែងយកចិត្តទុកដាក់សិក្សារបស់បេក្ខជនផ្ទាល់ និងជាការខិតខំរបស់ក្រសួងអប់រំយុវជន និងកីឬាជាពិសេសរាជរដ្ឋាភិបាលកម្ពុជាដែលធ្វើឲ្យមានសន្តិភាពការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការបណ្ដុះបណ្ដាលគ្រូបង្រៀនជាដើម ។ សម្ដេចតេជោក៏បានថ្លែងនូវកោតសរសើរដល់ឯកឧត្តម **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឬា ក្នុងការដឹកនាំកំណែទម្រង់ប្រព័ន្ធអប់រំនៅកម្ពុជា ។ សម្ដេចសង្ឃឹមថា ២០ឆ្នាំទៀត ធនធានមនុស្សរបស់កម្ពុជានឹងខ្លាំងបំផុត។

ស្វែងយល់អំពីច្បាប់បោះឆ្នោត

អំពីបញ្ជីបោះឆ្នោតដំបូង និងការប្តឹងតវ៉ា ឬការប្តឹងជំទាស់

I.ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងជាសាធារណៈ សម្រាប់គោលដៅនៃការប្តឹងតវ៉ា ឬការប្តឹងជំទាស់

បន្ទាប់ពីបានពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះបោះឆ្នោតក្នុងប្រព័ន្ធផ្ទុកទិន្នន័យរួចរាល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវបោះពុម្ពនិងចាត់ឲ្យបិទផ្សព្វផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតដំបូងរួមនឹងបញ្ជីឈ្មោះអ្នកដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ នៅតាមសាលាឃុំ សង្កាត់ និងទីតាំងណាមួយក្នុងឃុំ សង្កាត់ តាមការកំណត់របស់ គ.ជ.ប ក្នុងគោលដៅនៃការប្តឹងតវ៉ា ឬការប្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូង ។

សម្រាប់ការចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០១៦ នេះ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ទូទាំងប្រទេស ត្រូវធ្វើនៅថ្ងៃទី ៣ ខែមករា ឆ្នាំ ២០១៧ ។ ក្នុងរយៈពេលបិទផ្សាយក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ស្មៀន និងមេភូមិ ត្រូវផ្សព្វផ្សាយបំផុសលើកទឹកចិត្តប្រជាពលរដ្ឋ អ្នកបោះឆ្នោតគ្រប់រូប ឲ្យទៅមើលឈ្មោះ និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនតាមទីតាំងដែលបានបិទផ្សាយ ។ បន្ទាប់ពីរយៈពេល ១០ (ដប់)ថ្ងៃ នៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ក្នុងករណីគ្មានបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ណាមួយទេនោះ គបឃ.ស ត្រូវធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប តាមរយៈលេខាធិការដ្ឋានរាជធានី ខេត្ត រៀបចំការបោះឆ្នោត (លធ.ខប) ។

គណបក្សនយោបាយ ដែលបានចុះបញ្ជីស្របច្បាប់ មានសិទ្ធិស្នើសុំបញ្ជីបោះឆ្នោតដំបូង ច្បាប់ថតចម្លង ឬ PDF File បានដោយបង់ត្រឹមថ្លៃផលិត ។

II. ការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងតវ៉ា ឬ/និង បណ្ដឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

ជនណាក៏ដោយមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាម ទ. ១២០២ ទាក់ទង នឹងបញ្ជីបោះឆ្នោតដំបូងទៅ កបឃ.ស ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

ក- ពាក្យបណ្ដឹងតវ៉ា : អាចធ្វើឡើងអំពីការបាត់ឈ្មោះរបស់អ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែការកត់ត្រាមិនច្បាស់លាស់អំពីករណីដូចតទៅ ៖

-មិនឃើញមានឈ្មោះក្នុងបញ្ជីបញ្ជីបោះឆ្នោតដំបូង (មានបង្ហាន់ដៃបញ្ជាក់ការចុះឈ្មោះ ឬបង្ហាន់ដៃទទួល ការប្តូរការិយាល័យក្នុងឃុំ សង្កាត់ ជាភស្តុតាង) ។

- មានឈ្មោះ ប៉ុន្តែឈ្មោះនោះនៅក្នុងការិយាល័យផ្សេងទៅវិញ ។

- មានឈ្មោះ ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យពាក់ព័ន្ធមានភាពមិនច្បាស់លាស់ ឬមិនត្រឹមត្រូវ ។

- ឃើញឈ្មោះដែរ តែឈ្មោះនោះស្ថិតនៅក្នុងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ។

*ខ-ពាក្យបណ្ដឹងជំទាស់:*អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង តែជននោះគ្មានសិទ្ធិចុះឈ្មោះក្នុងករណីដូចតទៅ ៖

- មិនមានសញ្ជាតិខ្មែរ

- មិនទាន់គ្រប់អាយុចុះឈ្មោះបោះឆ្នោតស្របតាមច្បាប់

- មិនមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់

-ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាង ១ កន្លែង ។

១- ការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់នៅក្រុមប្រឹក្សាឃុំ សង្កាត់

ក- ការដាក់ និងការទទួលបណ្ដឹង

- នៅពេលទទួលបានពាក្យបណ្ដឹង កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ៖

+ ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកប្តឹង ឬ/និងតំណាង

+កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពអំឡុងពេលកំណត់ ១០ ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

- ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង

- ពាក្យបណ្ដឹងដែលគោរពអំឡុងពេលកំណត់ កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀតដែលនៅជាធរមាន និងមានសំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ក្នុងរយៈពេល ៣ ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង (ទ. ១២០២) ។ អ្នកប្តឹងតវ៉ា ឬ/និងអ្នកប្តឹងជំទាស់ត្រូវបង្ហាញឯកសារ ភស្តុតាង ឬសាក្សី ។

ខ- ការប្រជុំសម្រេចជាសាធារណៈរបស់ កបឃ.ស

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបើកការប្រជុំសម្រេចជាសាធារណៈ សម្រេចបដិសេធ ឬយល់ព្រម ដោយធ្វើកំណត់ហេតុប្រជុំសម្រេច ។

ក្នុងករណីបដិសេធ : ត្រូវស្រង់សេចក្ដីសម្រេច "បដិសេធ" ដាក់ក្នុង ទ. ១២០៣ ចំនួន ៣ ច្បាប់ (ករណីបណ្ដឹងជំទាស់) ឬចំនួន ៤ ច្បាប់ (ករណីបណ្ដឹងជំទាស់)) ដោយបញ្ជាក់មូលហេតុ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ ដោយមួយច្បាប់ជូនអ្នកប្តឹងតវ៉ា ឬតំណាង (និងជម្រាបគាត់ថា អាចប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ) មួយច្បាប់ផ្ញើជូន គ.ជ.ប និងមួយច្បាប់រក្សាទុកជាឯកសារ) ។

ក្នុងករណីយល់ព្រម : ត្រូវស្រង់សេចក្ដីសម្រេច "យល់ព្រម" ដាក់ក្នុង ទ. ១២០៣ ចំនួន ៣ ច្បាប់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ (មួយច្បាប់ជូនអ្នកប្តឹងតវ៉ា ឬតំណាង មួយច្បាប់ជូន គ.ជ.ប និងមួយច្បាប់រក្សាទុកជាឯកសារ) ។

២- ការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងនៅ គ.ជ.ប

អ្នកប្ដឹងតវ៉ា អ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ កបយ.ស មានសិទ្ធិប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ. ១២០៣ ។ អ្នកប្ដឹងត្រូវបំពេញ ទ. ១២០២ ចំនួន ៣ ច្បាប់ (ករណីប្ដឹងតវ៉ា) ឬចំនួន ៤ ច្បាប់ (ករណីប្ដឹងជំទាស់) ។

គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្ដឹងក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

៣- ការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

អ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្ត និងសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ. ១២០៣ ។

នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចយល់ព្រមលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចេញសេចក្ដី សម្រេចឲ្យ គ.ជ.ប អនុវត្តតាម ។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ។

៤- ការបំពេញរបាយការណ៍ ស្ដីពីសេចក្ដីសម្រេចរបស់ កបយ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ. ១០២០)

កបយ.ស ត្រូវបំពេញរបាយការណ៍ស្ដីពីសេចក្ដីសម្រេចរបស់ កបយ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូង នៃឃុំ សង្កាត់ (ទ. ១០២០) ចំនួន ៣ ច្បាប់ ដែលមានតារាងជូនភ្ជាប់ជាមួយ និងឯកសារបញ្ជាក់ផ្ញើ ជូននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតតាមរយៈ លធ.ខប (ចំនួន ២ច្បាប់)និងរក្សាទុកជាឯកសារនៅឃុំ សង្កាត់ ១ច្បាប់ ។

កបយ.ស បំពេញទម្រង់បែបបទនេះ នៅពេលបញ្ចប់ការដោះស្រាយបណ្ដឹងនៅថ្នាក់ខ្លួន ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ។

III. ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ

នៅពេលបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ត្រូវបានដោះស្រាយចប់ជាស្ថាពរ គ.ជ.ប ត្រូវបោះពុម្ព និងចាត់បញ្ជូនបញ្ជីបោះឆ្នោតផ្លូវការទៅ លធ.ខប ១ ច្បាប់ សាលាឃុំ សង្កាត់ ១ ច្បាប់ ដើម្បីរក្សាទុកជាឯកសារផ្លូវការ ។ បញ្ជីបោះឆ្នោតផ្លូវការត្រូវមានទិន្នន័យដូចតទៅ : ១. ឈ្មោះ និងលេខកូដរាជធានី ខេត្ត ២. ឈ្មោះ និងលេខកូដ ឃុំ សង្កាត់ ៣. ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត ៤. កូនប្រអប់ និងលេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោត ៥. អត្តលេខអ្នកបោះឆ្នោត ៦. លេខ អ.ខ ឬ ឯ.អ ប្រើពេលចុះឈ្មោះបោះឆ្នោត ៧. រូបថតអ្នកបោះឆ្នោត ៨. នាមត្រកូល និងនាមខ្លួនដែលរៀបចំតាមលំដាប់អក្សរក្រមខ្មែរ ៩. ភេទ ១០. ថ្ងៃខែឆ្នាំកំណើត ១១. លំនៅឋាន ទីសំណាក់ក្នុងឃុំ សង្កាត់ នៃអ្នកបោះឆ្នោត ។

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ មានសិទ្ធិស្នើសុំពិនិត្យមើលឈ្មោះរបស់ខ្លួន ក្នុងបញ្ជីឈ្មោះបោះឆ្នោតនេះបាន ។ គណបក្សនយោបាយមានសិទ្ធិស្នើសុំបញ្ជីបោះឆ្នោតផ្លូវការច្បាប់ចតចម្លងបានដោយបង់ថ្លៃផលិត ។ គ.ជ.ប ត្រូវបង្ហោះបញ្ជីបោះឆ្នោតផ្លូវការនៅលើគេហទំព័ររបស់ខ្លួន ដោយត្រូវធានាការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពរបស់បុគ្គល ដោយបង្ហាញតែឈ្មោះ និងលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត នាមត្រកូល នាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកបោះឆ្នោតប៉ុណ្ណោះ ។

IV. អំពីភ្នាក់ងារគណបក្សនយោបាយ

ភ្នាក់ងារគណបក្សនយោបាយ គឺជាតំណាង ដែលតែងតាំងដោយគណបក្សនយោបាយ និងត្រូវបានអនុញ្ញាត ដោយ កបយ.ស ដើម្បីសង្កេតមើលដំណើរការរៀបចំការចុះឈ្មោះបោះឆ្នោត និងជាអ្នកមានសិទ្ធិប្ដឹងតវ៉ា ឬជំទាស់ ។

គណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ស្ដីពីគណបក្សនយោបាយ មានសិទ្ធិចាត់តាំងភ្នាក់ងារពេញសិទ្ធិរបស់ខ្លួន ១ រូប និងភ្នាក់ងារមប្រុង ១ រូប ដើម្បីសង្កេតមើលការចុះឈ្មោះបោះឆ្នោតនៅតាមសាលា ឃុំ សង្កាត់ និងតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ដែលកំណត់ដោយ គ.ជ.ប ហើយមានសិទ្ធិផ្លាស់ប្ដូរភ្នាក់ងាររបស់ខ្លួន រហូតដល់ម៉ោង ១៧ និង ៣០ នាទី មួយថ្ងៃមុនថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ (២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦) ។ ភ្នាក់ងារពេញសិទ្ធិ ត្រូវបានអនុញ្ញាតឲ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឯភ្នាក់ងារបម្រុងត្រូវអនុញ្ញាតឲ្យចាំនៅខាងក្រៅ ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិក្នុងករណីអវត្តមាន ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឲ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយ សង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោតឡើយ ។ គណបក្សនយោបាយ ដែលមានបំណងចាត់តាំងភ្នាក់ងាររបស់ខ្លួន ដើម្បីសង្កេតមើលការចុះឈ្មោះបោះឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅ កបយ.ស ចាប់ពី ៧ ថ្ងៃ មុនថ្ងៃចាប់ផ្ដើមការចុះឈ្មោះបោះឆ្នោត (ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៦) រហូតដល់ ១០ ថ្ងៃ មុនថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោត (ថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៧) តាមទម្រង់បែបបទលេខ ១០០៧ ដោយមានភ្ជាប់ជាមួយនូវច្បាប់ចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ ១ ច្បាប់ និងមានចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយ ដែលទទួលបានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ ។ ភ្នាក់ងារគណបក្សនយោបាយ គឺជាអ្នកមានសិទ្ធិបោះឆ្នោត និងមានសមត្ថភាពអាចបំពេញការងារបាន ។

ប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ មានសុពលភាព ប្រើប្រាស់បានតែក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ ។

ក.ច.ប ត្រូវរាយការណ៍ទៅ កបយ.ស អំពីវត្តមាន និងសកម្មភាពនានារបស់ភ្នាក់ងារគណបក្សនយោបាយ នៅក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត ។

កំណត់សម្គាល់

ទ. ១២០២ ជាពាក្យបណ្ដឹង

ទ. ១២០៣ ជាសម្រង់សេចក្ដីសម្រេច (កបយ.ស ឬ/និង គ.ជ.ប)

ទ. ១០២០ ជារបាយការណ៍ ស្ដីពីសេចក្ដីសម្រេចរបស់ កបយ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ។

សង្គ្រោះបន្ទាន់ និងអភិរក្ស ប្រាសាទបន្ទាយឆ្នារ

ប្រាសាទបន្ទាយឆ្នារកសាងឡើងក្នុងរជ្ជកាលព្រះបាទជ័យវ៉ារ្ម័នទី ៧ (គ.ស ១១៨១-១២១៨) ។ ប្រាសាទបន្ទាយឆ្នារ រួមមានបណ្ដុំប្រាង្គកណ្ដាលមួយ និងប្រាង្គរណបប្រាំបីសង់នៅចំអ័ក្សធំៗ ទាំងបួន និងហ៊ីមព័ទ្ធដោយកំពែងដី

ប្រាសាទបន្ទាយឆ្នារស្ថិតនៅភូមិបន្ទាយឆ្នារ ឃុំបន្ទាយឆ្នារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ជិតជួរភ្នំដងរ៉ែកចម្ងាយ២២គ.មពីព្រំដែនកម្ពុជា ថៃ និងមានចម្ងាយប្រហែល ១១០ គ.ម ភាគ ពាយ័ព្យនៃទីក្រុងអង្គរ ។

ប្រសាទបន្ទាយឆ្នារកសាងឡើងក្នុងរជ្ជកាលព្រះបាទជ័យវ៉ារ្ម័នទី៧(គ.ស១១៨១-១២១៨) ។ ប្រាសាទបន្ទាយឆ្នារ រួមមានបណ្ដុំប្រាង្គកណ្ដាលមួយ និងប្រាង្គរណបប្រាំបីសង់នៅចំអ័ក្សធំៗ ទាំងបួន និងហ៊ីមព័ទ្ធដោយកំពែងដី ។ នៅផ្នែកខាងកើតប្រាសាទនេះមានបារាយណ៍ ហើយមានប្រាសាទមេបុណ្យ សង់នៅចំកណ្ដាលបារាយណ៍នោះ។បណ្ដុំប្រាង្គកណ្ដាលទាំងមូលហ៊ីមព័ទ្ធដោយកសិន្ទ្ធទឹកមួយ មានរាងស្នើរបួនជ្រុងស្មើ និងមានផ្លូវចូលបួននៅតាមទិសសំខាន់ៗទាំងបួន ដែលអមដោយរូបចម្លាក់ទេវតា និងយក្សទ្រនាគ ដូចនឹងប្រាសាទដទៃទៀតនៃរចនាបថបាយ័នដែរ ។

ប្រសាទបន្ទាយឆ្នារទទួលរងការខូចខាតជាច្រើន ។ កន្លងមកក្រសួងវប្ប ធម៌ និងវិចិត្រ-សិល្ប: តាមរយ:នាយកដ្ឋានគាំពារ និងអភិរក្ស សំណង់បុរាណ បានធ្វើការអភិរក្សប្រាង្គ និងរចនាសម្ព័ន្ធមួយចំនួន ដូចជាប្រាង្គកណ្ដាល ប្រាង្គតាព្រហ្ម ពង្រីកលូបង្ហូរទឹកនៅជ្រុងអាគ្នេយ៍នៃកសិន្ទ្ធទឹក សង់លូនៅមុខខាងកើតស្ពានហាល ស្ពានប្រព័ន្ធទឹកហូរនៅកណ្ដាលស្ពានហាល មុខខាងត្បូង រើខ្លោងទ្វារខាងត្បូងធ្វើជាផ្លូវចេញចូលជួសជុលស្ពានហាលខាងត្បូង សង្គ្រោះបន្ទាន់ប្រាង្គលេខ ១៨ និងជួសជុលរោងទងមុខខាងកើតផ្នែកខាងត្បូង ។

នាពេលថ្មីៗនេះដែរ នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ សហការជាមួយអង្គការជាដៃគូ បានសម្រេចសង្គ្រោះបន្ទាន់ប្រាង្គលេខ ៧០ ដែលស្ថិតនៅជ្រុងនិរ៌តីនៃកំពែងទី ២ និងប្រាង្គតាណែមដែលកំពុងប្រឈម និងហានិភ័យធ្ងន់ធ្ងរ ។ មុខព្រហ្មនៃប្រាង្គតាណែមមានលក្ខ-ណ:ពិសេស តែមិនដូចមុខព្រហ្មនៅប្រាសាទបាយ័ន និងប្រាសាទមួយចំនួននៅតំបន់អង្គរទេ។

ការទល់ទ្ររើរៀបថ្មឡើងវិញ និងចំពេញស្នៀតឈើនិងថ្មពិតជាអាចធ្វើឲ្យប្រាង្គដែលកំពុងប្រឈមនឹងហានិភ័យខ្ពស់ទាំងនោះ មានសុវត្ថិ-ភាព និងឈរធ្ងឹងមាំបានរយ:ពេលយូរ ។ កិច្ចការចំពោះមុខមួយទៀតដែលនាយកដ្ឋានទទួលបន្ទុកត្រូវធ្វើបន្ត នោះគឺត្រួតពិនិត្យមិនឲ្យមានសត្វល្អិតស្រមោច កណ្ដៀរ រុកវានដល់ថ្មប្រាសាទ ការពារមិនឲ្យរលង់ស្នៀតឈើ រៀងរាល់មួយសប្ដាហ៍ម្ដង ។

ដើម្បីថែរក្សាប្រាសាទតាណែម ដែលមានគម្រូមុខព្រហ្មដ៏ពិសេសតែមួយគត់ ឲ្យស្ថិតគង់-វង្សនោះ មន្ត្រីបច្ចេកទេសរបស់នាយកដ្ឋានកំពុងកសាងផែនការជួសជុលរយ:ពេលវែង សម្រាប់ទុកជាគម្រូដល់អ្នកសិក្សាស្រាវជ្រាវ និងភ្ញៀវទេសចរបានទៅទស្សនានាពេលអនាគត ។

សម្រាប់គោលដៅទៅអនាគតរាជរដ្ឋាភិបាលកម្ពុជាតាមរយ:ក្រសួងវប្ប ធម៌ និងវិចិត្រសិល្ប: គ្រោងនឹងដាក់បញ្ចូលប្រាសាទបន្ទាយឆ្នារ ជាសម្បត្ដិបេតិកភណ្ឌពិភពលោក ។

នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ សហការជាមួយអង្គការជាដៃគូ កំពុងសង្គ្រោះបន្ទាន់ប្រាង្គលេខ ៧០ ដែលស្ថិតនៅជ្រុងនិរ៌តីនៃកំពែងទី ២ និងប្រាង្គតាណែម

ស្អាតបី

(ពាក្យ ៧)

១. បានមកជាមនុស្ស បុរស ស្ត្រី
គឺកម្លាំងបុណ្យ បុព្វេផង
២. បានជាមនុស្សហើយ កុំឡើយធ្វេស
ចុះហាយនៈ ធ្លាក់ធ្លោយប្រាណ
៣. រស់នៅត្រូវសាង អំពើល្អ
រៀរផុតអបាយឆ្ងាយទុក្ខា
៤.មួយជម្រះកាយឆ្ងាយផុតបាប
ជីវិតមនុស្សសត្ត តូច ធំក្ដី
៥. លបលួចឆក់ប្លន់ សព្វទ្រព្យា
គំរាមបៀតបៀនគ្មានអនុគ្រោះ
៦. ពីរគឺពាក្យពេចន៍ ពោលវាចា
ពាក្យមានខ្លឹមសារ មានអត្ថន័យ
៧. ពាក្យអសុរោះ ផរុសវាទ
ភូតភរកុហក មិនស្ដីប្រាប់
៨. ស្អាតចិត្តចៀសផុត អគតិបួន
ចិត្តជាកណ្ដាល ន្ទាលត្រេកអរ
៩. ចិត្តគិតប្រព្រឹត្ត កិច្ចសាធារណ៍
សងសឹកគំកួន ស្ងួនវិមុត្ត
១០. មេត្តា ករុណា មុទិតា
ចំពោះសត្វទូទៅទាំងអស់
១១. ចិត្តដឹកនាំសត្ត ចាត់តាមកម្ម
ចិត្តបាបឆ្ពោះឆេះកាយា
១២. ច្នេះគួរប្រព្រឹត្តបានខ្ជាប់ខ្ជួន
ជីវិតពិតបាន សុខសួស្ដី

កម្រក្រាក្រី ក្រែកន្លង
រុញច្រានតបស្ដង ទើបកើតបាន ។
សតិប្រហែសភ្លាត់សន្ដាន
រហូតខកខាន ក្សាន្ដសុខា ។
បណ្ដុះគុណធម៌ជាប់អាត្មា
ប្រើប្រាស់ប្រាជ្ញា បានស្អាតបី ។
រៀរកាប់សម្លាប់ សព្វសត្ត្ववអ្ងី
នៅលើលោកិយ សឹងចង់រស់ ។
ផ្ដន្ទាកិបកេង ប្រវ៉ាញ្ជោះ
គឺព្រោះលោភលន់ គ្មានខន្ដី ។
គួរពិចារណា មុនហាស្ដី
ទន់ភ្លន់ប្រពៃ ពីរោះស្ដាប់ ។
ទ្រគោះគ្រោតគ្រាតឮឈឺចាប់
សាស័ព្ទពាក្យពិតសុចរិតល្អ ។
ប្រកាន់ខ្ជាប់ខ្ជួន យុត្ដិធម៌
រាប់រកស្មោះសរបរិសុទ្ធ ។
តាមគោលមាគ៌ាព្រះសម្ពុទ្ធ
រំលត់ទោសៈ ដោយសប្បុរស ។
និងឧបេក្ខា ការសន្ដោស
អាណិតសង្គ្រោះរស់សង្ខារ ។
ចិត្តបុណ្យគុណចាំ នាំសុខា
នាំសោយទុក្ខា អវិចី ។
ប្រយោជន៍ដល់ខ្លួនបានស្អាតបី
នៅនាលោកិយ លុះបរលោក ។

នឹម ណាំ

អ្នកណាបោក?

អន្ធិត ជុក និងនាង ជិន ទើបរៀបការបានប្រមាណមួយខែក៏ទាស់គ្នាប្រាវ។ ជិន សម្លក់ជុក ស្ទើរស៊ីសាច់ ហើយស្រែក ៖

- បងឯងបោកប្រាស់ខ្ញុំ ធ្វើឲ្យខ្ញុំខូចខ្លួនបាត់អស់ភាពក្រមុំ !

-អ្ហ៊ាក!រួចចុះបងបោកប្រាស់អូនរឿងស្អី ?

-បងឯងអួតថា ខ្លួនមានទ្រព្យសម្ដត្ដិច្រើន កេរឌ៉ិពុកចែកឲ្យព្រោះតែជឿសំដីហ្នឹងហើយ ទើបខ្ញុំព្រមរៀបការជាមួយ ។ ប៉ុណ្ណឹងហើយនៅថាមិនបានបោកប្រាស់ទៀតឬ ?

នាយ ជុក តម្លើងសំឡេងតប ៖

-ចុះអូនវិញយ៉ាងម៉េចដែរ ? ពេលបងប្រាប់ថា មានទ្រព្យសម្ដត្ដិច្រើន អូនឯងថា អត់ចង់បានទ្រព្យសម្ដត្ដិទេ ចង់បានតែចិត្ដស្មោះត្រង់ប៉ុណ្ណោះ។ ឥឡូវអូនឯងមិននិយាយពីចិត្ដស្មោះត្រង់ បែរជានិយាយពីទ្រព្យសម្ដត្ដិទៅវិញ។ បើបែបនេះ តើអ្នកណាបោកប្រាស់អ្នកណា ? ។

ចង់រៀបការ

ក្នុងថ្នាក់រៀន អ្នកគ្រូបានតម្រូវឲ្យសិស្សគ្រប់គ្នា គូរនូវរូបភាពតាមការស្រមើលស្រមៃចង់បានរបស់ខ្លួនទៅថ្ងៃអនាគត ។

ពេលប្រមូលក្រដាសពីសិស្ស គាត់ឃើញក្រដាសខ្លះគូររូបយន្ដហោះ ដែលបញ្ជាក់ថា អ្នកគូរចង់ក្លាយជាអ្នកបើកយន្ដ-ហោះ ។ ឯក្រដាសខ្លះទៀត គូររូបប្រដាប់ស្វ័ងជំងឺ បញ្ជាក់ថាចង់ក្លាយជាវេជ្ជបណ្ឌិត ។ ក្រដាសខ្លះគូររូបកងទ័ពលីកាំភ្លើង បញ្ជាក់ថាចង់ក្លាយជាកងកម្លាំងការពារទឹកដី ។ ដោយឡែកក្រដាសរបស់សិស្សស្រីម្នាក់គឺសស្អាតគ្មានរូបអ្ងីសោះ ទើបអ្នកគ្រូសួរ ៖

-ប្អូនឯងគ្មានចំណង់ចំណូលចិត្ដចង់ធ្វើអ្ងីទេ ពេលធំឡើង ?

-ចា៎ៈ..ចើមិនចង់! ខ្ញុំចង់ដល់ពេលធំឡើងនឹងរៀបការប្ដីម្នាក់ តែមិនដឹងថាមានរូបរាងយ៉ាងម៉េចផង ទើបមិនទាន់អាចគូរបានហ្នឹងណា៎ ។

ស្ងាត់ស្ងៀម!

ថ្ងៃនេះ នាយ ម៉ាប់ បានចូលរួមការប្រឡងសម្រាប់សិស្ស ពេទ្យបឋម ។ គណៈមេប្រយោគ លើកបន្ទះថ្នាំមួយដែលមានថ្នាំ ១៤ គ្រាប់សួរបេក្ខជនម៉ាប់ ៖

-ឧបមាថា អ្នកជំងឺម្នាក់ដែលជំងឺរបស់គាត់តម្រូវឲ្យលេបថ្នាំនេះ មិនអាចលេបផឹកថ្នាំណាផ្សេងទៀតបាន តើប្អូនកំណត់ឲ្យគាត់លេបថ្នាំនេះក្នុង ១ ថ្ងៃប៉ុន្មានគ្រាប់ ?

-បាទ ដោយហេតុជំងឺគាត់អ៊ីចឹង ខ្ញុំតម្រូវឲ្យគាត់លេបថ្នាំនេះ ១ ថ្ងៃ ១ បន្ទះបាទ ។

ចប់ចម្លើយភ្លាម គណៈមេប្រយោគក្រោកឈរព្រមគ្នាដោយស្ងាត់ស្ងៀម ឥតនិយាយថាអ្ងីឡើយ ។

ឃើញដូច្នេះ បេក្ខជន ម៉ាប់ ប្រញាប់ឆ្លើយបន្ត :

-សូមទោស ប្រហែលច្រឡំមាត់ បាទ !

ខណៈនោះ លោកមេប្រយោគម្នាក់គំហក :

-ស្ងាត់ស្ងៀមភ្លាម! ពួកខ្ញុំកំពុងស្ទឹងស្ទាធ គោរពវិញ្ញាណក្ខ័ន្ធអ្នកជំងឺសំណាងអាក្រក់រូបនោះដឹងទេ ? ។

សេចក្ដីកែតម្រូវ

សូមធ្វើការកែតម្រូវខ្លឹមសារអត្ថបទដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីប្រជាជនលេខ ១៨៣ ខែសីហា ឆ្នាំ ២០១៦ ទំព័រទី ៩ ជួរទី ២ បន្ទាត់ទី ៩ សូមកែដាក់ថា "សម្ដេចតេជោទទួលយកសំណើនេះ ហើយ....." ។ **សូមអរគុណ**

ចោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខ័ណ្ឌទួលគោក-ភ្នំពេញ
H/P : 012 990 935 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com

អ្នកឧបត្ថម្ភ ទស្សនាវប្តី ប្រជាជន លេខ ១៨៤

១-	លោកជំទាវ	**ម៉ែន**	**សំអាន**	*សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច*	៤០០.០០០រ
២-	ឯ.ឧ	**កែ**	**គឹមយ៉ាន**	*សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ*	១០០ ដុល្លារ
៣-	ឯ.ឧ	**អ៊ុក**	**រ៉ាប៊ុន**	*សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ*	១០០ ដុល្លារ
៤-	ឯ.ឧ	**អូន**	**ពំនួមមួន្នីរ៉ូ**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*	២០០ ដុល្លារ
៥-	ឯ.ឧ	**ភេង**	**សាខុន**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*	១៥០ ដុល្លារ
៥-	ឯ.ឧ	**ហ៊ុន**	**ណេង**	*ប្រធានគណៈកម្មការទី ៤ នៃរដ្ឋសភា*	១០០ ដុល្លារ
៧-	ឯ.ឧ	**ម៉ិន**	**ឃិន**	*ទេសរដ្ឋមន្ត្រី និងលោកជំទាវ **ជួន ជួន***	១០០ ដុល្លារ
៨-	ឯ.ឧ	**ផ្ចាន**	**ខុន**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍*	១០០ ដុល្លារ
៩-	ឯ.ឧ	**អ៊ីត**	**សំហេង**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*	១០០ ដុល្លារ
១០-	ឯ.ឧ	**គង់**	**ឥន្ទ្រ**	*ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*	១០០ ដុល្លារ
១១-	ឯ.ឧ	**លន់**	**លីមថៃ**	*ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម*	១០០ ដុល្លារ
១២-	ឯ.ឧ	**អូស្មាន**	**ហាសឃ្ឆាន់**	*ប្រធានគណៈចលនាសាសនិកសម្លាមនៃគណបក្សប្រជាជនកម្ពុជា*	១០០ ដុល្លារ
១៣-	ឯ.ឧ	**សរ**	**ចាំ**ង	*ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ*	១០០ ដុល្លារ
១៤-	ឯ.ឧ	**ជ**	**សុជាតិវង្ស**	*ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ*	១០០ ដុល្លារ
១៥-	ឯ.ឧ	**ម៉ែន**	**ឥន្ទ្រ**	*ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង*	១០០ ដុល្លារ
១៦-	ឯ.ឧ	**ម៉ម**	**ប៊ុនណាង**	*អនុប្រធានគណៈកម្មការទី ១០នៃព្រឹទ្ធសភា*	១០០ ដុល្លារ
១៧-	ឯ.ឧ	**ឃូ**	**តារ៉ូ**	*អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្តាល ចុះជួយរាជធានីភ្នំពេញ*	១០០ ដុល្លារ
១៨-	**គណៈកម្មាធិការគណបក្សខេត្តឆាត់ដំបង**				១០០ ដុល្លារ
១៩-	**គណៈកម្មាធិការគណបក្សខេត្តសៀមរាប**				១០០ ដុល្លារ
២០-	**គណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ**				១០០ ដុល្លារ
២១-	**គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ**				៥០ ដុល្លារ
២២-	**គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី**				៥០ ដុល្លារ
២៣-	ឯ.ឧ	**លីម**	**គានហោ**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម*	២០០.០០០ ៛
២៤-	ឯ.ឧ	**ម៉ម**	**ប៊ុនហេង**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល*	៥០ ដុល្លារ
២៥-	ឯ.ឧ	**ផា**	**យ៉ាវ**	*អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា*	២១៣.៤៧០រ
២៦-	ឯ.ឧ	**ជ**	**យិនស៊ីម**	*រដ្ឋលេខាធិការក្រសួងសុខាភិបាល*	៥០ ដុល្លារ
២៧-	ឯ.ឧ	**អ៊ុក**	**ច្រាន់ថ្លា**	*រដ្ឋលេខាធិការក្រសួងព័ត៌មាន*	២០០.០០០ ៛
២៨-	ឯ.ឧ	**ឃីម**	**សារ៉ាន្ធ**	*ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្ប្ធម៌ និងវិចិត្រសិល្ប៍*	៥០ ដុល្លារ
២៩-	ឯ.ឧ	**ង៉ាវ**	**ហមជាន**	*រដ្ឋលេខាធិការក្រសួងមហាផ្ទៃ*	៥០ ដុល្លារ
៣០-	ឯ.ឧ	**សូ**	**ជុងហ្ស**	*ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ*	៥០ ដុល្លារ
៣១-	ឯ.ឧ	**ចាយ**	**ប៊ូរិន**	*អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម*	៥០ ដុល្លារ
៣២-	ឯ.ឧ	**សួស**	**យ៉ារ៉ា**	*អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ*	៥០ ដុល្លារ
៣៣-	ឯ.ឧ	**ន**	**រតនៈវឌ្ឍនោ**	*រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា*	២០០.០០០ ៛
៣៤-	ឯ.ឧ	**ឃួន**	**រ៉ានីន**	*រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*	៥០ ដុល្លារ
៣៥-	ឯ.ឧ	**ភេ**	**ខុនជ**ារ៉ា	*អនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកោះកុង*	៥០ ដុល្លារ
៣៦-	ឯ.ឧ	**មាស**	**ឥន្ធី**	*អគ្គលេខាធិការនៃអជ្ញាធរជាតិប្រឆាំងគ្រឿងញៀន*	៥០ ដុល្លារ
៣៧-	ឯ.ឧ	**ម៉ា**	**ប៊ុនណារ៉ា**	*សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា*	២០០.០០០រ
៣៨-	ឯ.ឧ	**ឆាយ**	**ឫទ្ធិសែន**	*អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់*	២០០.០០០រ
៣៩-	ឯ.ឧ.	**ឫទ**	**លីមហេង**	*អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី*	២០០.០០០រ
៤០-	ឯ.ឧ	**សេង**	**ឌ្ឍ**ីង	*ជំនួយការផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន***	២០០.០០០រ
៤១-	ឯ.ឧ	**ម៉ែន**	**ស៊ីផាន់**	*សមាជិកព្រឹទ្ធសភា*	១០០.០០០រ
៤២-	ឯ.ឧ	**ង៉ាន**	**ប៊ុនធ្ឿ**ន	*រដ្ឋលេខាធិការក្រសួងផែនការ*	១០០.០០០រ
៤៣-	លោកជំទាវ	**ស៊ីង**	**ស៊ីយុត**		១០០.០០០រ
៤៤-	ឯ.ឧ	**គឹម**	**ធា**	*ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង*	១០០.០០០រ
៤៥-	ឯ.ឧបណ្ឌិត	**មាស**	**ប៊ូ**	*អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍*	១០០.០០០រ
៤៦-	លោកជំទាវ	**ទិត្យ**	**ចំន្ទតារ៉ា**ន	*អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*	១០០.០០០រ
៤៧-	ឯ.ឧ	**ជ្ម**ន	**ផេ**ង**ហ**ាត	*ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរ**ិន*	១០០.០០០រ
៤៨-	ឯ.ឧ	**ម៉ា**	**ឡាំ**ង	*អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន*	១០០.០០០រ
៤៩-	លោក	**អោម**	**ចន**	*ប្រធានទាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ*	១០០.០០០រ
៥០-	លោក	**គឹម**	**ប៊ុណ្ណា**	*សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សខេត្តសៀមរាបប្រធានសាខាគណបក្សមន្ទីរសាធារណការ និងដឹកជញ្ជូន*	១០០.០០០រ
៥១-	ឯ.ឧ. ឧកញ៉ា	**សន**	**ឆ្ងាសល**	*អនុប្រធានគណបក្សស្រុកកំពង់សិលា*	២០ ដុល្លារ
៥២-	កញ្ញា	**ផ**ាង	**ន**ិ**ត**ហ៊ីរ	*មន្ត្រីក្រសួងទេសចរណ៍*	៦៦.៦៦៦រ
៥៣-	លោកជំទាវ	**ខេង**	**សំ**ង**ាដ**ា	*រដ្ឋលេខាធិការក្រសួងកិច្ចការនារី*	៥០.០០០រ
៥៤-	ឯ.ឧ	**អ៊ុ**ន	**ណ**ាលី	*សមាជិកក្រុមប្រឹក្សាខេត្តកោះកុង*	៥០.០០០រ
៥៥-	ឯ.ឧ	**ពត**	**ចាន់**នី	*សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម*	៥០.០០០រ
៥៦-	ឯ.ឧ	**ហេ**ង	**ឫ**ណ្ណា	*សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ*	៥០.០០០រ
៥៧-	ឯ.ឧ	**ង៉ា**ង	**ចាន់**	*សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ*	៥០.០០០រ
៥៨-	លោកជំទាវ	**ស្រ៊ី**	**ចំន្ទ**ថា		៥០.០០០រ

អ្នកឲ្យបត្តម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៨៤

៥៩-	លោក	**មួល**	**ទិចិត្រ**	ប្រធានគណៈកម្មាធិការគណបក្សក្រុងដូនកែវ ខេត្តតាកែវ	៥០.000រ
៦០-	លោក	**ជ**	**ឫទ្ធី**	សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ	៥០.000រ
៦១-	លោក	**អ៊ុ**	**រាត្រី**	អភិបាលរងខេត្តបន្ទាយមានជ័យ	៥០.000រ
៦២-	លោក	**ចាប**	**ឌីណា**	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ដដូនពេញ ប្រធានគណៈកម្មការផ្សារកណ្ដាល	៥០.000រ
៦៣-	**គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំគណៈកម្មាធិការសម្រាបសម្រួលខ្មែរកម្ពុជាក្រោម**				៤០.000រ
៦៤-	លោក	**ថោ**	**ថេដ្ឋា**	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	៤០.000រ
៦៥-	លោក	**លី**	**សារ**	អភិបាលរង ខេត្តបន្ទាយមានជ័យ	៤០.000រ
៦៦-	លោក	**គឹម**	**សុវណ្ណ**	ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ	៤០.000រ
៦៧-	ឯ.ឧ	**សុិន**	**ឫទ្ធី**	សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម	៣០.000រ
៦៨-	ឯ.ឧ	**ឈុំ**	**វណ្ណារិទ្ធ**	អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល	៣០.000រ
៦៩-	ឯ.ឧ	**សាំង**	**សាវ៉ាត**	សមាជិកក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ	៣០.000រ
៧០-	លោក	**ម៉ៅ**	**សុខលីម**	អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ	៣០.000រ
៧១-	លោក	**ចាន់**	**សុំណាត**	សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម	៣០.000រ
៧២-	លោក	**ឃូ**	**ពៅ**	អភិបាលស្រុកស្វាយចេក	៣០.000រ
៧៣-	លោក	**ទេព**	**ទិសិដ្ឋ**	អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ	៣០.000រ
៧៤-	កញ្ញា	**កែវ**	**សុជាតា**	អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា	៣០.000រ
៧៥-	លោក	**ភាត**	**ហ៊ីង**	ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ	៣០.000រ
៧៦-	លោក	**ហាង**	**ឃុ**	ប្រធានក្រុមការងារចុះ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ	២០.000រ
៧៧-	លោក	**ឈា**	**ចុំនរិទ្ធ**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	២០.000រ
៧៨-	លោក	**ម៉ៅ**	**ហាត់**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	២០.000រ
៧៩-	លោក	**លីម**	**ទីរ៉ារ**	សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម	២០.000រ
៨០-	លោក	**លីម**	**ថេង**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	២០.000រ
៨១-	លោក	**ឃ្លោក**	**សំអាង**	សមាជិកក្រុមការងារចុះខេត្តកំពង់ចាម	២០.000រ
៨២-	លោក	**ម៉ី**	**ឫទ្ធា**	មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង	២០.000រ
៨៣-	លោក	**អ៊ីត**	**សំអាន**	អគ្គារធិការវង់នៃអធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	២០.000រ
៨៤-	លោក	**ជ**	**គឹមលីន**	ជំនួយការ ឯកឧត្តម **ប៊ូ ថង**	២០.000រ
៨៥-	លោក	**ឃិន**	**សុខសំអ្ម៉ែន**	ជំនួយការ ឯកឧត្តម **ប៊ូ ថង**	២០.000រ
៨៦-	លោក	**ភួង**	**ចាន់ធិត្យ**	អាជីវករ ខេត្តបន្ទាយមានជ័យ	២០.000រ
៨៧-	លោក	**អ៊ីង**	**សាវន**	អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ	១៥.000រ
៨៨-	ឯ.ឧ	**សេង**	**សុមុនី**	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា	១០.000រ
៨៩-	ឯ.ឧ	**ប៉ាញ**	**សម្ជ:**	អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម	១០.000រ
៩០-	លោក	**ម៉ុ**	**លីហ្ជត**	សមាជិកក្រុមការងារចុះខេត្តកំពង់ចាម	១០.000រ
៩១-	លោក	**ជួន**	**វណ្ណារិទ្ធ**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
៩២-	លោក	**ឌួន**	**ពេជ្រ**	ប្រធាននាយកដ្ឋានទឹកស្អាត ក្រសួងធនធានទឹក និងឧតុនិយម	១០.000រ
៩៣-	លោក	**ម៉ម**	**ឃ្ម្រស**	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម	១០.000រ
៩៤-	លោក	**សៅ**	**សម្ផស្ស**	អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម	១០.000រ
៩៥-	លោក	**ង៉ាត**	**មុយមុំង**	អនុប្រធានគណៈកម្មាធិការសាខាបក្សមជ្ឈមណ្ឌលផ្ដល់ឈាមនៃមន្ទីរពេទ្យព្រះអង្គឌួង	១០.000រ
៩៦-	លោក	**ឈុន**	**ចុំនលៀ**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
៩៧-	លោក	**ថេង**	**ចុំនតេង**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
៩៨-	លោក	**ស្វាយ**	**សុគន្ធ**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
៩៩-	លោក	**សុខ**	**ចំណាន**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១០០-	លោក	**សៅ**	**សម្ភារ**	ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម	១០.000រ
១០១-	លោក	**ទិត**	**ចរិយា**	ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម	១០.000រ
១០២-	លោក	**សែម**	**សំណាង**	ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម	១០.000រ
១០៣-	លោក	**សុខ**	**តារា**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១០៤-	លោក	**ស**	**ជំណ្ដ**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១០៥-	លោក	**ហ្ជត**	**ចាន**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១០៦-	លោក	**ទីម**	**ឫដ្ឋារ៉ា**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១០៧-	លោក	**ណុប**	**រ៉ៃមណី**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១០៨-	លោក	**សារុន**	**សម្ផត្តិ**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១០៩-	លោក	**សរ**	**ទិចិត្រ**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១១០-	លោក	**ឌួច**	**សុជណ្ណា**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១១១-	លោក	**ជ**	**ឌ្ឍត្ត**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១១២-	លោក	**ឈ្លាង**	**ចុំយ**	សមាជិកក្រុមការងារចុះខេត្តកណ្ដាល	១០.000រ
១១៣-	លោក	**យស់**	**ធុល**	សមាជិកក្រុមការងារចុះស្រុកពោធិ៍រៀង ខេត្តព្រៃវែង	១០.000រ
១១៤-	លោក	**ឡូង**	**ចន្ធា**	សមាជិកក្រុមការងារចុះស្រុកពោធិ៍រៀង ខេត្តព្រៃវែង	១០.000រ
១១៥-	លោក	**ឡាច**	**ឌីរ៉ាត់**	សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង	១០.000រ
១១៦-	លោក	**ឈាង**	**សុវណ្ណារ៉ា**	មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង	១០.000រ

សម្តេចមហាពញាចក្រី **ហេង សំរិន** អញ្ជើញទៅកាន់បិណ្ឌទី ៤ នៅវត្តប្រជុំនទី ហៅវត្តក្រពើហារ នៅក្រុងតាខ្មៅ ... ៤

សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅប្រទេសឡាវ ... ៥



កម្ពុជាខិតខំពង្រីកទីផ្សារ និងធ្វើសមាហរណកម្មឲ្យកាន់តែស៊ីជម្រៅក្នុងតំបន់អាស៊ាន..... ... ៨

សម្តេចតេជោ:ផ្តល់សារសំខាន់ បំផុតលើការចុះឈ្មោះបោះឆ្នោត ១១

សម្តេចក្រឡាហោម **ស ខេង** អំពាវនាវឲ្យប្រជាជនចូលរួមកសាងប្រទេស តាមរយៈការអភិវឌ្ឍមូលដ្ឋានថ្នាល់ ... ១៤

សម្តេចវិបុលសេនាកត្តិ **សាយ ឈុំ** អញ្ជើញចុះសួរសុខទុក្ខនិងស្វែងយល់ពីវត្ថុភាពរស់នៅ របស់បងប្អូនជនជាតិអិស្លាម..... ... ១៥

និពន្ធនាយក :

លោក តាក ស៊ុនអ៊ី

គណៈកម្មការនិពន្ធ

១. លោក ខ្យៀ ណារី

២. លោក អ៊ីម សុន្ទរ:

៣. លោក រ៉ង្ស សារ៉ុត

៤. លោក ទាវ សារ:មុនី

៥. លោក សុខ សុផន

លេខានិពន្ធ

១. លោក ជុំ សម្បត្តិ

២. លោក ម៉ក់ ឈិន

អ្នកបកប្រែភាសា

១. លោកស្រី ម៉ែន នារីសោភ័ត

អ្នកថតរូប

១. លោក សុផាត រ៉ី:មុនី

វិចិត្រករ

១. លោក ធា សារ៉ុត

អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

Address :

No 203 Preah

Norodom Bld.

Phnom Penh Cambodia

Tel : 023 219 065

ក្រុមមុខ

*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន***
ប្រធានរដ្ឋសភា និងលោកជំទាវ
ក្នុងឱកាសអញ្ជើញកាន់បិណ្ឌទី ៤
នៅវត្តប្រជុំនទី (ក្រពើហារ)ក្រុងតាខ្មៅ
ខេត្តកណ្តាល ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១៦

មាតិកា
Contents

វិចារណកថា : *គ្មានអ្នកណាអាចមកបំផ្លាញដំណើរការរីកចម្រើននៃកម្ពុជាបានឡើយ* ១

Editorial : *No One Can Obstruct Cambodia's Path of Progress* .....

⇨ *ទោះក្នុងតម្លៃណាក្តី ត្រូវតែការពារសុខសន្តិភាពជូនប្រជាជន*..... ៣

⇨ *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស* ១៦

⇨ *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស* ២០

⇨ *លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច* ២២

⇨ *រួមគ្នាប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម និងស្តារគុណភាពដី ដើម្បីបង្កើនផលិតកម្មកសិកម្ម* ២៣

⇨ *ផ្លែផ្កាជាវិជ្ជមាននៅក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ វិស័យអប់រំឆ្នាំ ២០១៤-២០១៨* ២៦

⇨ *ស្វែងយល់អំពីច្បាប់បោះឆ្នោត : អំពីបញ្ជីបោះឆ្នោតដំបូង និងការប្តឹងតវ៉ា ឬការប្តឹងជំទាស់* ២៨

⇨ *វប្បធម៌ : សង្ក្រានៈបន្ទាន់ និងអភិរក្សប្រាសាទបន្ទាយឆ្នារ* ៣០

⇨ *កំណាព្យ : ស្ពានបី* ..... *សំណើច* ៣១

ទស្សនាវដ្ដី

ប្រចៀងជ័យ

THE PRACHEACHUN MAGAZINE

ឆ្នាំទី១៦ លេខ ១៤៤ ខែកញ្ញា ឆ្នាំ ២០១៦

មន្ទីរពេទ្យជប៉ុនសាន់អ៊ាយស៍ ស្ថិតនៅក្នុងភូមិ ២ សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ

(សម្ពោធថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១៦)

ចែកចាយដោយឥតគិតថ្លៃ